**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Driot et des Sciences Economiques

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ការធ្វើទំនើបភាវូបនីយកម្ម
# រដ្ឋបាលសារពើពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យ៉ាន់ លក្ខិណា**

**ស៊ុនអ៊ី សីរៈ**

សាស្ត្រាចារ្យណែនាំ

លោក **ភើយ វិញ្ញគឿម**

ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **យ៉ាន់ លក្ខិណា និង ស៊ុនអ៊ី ស៊ីរះ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២២ ក្រុម L4C4 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ វិទ្យាសាស្ត្រ សេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២២ **យើងខ្ញុំសូមគោរពលំអោនកាយវាចាចិត្តសម្តែងនូវការវគិច្ចនិងមហាកត្តញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

**មាតិបិតា** របស់យើងខ្ញុំ កូនសូមអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះ គុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបានរបស់លោកឪពុកអ្នកម្តាយដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ទំនុកបម្រុងកូនៗទាំងពីរអោយតស៊ូរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ កូនទាំងពីរសូមដើម្បីសម្តែងនូវកត្តញ្ញូចំពោះគុណដ៏ថ្លៃថ្លា និង ដ៏ធំធេងមួយនេះព្រមទាំងសូមបួងសួង អធិដ្ឋានដល់ព្រះជាម្ចាស់លោកតាមថែរក្សាអ្នកមានគុណអោយប្រកបតែសេចក្តីសុខ សុខភាពមាំមួន និងភាពចុំថ្កើងរុងរឿងជាដរាប ។

**សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ វិទ្យាសាស្ត្រ សេដ្ឋកិច្ច**ជាពិសេសសូមថ្លែងអំណាគុណ និងការដឹងគុណចំពោះ **ឯកឧត្តម លុយ ចន្ធ្នា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួមទាំង **សកលវិទ្យាធិការង គណៈកម្មការ ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ** ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង និងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធិភាពការងារខ្ពស់។ ទោះបីជាជំនាន់យើងខ្ញុំស្ថិតនៅក្នុងវិបត្តិជាសាកលនៃការរីករាលដាលនៃជម្ងឺ កូវីដ១៩យ៉ាងណាក៏ដោយក៏គណៈគ្រប់គ្រងសាលាលោកគ្រូអ្នកគ្រូ ទាំងអស់បានរិះរកគ្រប់វិធីសាស្ត្រដើម្បីអោយយើងខ្ញុំអាចបន្តរៀនរហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ ជាពិសេសការបង្រៀនតាមបែបឌីជីថលតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលយើងខ្ញុំជានិស្សិតបានទទួលការបណ្តុះបណ្តាលផងដែរ។

យើងខ្ញុំទាំងពីរនាក់សូមសម្តែងការដឹងគុណចំពោះលោកគ្រូសាស្ត្រាចារ្យ **កើយ វិញគឿម** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយលោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងផ្តល់យោបល់ជាគំនិតល្អៗត្រួសត្រាយផ្លូវ និងបង្ហាត់បង្រៀនវិធីសាស្ត្រល្អៗដល់យើងខ្ញុំទាំងពីររហូតដល់ការសរសេររបាយការណ៍សារណាបញ្ចប់ថ្នាក់ឧត្តមសិក្សានេះប្រកបដោយជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរដល់ **សាកលវិទ្យាធិការ សកលវិទ្យាធិការរង គណៈកម្មការ ព្រឹទ្ធបុរស លោក លោកស្រី និងសាស្ត្រាចារ្យគ្រប់ៗរូប ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** រួមទាំងលោកគ្រូសាស្ត្រាចារ្យ **កើយ វិញគឿ** សូមជួបប្រទះតែសុភមង្គលមាន សុខភាពល្អ ព្រមទាំងប្រកបការងារអ្វីៗអោយបានជោគជ័យប្រកបដោយឧត្តមភាព និងភាពចុំថ្កើងជានិរន្តរ៍។

# **អារម្ភកថា**

ក្នុងនាមយើងខ្ញុំទាំងពីរជានិស្សិតផ្នែក **នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំទី៤ ថ្នាក់L4C4 នៃឆ្នាំសិក្សា ២០២១-២០២២ យើងមានសេចក្តីសោមនស្សរីករាយក្រៃលែង បន្ទាប់ពីយើងខ្ញុំបាននឹងកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយយើងខ្ញុំបានចងក្រងនូវសារណាដ៏សំខាន់មួយក្រោមប្រធានបទ "**ការធ្វើទំនើបកាវូបនីយកម្មរដ្ឋបាលសារពើពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា**"។ សារណាបញ្ចប់ការសិក្សាជំនាញនីតិសាស្ត្រនៅចំពោះមុខនេះ គឺជាសមិទ្ធិផលដែលកើតចេញពីការខិតខំប្រឹងប្រែងស្រាវជ្រាវចងក្រងដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានាដែលជាការរួមចំណែកមួយ ដើម្បីផ្សព្វផ្សាយចែករំលែកនូវចំណេះដឹង និងបង្ហាញអោយយើងបានយល់ពីច្បាប់ពន្ធក៏ដូចជាកំណែទម្រង់រដ្ឋបាលសារពើពន្ធនៅកម្ពុជាបច្ចុប្បន្ន។ ទាំងនេះគឺជាការចែករំលែកចំណេះដឹងពុទ្ធិ ទស្សនៈទានសំខាន់ៗ សារៈសំខាន់នៃការបង់ពន្ធ និងប្រព័ន្ធពន្ធដារ ជូនដល់ពលរដ្ឋ សិស្សនិស្សិតអោយកាន់តែជ្រាបច្បាស់បន្ថែមទៀត។ អស់រយៈពេល៤ឆ្នាំ កន្លងមកនេះ យើងខ្ញុំបានក្រេបជញ្ជក់ និងទទួលបាននូវពុទ្ធិ ក៏ដូចជាចំណេះដឹង បទពិសោធន៍ជាច្រើនទាក់ទងនឹងវិស័យច្បាប់ និងចំណេះដឹងទូទៅផ្សេងៗមួយចំនួនទៀត។ ទន្ទឹមនិងនេះយើងខ្ញុំចាត់ទុកសាលាជាភូមិកំណើតដែលបង្កើតក៏ដូចជាសាបព្រោះនូវកោសិកាគំនិត ព្រោះសាលាមិនត្រឹមតែផ្តល់នូវចំណេះដឹងដល់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជាគុណធម៌ និងសីលធម៌ដល់យើងខ្ញុំផងដែរ។

ជាចុងក្រោយយើងខ្ញុំរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តអ្នកអានអ្នកស្រាវជ្រាវចូលរួមវាយតម្លៃអត្ថបទសារណានេះនូវរាល់កំហុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនានៃការសរសេរក៏ដូចជាពាក្យពេជន៍ វគ្គឃ្លា វេយ្យាករណ៍ ដើម្បីចូលរួមជួយកែលំអអោយសៀវភៅនេះកាន់តែប្រសើរជាងនេះទៀត។

យើងខ្ញុំសូមជូនពរ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិត្តអ្នកអាន អ្នកស្រាវជ្រាវ និង មិត្តនិស្សិតទាំងអស់អោយទទួលបាននៅភាពជោគជ័យគ្រប់ភារកិច្ចទាំងអស់។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០២២

**យ៉ាន់ លក្ខិណា** **ស៊ុនអ៊ី ស៊ីរៈ**

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារកម្ពុជា**

**ផ្នែកទី១ សញ្ញាណទូទៅនៃរដ្ឋបាលសារពើពន្ធ** ........ ៤

១.១ និយមន័យ........ ៤

១.២ ប្រវត្តិនៃការកកើត........ ៥

១.៣ ទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ........ ៦

**ផ្នែកទី២ អំពីប្រព័ន្ធពន្ធដារកម្ពុជា**........ ៨

២.១ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ ........ ៨

២.១.១ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ........ ៨

២.១.២ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម ........ ១០

២.២ ប្រភេទពន្ធដោយសង្ខេប ........ ១០

២.៣ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ........ ២៦

២.៤ បទល្មើសពន្ធដារ និងទោសទណ្ឌ ........ ២៩

**ជំពូកទី២ ការធ្វើទំនើបកាវូបនីយកម្មរដ្ឋបាលសារពើពន្ធ**

**ផ្នែកទី១ កំណែទម្រង់រដ្ឋបាលសារពើពន្ធ** ........ ៣៤

១.១ ក្របខណ្ឌស្ថាប័ន និងអភិបាលកិច្ច........ ៣៤

១.២ មុខងារប្រតិបត្តិការស្នូល ........ ៣៧

១.៣ មុខងារគាំទ្រ........ ៤២

១.៣.១ ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង........ ៤៥

១.៣.២ បច្ចេកវិទ្យាពត៌មាន........ ៤៦

១.៣.៣ កំណែទម្រង់ធនធានមនុស្ស ........ ៤៨

**ផ្នែកទី២ កំណែទម្រង់គោលនយោបាយសារពើពន្ធ** ........ ៥១

២.១ ការរៀបចំច្បាប់ និងគោលនយោបាយសារពើពន្ធ........ ៥២

២.១.១ គោលនយោបាយអាករពិសេស..........................................................................................៥២
២.១.២ ពន្ធលើអចលនទ្រព្យ ............................................................................................................ ៥៣
២.១.៣ អាករលើតម្លៃបន្ថែម ............................................................................................................ ៥៣
២.១.៤ អាករសម្រាប់បំភ្លឺសារធារណៈ.....................................................................................................៥៤
២.១.៥ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល..................................................................................................៥៤
២.១.៦ ពន្ធលើពាណិជ្ជកម្មតាមប្រពន្ធអេឡិចត្រូនិក...................................................................................៥៥
២.១.៧ វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ ...................................................................................៥៦
២.១.៨ ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ .....................................................៥៦
២.១.៩ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ......................................................................................... ៥៧
២.១.១០ ការរៀបចំប្រព័ន្ធសារពើពន្ធ ......................................................................................................៥៨
២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ........................................................................................................៥៨
**សេចក្តីសន្និដ្ឋាន** ........................................................................................................................ ៦៧
**ការផ្តល់អនុសាសន៍** .....................................................................................................................៦៩
**ឯកសារពិគ្រោះ**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ប្រជាជាតិមួយប្រៀបបានទៅនឹងនាវាដ៏ធំមួយ ដែលទាមទារជាចាំបាច់នូវការគិតគូរពិចារណាយ៉ាងល្អិតល្អន់ពីថ្នាក់ដឹកនាំរដ្ឋក្នុងការប្រមូលចំណូល និងអនុវត្តចំណាយដើម្បីជៀសវាងជួបនូវវិបត្តិណាមួយដោយថាហេតុ។ អាស្រ័យហេតុនេះ គ្រប់ប្រទេសទាំងអស់ក្នុងសកលលោកតែងតែរៀបចំនូវផែនការថវិកាជាតិរបស់ខ្លួនជារៀងរាល់ឆ្នាំដើម្បីគ្រប់គ្រងលើការប្រមូលចំណូលពន្ធ និងវិភាជន៍ចំណាយដើម្បីធានានូវការផ្តល់សេវាសាធារណៈដល់ប្រជាជនប្រកបដោយប្រសិទ្ធភាព និងស្ថិរភាពខ្ពស់។ ដូច្នេះកាលណាចំណាយដែលបានគ្រោងទុកមានចំនួនកាន់តែច្រើននោះក៏ទាមទារនូវប្រភពចំណូលកាន់តែច្រើនផងដែរហើយចំពោះប្រភពចំណូលថវិកាជាតិដែលដើរតួយ៉ាងសំខាន់ជាងគេជាយូរយារមកហើយនោះ គឺជាចំណូលបានមកពីពន្ធដារ និងពន្ធគយ។ ពន្ធបើផ្អែកទៅតាមទស្សនៈរបស់លោក Benjamin Franklin បានលើកឡើងអំពីសារសំខាន់នៃពន្ធថា "នៅក្នុងលោកយើងនេះគ្មានអ្វីដែលទៀងទាត់នោះទេ លើកលែងតែសេចក្តីស្លាប់ហើយនិងពន្ធ ( In this world, nothing can be certain except Death and Taxes) ដែលយើងអាចនិយាយបានថាពន្ធ គឺជាឧបករណ៍ដ៏សំខាន់របស់រដ្ឋក្នុងការប្រមូលធនធានពីប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសមួយ និងជាធាតុផ្សំយ៉ាងសំខាន់នៅក្នុងចំណោមធាតុផ្សំជាសារវន្តដទៃរបស់រដ្ឋ។ ក្នុងន័យនេះពន្ធជាកាតព្វកិច្ច និង ចាំបាច់ដែលរដ្ឋត្រូវដក ឬ ប្រមូលដោយផ្អែកលើមូលដ្ឋានដែលកំណត់ដោយច្បាប់ និង មានទិសដៅបំពេញរាល់ចំណាយដ៏ច្រើនរបស់រដ្ឋដែលឆ្លើយតបទៅនឹងផលប្រយោជន៍សាធារណៈ ហើយពន្ធដារតែងតែវិវត្តន៍ទៅមុខជានិច្ចជាកាលចាំបាច់ត្រូវតែមានការផ្លាស់ប្តូរទៅតាមគោលនយោបាយរបស់រដ្ឋ និងវិវត្តនៃសេដ្ឋកិច្ច សង្គម។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាចំណូលថវិកាជាតិបានមកពីចំណូលសារពើពន្ធដែលមាន ចំណូលពន្ធដារ និងពន្ធគយ រីឯចំណូលមិនមែនសារពើពន្ធបានមកពីធនធានធម្មជាតិ សម្បទាន និងសេដ្ឋកិច្ចគ្រឹះស្ថានសាធារណៈជាដើម។

ពន្ធ គឺប្រភពចំណូលដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលកម្ពុជាព្រោះចំណូលពីការប្រមូលពន្ធត្រូវប្រើប្រាស់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីទ្រទ្រង់ដល់ការចំណាយជាច្រើនរបស់រដ្ឋាភិបាលលើការផ្តល់សេវាសាធារណៈនានាដូចជា បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ បើកប្រាក់បៀវត្សជូនកងទ័ព និងកម្លាំងប្រដាប់អាវុធ និងការពារព្រំដែនបេតិកភណ្ឌ សាងសង់មន្ទីរពេទ្យ ផ្លូវថ្នល់ស្ពាន សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត និងការចំណាយទូទៅ រួមមានសង្គមកិច្ច សេដ្ឋកិច្ច និងការអភិវឌ្ឍ[1] ។ យើងសង្កេតឃើញថាការដាក់ចេញនូវវិធានរាជរដ្ឋាភិបាលកម្ពុជា បានធ្វើការអភិវឌ្ឍយ៉ាងល្អប្រសើរក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះជាមួយនឹង

[1] អគ្គនាយកដ្ឋានកម្ពុជា

អត្រាកំណើនសេដ្ឋកិច្ចដែលបានជាមធ្យមប្រមាណជាង៧% និង កំណើនយ៉ាងកំហុកនៃការប្រមូលពន្ធបានដល់ ២៥%ក្នុងឆ្នាំ២០១៥។ យោងតាមរបាយការណ៍ពីលទ្ធផលការងារប្រមូលចំណូលពន្ធនៅឆ្នាំ២០២១និងទិសដៅការងារ ឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេលពេញមួយឆ្នាំ២០២១កម្ពុជាសម្រេចបានចំណូលពន្ធអាករ សរុបចំនួនជាង២,៧ពាន់លានដុល្លារ(២៧៨១,៩២លានដុល្លារ) ស្មើនឹង១២៤,០២% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងក្នុងឆ្នាំ២០២១។ ដោយចំនួននេះគឺលើសផែនការឆ្នាំ២០២១ចំនួន៥៣៨,៨៥លានដុល្លារ ស្មើ ២៤,០២% បានកំណត់ប្រមូលចំណូលពន្ធចំនួនតែជាង ២,២ពាន់លានដុល្លារ(២២៤៣,០៧លានដុល្លារ)ប៉ុណ្ណោះ។ ដោយឡែកចំពោះលទ្ធផលការប្រមូលពន្ធសម្រាប់ខែធ្នូឆ្នាំ២០២១របស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបានចំនួនជាង២២១,៦៨លានដុល្លារ ស្មើនឹង ៩,៨៨% បើធៀបនឹងរយៈពេល ដូចគ្នាក្នុងឆ្នាំ២០២០ គឺមានចំនួនជាង២៤០លានដុល្លារ។ ការរីកចម្រើននេះក៏មានការចូលរួមដ៏សំខាន់របស់ វិស័យឯកជនផងដែរ ម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយដែលធ្វើអោយ ៉ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា៉កាន់តែប្រសើរឡើងព្រមទាំងមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា និងបានធ្វើកំណែទម្រង់រដ្ឋបាលសារពើពន្ធដែលអាចជួយជំរុញអោយការធ្វើអាជីវកម្មនៅកម្ពុជាកាន់តែងាយស្រួល លឿនរហ័សប្រកបដោយបច្ចេកវិទ្យា និងការធ្វើនីតិវិធីក្នុងការប្រមូលពន្ធកាន់តែមានប្រសិទ្ធភាពឡើង។[2]

## ២.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង៖ (១)ពិពណ៌នាអំពីប្រព័ន្ធពន្ធដារនៅកម្ពុជា (២)បង្ហាញពីកាតព្វកិច្ច និង សិទ្ធិអ្នកជាប់ពន្ធ (៣)អត្ថប្រយោជន៍នៃការបង់ពន្ធ (៤)ចែករំលែកនូវចំណេះដឹងពាក់ព័ន្ធ នឹងវិស័យពន្ធដារ (៥)បង្ហាញពីកំណែទម្រង់រដ្ឋបាល និងគោលនយោបាយសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារនាពេលថ្មីៗនេះ និង (៦)បង្ហាញអំពីលទ្ធផលនៃកំណែទម្រង់ រដ្ឋបាលសារពើពន្ធ។

គោលបំណងទាំងនេះហើយដែលបានជំរុញឱ្យយើងខ្ញុំទាំងពីរព្យាយាមស្វែងរកឯកសារគតិយុត្តនានាជាច្រើនមកចងក្រងជាអត្ថបទដើម្បីធ្វើឱ្យការសរសេរសារណានេះបានសម្រេចឡើង និង ជាគុណតម្លៃសម្រាប់ពលរដ្ឋគ្រប់ៗរូបអាចទទួលបានចំណេះដឹងបន្ថែមអំពីប្រព័ន្ធពន្ធដារកម្ពុជានាពេលបច្ចុប្បន្ន។

## ៣.សារសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះពិតជាមានសារសំខាន់ណាស់ ត្បិតគ្រប់វិស័យទាំងអស់សុទ្ធតែទាក់ទិននឹងពន្ធដារមិនថាវិស័យឯកជន ឬ វិស័យសាធារណៈនោះឡើយ។ ដូច្នេះហើយទាមទារអោយពលរដ្ឋគ្រប់ៗរូបគួរតែស្វែងយល់អោយបានច្បាស់ដើម្បីយល់ដឹងពីអត្ថប្រយោជន៍នៃការបង់ពន្ធ។ ការបង់ពន្ធត្រូវបានចាត់ទុកជាការស្នេហាជាតិ

[2] ឯកសារអង្គការតម្លាភាពកម្ពុជា

និងជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គមជាតិមួយ។ ដូចនេះលទ្ធផលដែលកើតចេញពីការស្រាវជ្រាវមួយនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ជាចំណេះដឹងជូនដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋទូទៅបានយល់ដឹងពីប្រព័ន្ធពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា និង ពីដំណើរការវិវឌ្ឍនៃប្រព័ន្ធពន្ធដារដែលមានលក្ខណៈជឿនលឿនតាមការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថលដែលស្របតាមយុទ្ធសាស្ត្រនិងគោលនយោបាយនានា ដែលបានចេញដោយរដ្ឋាភិបាលក្នុងការប្រមូលពន្ធដែលអនុលោមតាមបទប្បញ្ញត្តិច្បាប់ស្តីពីសារពើពន្ធ និង លិខិតបទដ្ឋានដែលពាក់ព័ន្ធឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

### ៤.ទំហំ និងដែនកំណត់

វិសាលភាពនៃការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើប្រព័ន្ធពន្ធដារ និងកំណែទម្រង់រដ្ឋបាលសារពើពន្ធកម្ពុជារួមបញ្ចូលជាមួយនិងការយល់ដឹងពីប្រភេទពន្ធ និងការធ្វើទំនើបកម្មសេវាកម្មពន្ធដារដោយអគ្គនាយកដ្ឋានពន្ធដារដែលជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ក្នុងការរុករករបកគំហើញថ្មីក្នុងការបង់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលស្របទៅតាមការវិវត្តនៃបច្ចេកវិទ្យាក្នុងពេលបច្ចុប្បន្ន និងធ្វើការសម្រេចលើវិធានគតិយុត្តិនានាដើម្បីប្រមូលពន្ធ និងបង្កើនចំណូលថវិការជាតិ។

### ៥.ចំណោទបញ្ហា

នៅក្នុងសារណានេះបានផ្តោតសំខាន់លើប្រព័ន្ធពន្ធដារកម្ពុជា និងកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានអនុវត្តនាពេលកន្លងមក និងបានចោទឡើងនូវសំណួរគតិយុត្តិជាច្រើនថាតើប្រព័ន្ធពន្ធដារនៅប្រទេសកម្ពុជាមានលក្ខណៈដូចម្តេច? មានប៉ុន្មានប្រភេទពន្ធ? និង តើពន្ធដារកម្ពុជាមានកំណែទម្រង់យ៉ាងដូចម្តេចខ្លះ?

### ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានព្យាយាមស្វែងរកឯកសារផ្លូវការពីគ្រប់ប្រភពពាក់ព័ន្ធទាំងអស់ដែលរួមមានដូចជា ច្បាប់ស្តីពីសារពើពន្ធ អនុក្រឹត្យ ប្រកាស សារាចរណ៍ណែនាំ សេចក្តីសម្រេច និង លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងឯកសារអត្ថបទផ្លូវការផ្សេងៗទៀតជាច្រើន។

ដើម្បីងាយស្រួលយល់ក្នុងការបកស្រាយប្រធានបទនេះអោយបានក្បោះក្បាយព្រមទាំងឆ្លើយតបទៅនឹងបញ្ហាគតិយុត្តដែលចោទសួរខាងលើនេះ ក្រុមយើងខ្ញុំបានរៀបចំចែកជាពីរជំពូកធំៗ និងផ្នែកដូចតទៅ៖

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារកម្ពុជា**

**ជំពូកទី២ ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ**

# ជំពូកទី១
# ទិដ្ឋភាពទូទៅ
# នៃប្រព័ន្ធពន្ធដារកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃប្រព័ន្ធពន្ធដារកម្ពុជា

## ផ្នែកទី១៖ សញ្ញាណទូទៅនៃរដ្ឋបាលសារពើពន្ធ

### ១.១ និយមន័យ

យោងតាមវចនានុក្រមសម្តេចសង្ឃរាជជួនណាត ពាក្យ "**ពន្ធ ឬពន្ធន៍**" ត្រូវបានផ្តល់និយមន័យថាជាសួយ ឬអាករដែលប្រជានិករត្រូវបង់តាមកំណត់ ហើយមួយវិញទៀត ពន្ធនៅក្នុងន័យនេះ អាចត្រូវបានបែងចែកជាពន្ធចំពោះ និង ពន្ធមិនចំពោះ។[3] ដោយឡែកសន្ទានុក្រម ខ្មែរ-បារាំង នៃពាក្យច្បាប់បានផ្តល់និយមន័យ "**ពន្ធ**" គឺជាវិភាគទានខាងផ្នែកហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋដែលបង់សម្រាប់ការចំណាយរបស់រដ្ឋ និង របស់សមូហភាពដែនដី។[4]

១.ពន្ធ គឺជាឧបករណ៍ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូលមួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ចដូចជា៖ ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងប្រជាពលរដ្ឋដើម្បីបំរើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

២.ពន្ធ គឺជារូបធាតុ នៃការប្រមូលចំណូលមួយដែលផ្សារភ្ជាប់ជាមួយនឹងសិទ្ធអំណាចរបស់រដ្ឋាភិបាលដែលបានក្រឹត្យដោយច្បាប់ជាធរមាន។

៣.ពន្ធ គឺជាការបង់វិភាគទានកាតិព្វកិច្ច របស់គ្រប់សមាសភាពសង្គម ទាំងឡាយដែលរួមមានទាំងរូបវន្តបុគ្គល និងនីតិបុគ្គលជូនរដ្ឋាភិបាលដែលបានកំណត់ដោយច្បាប់ជាធរមាន។

៤.ពន្ធ គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពនៃសង្គមដែលត្រូវបានកំណត់ដោយច្បាប់។ ការបង់ពន្ធគឺជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ឬស្ថាប័នពាក់ព័ន្ធនានាដែលត្រូវបង់ជូនរដ្ឋដើម្បីចូលរួមចំណែកការពារ និងអភិវឌ្ឍន៍ជាតិមាតុភូមិ។

ពន្ធដារត្រូវបានគេចាត់ទុកថា ជាឧបករណ៍ស្របច្បាប់របស់រដ្ឋក្នុងការកៀគរចំណូលជាតិពីប្រជាជន។ ក្នុងន័យនេះប្រជាពលរដ្ឋគ្រប់រូបត្រូវបង់វិភាគទានជូនរដ្ឋសម្រាប់ជាចំណូលដល់ថវិកាជាតិ ដើម្បីធានាដល់ការចំណាយសេវាសាធារណៈទូទៅទាំងផ្នែកសង្គមកិច្ច សេដ្ឋកិច្ចដែលសម្រាប់បម្រើដល់ការអភិវឌ្ឍលើគ្រប់វិស័យ។

ជារួមយើងអាចនិយាយបានថាពន្ធ គឺជាកាតព្វកិច្ចមួយដែលប្រជាពលរដ្ឋត្រូវបំពេញ ព្រោះការចូលរួមបង់ពន្ធបានបង្ហាញពីស្មារតីស្នេហាជាតិ និងការប្រកាន់ខ្ជាប់នូវកាតព្វកិច្ចក្នុងការចូលរួមចំណែកដល់ការប្រមូល

[3] វចនានុក្រមឆ្នាំ១៩៦៧,ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិទ, ទំព័រទី៧៥២

[4] សន្ទានុក្រមបារាំង-ខ្មែរ នៃពាក្យច្បាប់ ឆ្នាំ២០០៥, ទំព័រទី១៥២

ចំណូលថវិកាជាតិដ៏សំខាន់សម្រាប់ទ្រទ្រង់ដល់ដំណើរការនៃស្ថាប័នរដ្ឋក្នុងការផ្តល់សេវាសាធារណៈបានកាត់បន្ថយវិសមភាពសង្គម និងរក្សាសុខមាលភាពសង្គម និងសេដ្ឋកិច្ច។

### ១.២ ប្រវត្តិនៃការកកើត

តាមការស្រាវជ្រាវការកកើតពន្ធ ឬ ទ្រឹស្តីទាក់ទិននឹងពន្ធត្រូវបានគេរកឃើញថាបានកើតឡើងស្រប ជាមួយនឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និង នៅពេលដែលមានការកកើតចេញឡើងនូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស ហើយការអនុវត្តនៃសង្គមមនុស្សជាហេតុដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធដែលបិតនៅលើរបត់មួយដ៏យូរលង់ត្រូវបានឆ្លោះមករកភាពទំបើបដូចពេលបច្ចុប្បន្ន។ ជាក់ស្តែងរដ្ឋខ្មែរបានចាប់កំណើតនៅក្នុងសតវត្សទី១នៃគ្រិស្តសករាជពោលគឺនៅក្នុងសម័យហ្វូណន។ ហើយចំពោះការប្រមូលពន្ធមានតាំងពីសម័យមុនមកម្ល៉េះ តាមរយៈប្រវត្តិសាស្រ្តបន្តរហូតដល់សម័យហ្វូណនមានសម័យកាលជាច្រើនទៀតដូចជា សម័យចេនឡា សម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គ និងសម័យចតុមុខ។ ការប្រមូលពន្ធនៅសម័យនោះមានការកំណត់អត្រាពន្ធមិនច្បាស់លាស់ អសមធម៌ និងមិនជាក់លាក់តាមច្បាប់កំណត់នោះទេ គឺរាល់ច្បាប់ទាំងអស់ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ព្រះមហាក្សត្រ ឬ បុគ្គលដែលមានអំណាចតែប៉ុណ្ណោះ។ លុះមកដល់អំឡុងឆ្នាំ១៨៦៣ បារាំងបានចូលខ្លួនមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយកម្ពុជាទៅជាទឹកដីអាណានិគមរបស់ខ្លួននាឆ្នាំ១៨៨៤ បារាំងបាននាំយកច្បាប់ និងការគ្រប់គ្រងរដ្ឋបាលមកអនុវត្តនៅកម្ពុជាជាពិសេសគឺវិស័យសារពើពន្ធផងដែរ។ បន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបារាំងនៅថ្ងៃទី០៩ ខែវិច្ឆកា ឆ្នាំ១៩៥៣ កម្ពុជាយល់ឃើញថាមានភាពពិបាកក្នុងការវិលត្រឡប់ទៅអនុវត្តច្បាប់ខ្មែរបុរាណវិញណាស់ដោយហេតុថាប្រទេសកម្ពុជាពេលនោះបានក្លាយទៅជាគ្រួសារច្បាប់រ៉ូម៉ាំងរួចទៅហើយ ដូច្នេះផលវិបាកនៅកម្ពុជា គឺជាច្បាប់ពន្ធដារដែលមានឫសគល់ចេញពីច្បាប់-បារាំង។[5]

ដោយយើងអាចដឹងពីប្រវត្តិនៃការកកើតពន្ធដារនៅកម្ពុជាតាមរយៈឯកសារនានាមួយចំនួន ចាប់ពីឆ្នាំ១៩៥៣ រហូតដល់បច្ចុប្បន្ន។ នៅឆ្នាំ១៩៥៣ បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងជាអកុសលដោយសារវិបត្តិសង្គ្រាមផ្ទៃក្នុងនៅឆ្នាំ១៩៧៥ ដល់១៩៧៩បានធ្វើអោយប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ទៅវិញ។ បន្ទាប់ពីអ្នកស្នេហាជាតិទាំងឡាយរបស់យើងបានដឹកនាំរំដោះប្រទេសជាតិចេញពីសង្គ្រាមប្រល័យពូជសាសន៍ នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣ ក៏ប៉ុន្តែនៅឆ្នាំ១៩៩៣ ដល់ ២០០៨ នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជត្រូវបានប្តូរទៅឈ្មោះ

[5]នីតិពន្ធដារ ដោយលោកគ្រូ គង់ ប៊ុនធី

នាយកដ្ឋានពន្ធដារ និងក្នុងឆ្នាំ២០០៨ ដោយសារប្រទេសមានសុខសន្តិភាព បានធ្វើអោយវិស័យពន្ធដារកាន់តែមានភាពរីកចម្រើនបានបានប្រែក្លាយនាយកដ្ឋានពន្ធដារទៅជាអគ្គនាយកដ្ឋានពន្ធដាររហូតដល់បច្ចុប្បន្ន ។[6]

### ១.៣ ទស្សនវិស័យ បេសសកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

ទស្សនវិស័យ ៖ អគ្គនាយកដ្ឋានពន្ធដារបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានទស្សនៈវិស័យជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្តលើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ។

បេសសកម្ម ៖ អគ្គនាយកដ្ឋានពន្ធដារមានបេសសកម្មផ្តល់នូវសេវាកម្មដែលមានគុណភាពពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សាមញ្ញភាព និងសមធម៌ ដើម្បីជំរុញអ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធដារប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

ភារកិច្ច ៖ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចដូចតទៅ

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងបរិបទអន្តរជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានស្តីពីពន្ធដារ កំណត់បញ្ជីឯកសារនិងលិខិតយុត្តិការនានាសម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវានិងព័ត៌មានដល់អ្នកជាប់ពន្ធដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានតឹងទារ និងទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញតិស្តីពីពន្ធដារ

[6] បទបង្ហាញស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់សមាគមសាលាត្រាជូ រៀបរៀងដោយ លោកគ្រូ កើយ វិញគឿម

- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំនិងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិននឹងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**គុណតម្លៃ៖**

- ការអនុវត្តៈ អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ និងតឹងរ៉ឹង ចំពោះជនដែលមិនអនុលោមតាមច្បាប់។
- វិជ្ជាជីវៈប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញដើម្បីផ្តល់នូវសេវាដែលមានភាព ស័ក្តិសិទ្ធិភាព ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព។
- សុចរិតភាព: ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាពសាមញ្ញ និងងាយស្រួល។
- គារវភាពៈ ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព។
- ភាពបត់បែនៈ ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីឱកាសដែលមាន។
- ការផ្តល់សេវាជូនអ្នកជាប់ពន្ធប្រកបដោយគុណភាពជាភារកិច្ចចម្បងរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីកាត់ បន្ថយបន្ទុក លើកទឹកចិត្ត និងកសាងទំនុកចិត្តដល់អ្នកជាប់ពន្ធ។

**រចនាសម្ព័ន្ធ៖** អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធដែលមានប្រព័ន្ធចាត់តាំងឯកភាពទទួលខុសត្រូវគ្រប់គ្រង និងត្រួតពិនិត្យទូទាំងប្រទេស នូវការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។[7]

**អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធដូចខាងក្រោម៖**

**ក. ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ

[7] ប្រកាសស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ លេខ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០១៧

- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ (ថ្នាក់ស្មើនាយកដ្ឋាន)
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ (ថ្នាក់ស្មើនាយកដ្ឋាន)។

**ខ. ថ្នាក់មូលដ្ឋាន**

នៅខណ្ឌនានាក្នុងរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួន មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាលជាជំនួយការ។

នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យ នៃសាខាពន្ធដារខេត្ត ខណ្ឌ និងដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ។

## ផ្នែកទី២៖ អំពីប្រព័ន្ធពន្ធដារកម្ពុជា

### ២.១ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ

របបពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាមានចំនួន៣របបនៅមុនឆ្នាំ២០១៦ គឺ របបស្វ័យប្រកាស របបម៉ៅការ និងរបបបំព្រួញ។[8] ដោយមានការកែទម្រង់ស៊ីជម្រៅលើវិស័យពន្ធដារតាមរយៈច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ព្រះរាជាណាចក្រកម្ពុជាក៏បានផ្លាស់ប្តូរមកអនុវត្តនូវរបបកំណត់ពន្ធតែមួយគឺ "របបស្វ័យប្រកាស" តាមរយៈការបែងចែងចំណាត់ថ្នាក់អ្នកជាប់ពន្ធជា ៣ ប្រភេទគឺអ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច។

ចំពោះការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំ និងតាមទ្រព្យសកម្មអាជីវកម្មទៅតាមវិស័យចម្បងរួមមាន៖ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម និងពាណិជ្ជកម្ម។[9] ការកំណត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានលក្ខខណ្ឌ ដូចតទៅ៖

#### ២.១.១ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

- **អ្នកជាប់ពន្ធតូច**

អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែល៖

ក.មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម

[8] មាត្រា៤នៃច្បាប់សារពើពន្ធ

[9] ប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៩ ចុះថ្ងៃទី១២ ខែមករា ២០២១

សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ.មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១ ៦០០លានរៀលសម្រាប់វិស័យឧស្សាហកម្ម ឬ

គ.មានផលរបរប្រចាំឆ្នាំក្នុងរយៈពេល បី ខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០លានរៀល ឬ

ឃ. រំពឹងថាមានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាខាងមុខចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ង.ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញនិងសេវារួមទាំងភាស៊ី។[10]

❖ **អ្នកជាប់ពន្ធមធ្យម**

អ្នកជាប់ពន្ធមធ្យម គឺជាបុគ្គលដែលស្ថិតនៅក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោមៈ

ក.ផលរបរប្រចាំឆ្នាំលើសពី១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ.មានផលរបរប្រចាំឆ្នាំលើសពី១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬ

គ.មានផលរបប្រចាំឆ្នាំលើសពី១ ៦០០ លានរៀល ដល់ ៨ ០០០លានរៀលសម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ.ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

ង.ជាស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគមន៍ឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬ គម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ ឬ

ច.ជាបេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនោះ។[11]

❖ **អ្នកជាប់ពន្ធធំ**

អ្នកជាប់ពន្ធធំ គឺជាបុគ្គលដែលស្ថិតនៅក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមៈ

ក.មានផលរបបប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម

ខ.មានផលរបបប្រចាំឆ្នាំលើសពី ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្មនិងពាណិជ្ជកម្ម

គ.មានផលរបបប្រចាំឆ្នាំលើសពី ៨ ០០០ លានរៀល សម្រប់វិស័យឧស្សាហកម្ម ឬ

ឃ.ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ

ង.ជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

[10]ប្រកាសលេខ០០៩ ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

### ២.១.២ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម

ក្នុងករណីផលរបរ ដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែងរបស់អ្នកជាប់ពន្ធទេនោះអគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្ម ដែលបានប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសដូចតខាងក្រោម៖

- **អ្នកជាប់ពន្ធតូច**

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០លានរៀល ដល់ ១ ០០០លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម

- **អ្នកជាប់ពន្ធមធ្យម**

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១ ០០០លានរៀល ដល់ ២ ០០០លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម

- **អ្នកជាប់ពន្ធធំ**

ក-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ-មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម

## ២.២ ប្រភេទពន្ធដោយសង្ខេប

ដោយផ្អែកតាមទ្រឹស្តីទូទៅនៃពន្ធដារនៅកម្ពុជា ពន្ធមាន២ប្រភេទ គឺ ពន្ធផ្ទាល់ និង ពន្ធប្រយោល៖

ពន្ធផ្ទាល់ គឺជាពន្ធដែលប្រមូលពីអ្នកជាប់ពន្ធជាបុគ្គល ឬនីតិបុគ្គលដែលត្រូវបង់ដោយផ្ទាល់ពីបុគ្គលម្នាក់ៗជូនរដ្ឋបាលសារពើពន្ធដោយផ្អែកតាមគោលការណ៍សមត្ថភាពក្នុងការបង់ (Ability to pay Principle) ដូចជា៖ ពន្ធលើថ្លៃឈ្នួលដីនិងផ្ទះ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធលើប្រាក់ចំណូល ពន្ធលើអចលនទ្រព្យ ពន្ធតែមប្រ៏សារពើពន្ធ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយាន្តជំនិះគ្រប់ប្រភេទ ។ល។

ពន្ធប្រយោល គឺជាពន្ធលើការប្រើប្រាស់ដែលរដ្ឋខ្ចីដៃសហគ្រាស ឬអ្នកលក់ប្រមូលពីអ្នកប្រើប្រាស់ ដោយមិនផ្អែកលើសមត្ថភាពរបស់បុគ្គលណាម្នាក់ក្នុងការបង់ពន្ធឡើយដែលនិយមហៅថាអាករមានដូចជា៖ អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ។ ល។

ក្នុងនោះចរិកាដែលបានពីការប្រមូលចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានអាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធប៉ាតង់ ពន្ធលើដីធ្លីមិនប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធ តែម ប្រើសារពើពន្ធ ពន្ធលើអចលនទ្រព្យ ពន្ធលើឈ្នួលផ្ទះ និងដី [12] និងចរិការដ្ឋបាលថ្នាក់ជាតិ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករពិសេស ពន្ធអប្បបរមា និងពន្ធកាត់ទុក ជាដើម ។[13]

នៅក្នុងប្រព័ន្ធពន្ធដារនៅកម្ពុជាយើងនឹងធ្វើការបកស្រាយបង្ហាញអំពីរបបនៃអ្នកជាប់ពន្ធ ប្រភេទនៃអ្នកជាប់ពន្ធ និងប្រភេទពន្ធដោយសង្ខេបផងដែរ។

**១.ពន្ធលើប្រាក់ចំណូល**

♦ និយមន័យ

ពន្ធលើប្រាក់ចំណូល ៖ ត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ពន្ធលើប្រាក់ចំណូលកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

♦ អត្រាពន្ធ

លើប្រាក់ចំណូលប្រចាំឆ្នាំមានអត្រាដូចតទៅៈ

១- ២០ភាគរយ(២០%)ចំពោះប្រាក់ចំណូលដែលសម្រេចបានដោយនីតិបុគ្គល

២- ៣០ភាគរយ(៣០%) ចំពោះប្រាក់ចំណូលដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និង ឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំងព្រៃឈើ រ៉ែមាស ឬត្បូងថ្មមានតម្លៃនានា។

៣- ០ភាគរយ(0%) ចំពោះប្រាក់ចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៤- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោមចំពោះប្រាក់ចំណូលដែលសម្រេចបានដោយរូបវន្តបុគ្គលសហគ្រាសឯកបុគ្គល និង ចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គលៈ[14]

---

[12] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លេខ៥៥០ច ល ចុះថ្ងៃទី២១ ខែមិថុនា ២០១១

[13] ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

[14] ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ លេខនស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ មីនា ២០០៣

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | ពន្ធអត្រា |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១២.000.000 ៛ | 0% |
| ពី | ១២.000.00១ ៛ | ដល់ | ១៨.000.000 ៛ | ៥% |
| ពី | ១៨.000.00១ ៛ | ដល់ | ១0២.000.000 ៛ | ១0% |
| ពី | ១0២.000.00១៛ | ដល់ | ១៥0.000.000៛ | ១៥% |
| លើសពី | ១៥0.000.000៛ | | | ២0% |

ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ក្នុងការធានារ៉ាប់រងឬ ធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ខាងក្រោមៈ

ក. ៥ភាគរយ (៥%) នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬ ធានា រ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬនូវហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា។

ខ. ២0ភាគរយ(២0%) ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និង សកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់តាមមាត្រា ២0ថ្មី(មួយ)។

**២.ពន្ធលើប្រាក់បៀវត្ស**

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ។[15] រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និង ប្រាក់បៀវត្សប្រភពបរទេស។ រូបវន្តអនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្សនៅមុនពេលបើកប្រាក់បៀវត្សទៅដល់និយោជិត និង បង់ប្រាក់ពន្ធនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី២៥នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបើក។

សម្រាប់និយោជិតនិវាសនជនប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកតាមអត្រាកំណើនតាមថ្នាក់ដូចតទៅៈ

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់ |
|---|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១.៣00.000 ៛ | 0% | 0 រៀល |
| ពី | ១.៣00.00១ ៛ | ដល់ | ២.000.000 ៛ | ៥% | ៦0.000 រៀល |
| ពី | ២.000.00១ ៛ | ដល់ | ៨.៥00.000 ៛ | ១0% | ១៦0.000 រៀល |
| ពី | ៨.៥00.00១ ៛ | ដល់ | ១២.៥00.000 ៛ | ១៥% | ៥៨៥.000 រៀល |
| លើសពី | ១២.៥00.000 ៛ | | | ២0% | ១.២១0.000 រៀល |

[15] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្សលេខ ៥៤៣ សហវ ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ២០២១ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២០% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក។ ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែសហគ្រាស ក្រុមហ៊ុនត្រូវកាត់ទុក និងបង់ប្រាក់ពន្ធតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។

**៣.ពន្ធកាត់ទុកទូទៅ**

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោមលើការទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖
  - អត្រា ១៥ ភាគរយ(១៥%) ចំពោះប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញ សេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន។
  - អត្រា ១០ភាគរយ (១០%) ចំពោះប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ
  - អត្រា ៦ភាគរយ(៦%) ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានការកំណត់
  - អត្រា ៤ភាគរយ(៤%) ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានការកំណត់

ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ឱ្យធនាគារ និងស្ថាប័នសញ្ជ័យធនក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩ថ្មីនៃច្បាប់នេះ។

- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធ ចំនួន ១៤ភាគរយ(១៤%) នៃទឹកប្រាក់ត្រូវបើក៖
  - ការប្រាក់
  - សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ
  - ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា ដែលនិងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ភាគលាភ

➢ ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនតាមមាត្រា ២៥ថ្មីនៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អនិវាសនជនតាមមាត្រា២៦ថ្មីនៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ដែលមានបញ្ជាក់ក្នុង មាត្រាទាំង២ ខាងលើនេះ។

## ៤.ពន្ធអប្បបរមា

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែក និងផ្សេងៗពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសលើកលែងតែ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា ១% លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

## ៥.ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាម អត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

## ៦.ពន្ធលើឈ្នួលផ្ទះ និងដី

♦ **និយមន័យ**

ពន្ធឈ្នួលផ្ទះ និងដីត្រូវបានកំណត់យកលើប្រាក់ឈ្នួលដែលបានប្រមូលពីកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករពីការជួលៈ អាគារដែលសង់លើដីដូចជាផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យយន្តបករណ៍ដែលជាប់ជាមួយគ្រឹះស្ថាន ឧស្សាហកម្ម ឋាបនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហ៍កម្មដែលនៅនឹងមួយកន្លែង អាគារធំៗដែលដាក់ធាតុរាវ ឬផលិតផលផ្សេងៗ ដូចជាប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ ផ្ទះបណ្តែតទឹក កប៉ាល់សំរាប់ធ្វើលំនៅដ្ឋាន ឬដើម្បីប្រកបអាជីវកម្មផ្សេងៗ។ ដីធ្លីដែលគ្មានសំណង់ដោយរាប់បញ្ចូលទាំងកន្លែងយកថ្មយករ៉ែ ធ្យូងថ្ម បឹងបួរ ឬស្រែអំបិល។ ករណីអ្នកជួលជាសហគ្រាសចុះបញ្ជីពន្ធដារក្នុងរបបស្វ័យប្រកាស ប្រាក់ឈ្នួលនេះត្រូវបានបង្វែរមកគិតពន្ធនឹងបង់តាមវិធានពន្ធកាត់ទុកទូទៅវិញក្នុងអត្រា១០%។

ពន្ធនេះមិនត្រូវអនុវត្តទេចំពោះកម្មសិទ្ធិករ ឬសិទ្ធវន្តរបស់កម្មសិទ្ធិករ ដែលបានប្រកាសចំណូលប្រាក់ឈ្នួលគិតបញ្ចូលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស។

♦ **មូលដ្ឋានកំណត់ពន្ធ**

អត្រាលើឈ្នួលផ្ទះ និងដី ត្រូវកំណត់ស្មើនឹង១០% នៃប្រាក់ឈ្នួលដុល ហើយប្រាក់ឈ្នួលដុលជាប្រាក់ដែលបានចុះក្នុងកិច្ចសន្យា។

- **ការលើកលែងពន្ធ និងការអនុគ្រោះពន្ធ**

ពន្ធនេះត្រូវបានលើកលែងចំពោះគ្រប់ករណីជួលទាំងឡាយ ដែលសរុបប្រាក់ឈ្នួលប្រចាំខែមានតម្លៃក្រោម ៥០០ ០០០ រៀល។

**៧.ពន្ធប៉ាតង់**

- **និយមន័យ**

ពន្ធប៉ាតង់ ជាពន្ធប្រចាំឆ្នាំដែលកំណត់លើផលរបរសរុបប្រចាំឆ្នាំ និងប្រភេទអ្នកជាប់ពន្ធដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

- **ចំនួនទឹកប្រាក់ដែលត្រូវបង់**

**ក.អ្នកជាប់ពន្ធតូច៖** ត្រូវបង់ពន្ធប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល។

**ខ.អ្នកជាប់ពន្ធមធ្យម៖** ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល។

**គ.អ្នកជាប់ពន្ធធំ៖** ដែលមានផលរបរ

- លើសពី ២ ០០០ លានរៀល ដល់ ១០ ០០០ លានរៀលត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ លានរៀល
- លើសពី ១០ ០០០ លានរៀល ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៥ ០០០ ០០០ លានរៀល

អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងខេត្ត/ក្រុងតែមួយមិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេប៉ុន្តែបើមានមុខរបរអាជីវកម្មខុសៗគ្នាឬស្ថិតនៅក្នុងខេត្ត/ក្រុងផ្សេងគ្នាត្រូវបង់ពន្ធប៉ាតង់ទៅតាមមុខរបរនីមួយៗ និងទៅតាមខេត្ត/ក្រុងដោយឡែកៗពីគ្នា។ អ្នកជាប់ពន្ធត្រូវដាក់តាំង ឬព្យួរប័ណ្ណប៉ាតង់នៅទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួន។

**៨.ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយាន្តជំនិះគ្រប់ប្រភេទ**

- **និយមន័យ**

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ គឺជាពន្ធប្រចាំឆ្នាំ ដែលអនុវត្តលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដូចជា៖

- រថយន្តទេសចរណ៍ ( ឧទាហរណ៍៖ Camry ឆ្លាម)
- រថយន្តដឹកទំនិញ
- រថយន្តដឹកអ្នកដំណើរ

- រ៉ឺម៉កសណ្តោង
- ជលយាន ឬជលយានយន្ត (លើសពី១៥០ សេះ) ទាំងផ្លូវទន្លេ និងសមុទ្រ។

ពន្ធនេះ គឺជាពន្ធផ្ទាល់ សម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

- ♦ **អត្រាពន្ធ មូលដ្ឋានគិតពន្ធ**

អត្រាពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដូចខាងក្រោមៈ

ក- រថយន្តទេសចរណ៍ (គិតតាមឆ្នាំផលិត និងទំហំស៊ីឡាំង)

ខ- រថយន្តដឹកទំនិញ (គិតតាមទម្ងន់សរុប)

គ- រ៉ឺម៉កសណ្តោង (គិតតាមទម្ងន់សរុប)

ឃ- ក្បាលរថយន្តសណ្តោង និងស៊ីមីរ៉ឺម៉កសណ្តោង (ត្រូវបង់ពន្ធរួមគ្នាគិតតាមទម្ងន់សរុប)

ង- រថយន្តដឹកអ្នកដំណើរ (គិតតាមឆ្នាំផលិត និងចំនួនកៅអី)

ច- ជលយាន ឬជលយានយន្ត (គិតតាមទម្ងន់ផ្ទុកសរុប ឬគិតតាមប្រវែងបណ្តោយ ឬគិតតាមកម្លាំងសេះ)

ឆ- យាន ឬយានយន្តកែច្នៃ (គិតតាមចំនួនភ្លៅ និងកង់)។

## ៩.ពន្ធលើដីធ្លីមិនបានប្រើប្រាស់

- ♦ **និយមន័យ**

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាប្រភេទពន្ធប្រចាំឆ្នាំ ដែលកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់[16]។ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានគោលបំណងដើម្បីៈ

- ទប់ស្កាត់រាល់រូបភាពទិញដីទុកមិនប្រើប្រាស់ រង់ចាំពេលឡើងថ្លៃលក់យកកម្រៃលើស
- ជំរុញការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និងមានការអភិវឌ្ឍ
- បង្កើនសកម្មភាពសេដ្ឋកិច្ចនិងកម្លាំងការងារ
- រួមចំណែកដល់ប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

- ♦ **កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ**

ពន្ធនេះជាប្រភេទពន្ធស្វ័យប្រកាស ដែលតម្រូវឱ្យកម្មសិទ្ធិករនៃដីជាប់ពន្ធនិងអ្នកជួលដីពីរដ្ឋ ត្រូវមកចុះបញ្ជីព្រមទាំងដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់នៅអគ្គនាយកដ្ឋានពន្ធដារចំពោះដី ដែលស្ថិតនៅ

[16] លិខិតបទដ្ឋានស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ លេខ០០៧ សសរ.សហវ.ពដ ចេញថ្ងៃទី២៩ ធ្នូ ២០០៥

រាជធានីភ្នំពេញ និងនៅខេត្ត ឬ នៅសាខាពន្ធដារខេត្តដែលដីនោះស្ថិតនៅ។ អ្នកជាប់ពន្ធត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ♦ អត្រាពន្ធ ៖ពន្ធនេះត្រូវកំណត់តាមអត្រា ២% នៃមូលដ្ឋានគិតពន្ធ។

## ១០.ពន្ធប្រថាប់ត្រា

- ♦ **កម្មវត្ថុនៃការប្រមូលពន្ធប្រថាប់ត្រា**

ដោយផ្អែកតាមជំពូកទី៣ផ្នែកទី១ដែលចែងពីបទបញ្ញត្តិមួយចំនួនស្តីពីពន្ធប្រថាប់ត្រានៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ៖

- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន
- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត ដូចជា ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន[17]

- ♦ **និយមន័យ**

១- ពាក្យ"រង្វង់ញាតិ" សំដៅដល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ

- រវាងឳពុកម្តាយបង្កើតនិងកូនបង្កើត
- រវាងប្តីនិងប្រពន្ធ
- រវាងយាយ-តាបង្កើតនិងចៅបង្កើត
- រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត
- រវាងឳពុក-ម្តាយក្មេក និងកូនប្រសារ
- រវាងយាយ-តាក្មេកនិងចៅប្រសារ។

២-ពាក្យ "តម្លៃចុះកិច្ចសន្យា" សំដៅដល់តម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៣-ពាក្យ "តម្លៃភាគហ៊ុន" សំដៅដល់តម្លៃនៃការផ្ទេរភាគហ៊ុន ផ្អែកតាមតម្លៃទីផ្សារ។

៤-ពាក្យ "ថវិការដ្ឋ" សំដៅដល់ថវិកាជាតិ ឬថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងមាតិកាថវិកាប្រចាំឆ្នាំនីមួយៗ។

[17] ប្រកាស ស្តីពីការប្រមូលពន្ធប្រថាប់ត្រា៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ មេសា ២០១៧

៥-ពាក្យ "ទំនិញឬសេវា" សំដៅដល់ទំនិញ សំណង់ ឬសេវា។

៦-ពាក្យ "ប្រទានកម្ម" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៧-ពាក្យ "ប្រធានសក្តិ" សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍ដែលកើតឡើង ដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបានដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុបកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៨-ពាក្យ "ភាគហ៊ុន" សំដៅដល់ចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬការលក់អាជីវកម្ម របស់ក្រុមហ៊ុននីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ សហគ្រាសឯកបុគ្គល ដែលបានចុះបញ្ជី ឬ មិនបានចុះបញ្ជី នៅក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

៩-ពាក្យ "មធ្យោបាយដឹកជញ្ជូនឬយានយន្ត" សំដៅដល់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដូចជា រថយន្ត ទូក កាណូត កប៉ាល់ សាឡាង។ល។

១០-ពាក្យ "លិខិតមានលក្ខណៈតតិយុត្ត" សំដៅដល់លិខិតមានលក្ខណៈតតិយុត្តស្តីពីការបង្កើតក្រុមហ៊ុនលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងស្ថាប័នមានសមត្ថកិច្ច។

១១-ពាក្យ "សន្តតិកម្ម" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិតាមរយៈបណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬបញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់។

១២-ពាក្យ "អចលនទ្រព្យ" សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ) ឬមិនបានចុះបញ្ជី(គ្មានប័ណ្ណកម្មសិទ្ធិ) ក្តី។

- **ប្រការ៥ការលើកលែងនិងការអនុវត្តពន្ធប្រថាប់ត្រា**

**១.ការលើកលែងពន្ធ** ៖ ពន្ធប្រថាប់ត្រាត្រូវបានលើកលែងដូចខាងក្រោម៖

ក-ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ពីដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សាងសង់លំនៅដ្ឋាន ឬ និងធ្វើកសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

ខ-ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ

-ការធ្វើសន្តតិកម្ម រវាងឪពុក-ម្តាយបង្កើត និងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើត និងចៅបង្កើត និងពីឪពុក-ម្តាយទៅឱ្យកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

-ការធ្វើប្រទានកម្មលើកទី១ រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាង យាយតាបង្កើតនិងចៅបង្កើត ពីឪពុកម្តាយទៅឱ្យកូនបង្កើត និង កូនប្រសារដែលជាសហព័ទ្ធរបស់ កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងពីយាយតាទៅឱ្យចៅបង្កើត និងចៅប្រសារដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ-ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តនិងត្រាក់ទ័រគ្រប់ប្រភេទ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

ឃ-ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និង មធ្យោបាយដឹកជញ្ជូនឬយានយន្តដែលត្រូវកត់ត្រាចុះបញ្ជីសារពើភណ្ឌរបស់ស្ថាប័នរដ្ឋនានានៃព្រះរាជាណាចក្រកម្ពុជា។

ង-ការទទួលកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ និង មធ្យោបាយដឹកជញ្ជូនឬយានយន្តរបស់បេសកកម្មការទូត ឬ កុងស៊ុលបរទេស ឬ អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ច-ការទិញមធ្យោបាយដឹកជញ្ជូន ឬ យានយន្ត ធ្វើជាទំនិញដើម្បីលក់វិញ របស់សហគ្រាសនានាដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធអាករប្រចាំខែនិងប្រចាំឆ្នាំ។ ដោយឡែកការទិញមធ្យោបាយដឹកជញ្ជូន ឬ យានយន្ត ដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការ និង ដឹកជញ្ជូនមិនត្រូវលើកលែងពន្ធប្រថាប់ត្រានេះទេ។

ឆ-ការទទួលបានសិទ្ធិកាន់កាប់ភាគហ៊ុនរបស់អ្នកវិនិយោគមូលបត្រ តាមរយៈការជួញដូរមូលបត្រ ក្នុងទីផ្សារដំបូងឬក្នុងទីផ្សារបន្ទាប់។ ការផ្ទេរភាគហ៊ុនការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាការកែប្រែរចនាសម្ព័ន្ធភាពពនិក ដូចជាការបំបែកភាគហ៊ុនរបស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុងវិស័យមូលបត្រតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះត្រូវមានលិខិតបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា។ ដោយឡែកករណីដែលក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបានដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជនអ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុនកន្លងមក ដោយអនុលោមតាមប្រកាសនេះលើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីគណៈកម្មការមូលបត្រកម្ពុជាដោយផ្អែកលើមូលហេតុសមស្របដូចជាករណីប្រធានសក្តិជាដើម។

**២.ការអនុគ្រោះពន្ធ៖** ពន្ធប្រថាប់ត្រាត្រូវបាន អនុគ្រោះដូចខាងក្រោម៖

ក-ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ និង រវាងបងប្អូន បង្កើត និង បងប្អូនបង្កើតត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ២០០,០០០,០០០(ពីររយលាន)រៀល ចំពោះការធ្វើសន្តតិកម្ម និង ចំនួន១០០,០០០,០០០ (មួយរយលាន)រៀលចំពោះការធ្វើប្រទានកម្ម។

ខ-ការធ្វើប្រទានកម្មអចលនទ្រព្យដែលចាប់ពីលើកទី២តទៅ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយ-តាបង្កើតនិងចៅបង្កើត ពីឪពុក-ម្តាយទៅឱ្យកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងពីយាយ-តាទៅឱ្យចៅបង្កើតនិងចៅប្រសារដែលជាសហព័ន្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ត្រូវបានអនុញ្ញាត ឱ្យដកចេញពីមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល។

**៣.ការផ្ទេរ និងការលើកលែងប្រាក់ពន្ធប្រថាប់ត្រា**ចំពោះចំណុច ខ និងចំណុច គ នៃកថាខណ្ឌ១ នៃប្រការនេះមិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួច និងការផ្ទេរមុនការចេញប្រកាសនោះទេ។

**៤.ការលើកលែងឬការអនុគ្រោះពន្ធប្រថាប់ត្រា** ក្នុងរង្វង់ញាតិដូចមានកំណត់ក្នុងប្រការនេះត្រូវមានឯកសារ និងភ័ស្តុតាងបញ្ជាក់ទំនាក់ទំនងអំពីញាតិដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង ឬឯកសារដទៃទៀតអាចបញ្ជាក់អំពីទំនាក់ទំនងរវាងបុគ្គលដែលមានចែងនៅក្នុងចំណុច១នៃប្រការ៤ នៃប្រកាសនេះ។

**៥.ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ** ដែលត្រូវបានលើកលែងពន្ធ ឬ ការអនុគ្រោះពន្ធប្រថាប់ត្រាទោះបីជាមានប្រាក់ពន្ធស្មើ 0(សូន្យ)រៀល ក៏ត្រូវបំពេញបែបបទ និង នីតិវិធីនៅរដ្ឋបាលសារពើពន្ធជាធរមាន 0 ដូចមានកំណត់ក្នុងប្រការ៨ នៃប្រកាសនេះ[18]ដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យនូវរាល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់ កាប់អចលនទ្រព្យទាំងនោះ។

- **អត្រាពន្ធ**

អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រា មានដូចខាងក្រោម៖

-៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យជា សំណង់ ឬ/ និងដី

[18] ប្រកាស ស្តីពីការប្រមូលពន្ធប្រថាប់ត្រាលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ មេសា ២០១៧

ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។

-៤%នៃតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ។

-0,១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

-0,១%នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

-១ 000 000(មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ប្រភេទគឺ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន និងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារួមទាំងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ។

- **មូលដ្ឋានគិតពន្ធ**

តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ ដូចខាងក្រោម៖

១-អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកំណត់តម្លៃអចលនទ្រព្យនិងតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្ត សម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២-ភាគហ៊ុនត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុននោះកើតឡើង។

៣-កិច្ចសន្យាត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា។

៤-លិខិតមានលក្ខណៈគតិយុត្តត្រូវកំណត់១ 000 000(មួយលាន)រៀលចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

## ១១.ពន្ធលើអចលនទ្រព្យ

- **និយមន័យ**

ពន្ធលើអចលនទ្រព្យ គឺជាប្រភេទពន្ធប្រចាំឆ្នាំ ដែលប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី ១00លានរៀលនិងមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និង រដ្ឋបាលក្រុងនៃខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ការប្រមូលពន្ធលើអចលនទ្រព្យនេះគឺសម្រាប់ជាផលប្រយោជន៍ថវិការដ្ឋបាល ថ្នាក់ក្រោមជាតិ។

- **កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ**

ពន្ធនេះជាប្រភេទពន្ធស្វ័យប្រកាស ដែលតម្រូវឱ្យកម្មសិទ្ធិករឬអ្នកកាន់កាប់ ឬអ្នកទទួលផលប្រយោជន៍ចុងក្រោយត្រូវមកចុះបញ្ជីអចលនទ្រព្យ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ និងដាក់លិខិតប្រកាសបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យស្ថិតនៅ។

- **អត្រាពន្ធ**

អត្រាពន្ធលើអចលនទ្រព្យត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១% លើមូលដ្ឋានគិតពន្ធ។ មូលដ្ឋានគិតពន្ធគឺ៨០%នៃតម្លៃអចលនទ្រព្យសរុប (ទាំងតម្លៃដី ឬ/និងតម្លៃសំណង់) តាមអាយុកាលសំណង់ និងប្រភេទសំណង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០ ០០០ ០០០ រៀលសម្រាប់អចលនទ្រព្យមួយ។

**១២.ពន្ធលើចំណេញមូលធន**

គោលបំណងនៃការដាក់អនុវត្តនៃពន្ធលើចំណេញមូលធនដែលសម្រេចបានដោយអ្នកជាប់ពន្ធស្របតាមមាត្រា៧(ថ្មី) មួយស្តីពីច្បាប់សារពើពន្ធ។

- **និយមន័យ**

ពន្ធលើចំណេញមូលធន ត្រូវអនុវត្តលើចំណេញមូលធនសម្រេចបានពីការលក់ឬផ្ទេរះ

- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសចំពោះរូបវន្តបុគ្គលនិវាសនជន
- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះរូបវន្តបុគ្គលនិងនីតិបុគ្គលអនិវាសនជន។

មូលធនរួមមានះ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញារូបិយវត្ថុបរទេស។

កាតព្វកិច្ចនិងបែបបទនៃការប្រកាសបង់ពន្ធអ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើចំណេញមូលធនតាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពពន្ធ ក្នុងអំឡុងពេលមិនលើសពី៣ខែបន្ទាប់ពីសម្រេចបានចំណេញមូលធន។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញត្រូវដាក់លិខិតប្រកាសនៅអគ្គនាយកដ្ឋានពន្ធដារ និង បង់ប្រាក់ពន្ធនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះទ្រព្យដែលស្ថិតនៅតាមបណ្តាខេត្តត្រូវដាក់លិខិតប្រកាសនៅសាខាពន្ធដារខេត្តដែលទ្រព្យនោះស្ថិតនៅ ឬ នៅអគ្គនាយកដ្ឋានពន្ធដារតាមការស្នើសុំរបស់អ្នកជាប់ពន្ធ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- **អត្រាពន្ធមូលដ្ឋានគិតពន្ធនិងការគណនាប្រាក់ពន្ធ**

ពន្ធលើចំណេញមូលធនត្រូវបានកំណត់តាមអត្រាថេរ២០%នៃចំណេញមូលធន។ មូលដ្ឋានគិតពន្ធ គឺជាចំណេញមូលធនដែលសំដៅដល់ប្រាក់ចំណូលជាប់ពន្ធដែលបានពីការចំណូលពីការលក់ ឬ ផ្ទេរមូលធន ដក

ការកាត់កងចំណាយដែលអនុញ្ញាត។ អ្នកជាប់ពន្ធអាចអាចជ្រើសរើសវិធីសាស្ត្រកាត់កងចំណាយដែលអនុញ្ញាតដូចខាងក្រោមដើម្បីគណនាចំណេញមូលធន។

ការគណនាចំណេញមូលធន៖

១.តាមចំណាយជាក់ស្តែងចំពោះមូលធនទាំងអស់

ចំណេញមូលធន = ថ្លៃលក់ឬផ្ទេរនៃទ្រព្យ - ថ្លៃដើមនៃទ្រព្យ

ថ្លៃលក់ឬផ្ទេរនៃទ្រព្យ៖ តម្លៃកំណត់ក្នុងកិច្ចសន្យានិងឯកសារពាក់ព័ន្ធ

ថ្លៃដើមនៃទ្រព្យ៖ ថ្លៃដើមពេលទិញទ្រព្យ រួមទាំងចំណាយពាក់ព័ន្ធផ្សេងៗដែលអនុញ្ញាតឱ្យកាត់កង

២.តាមការកំណត់ចំពោះមូលធនជាអចលនទ្រព្យអ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីកាត់កងចំណាយតាមការកំណត់(៨០%នៃប្រាក់ចំណូលពីការលក់ឬផ្ទេរ) ឬវិធីកាត់កងតាមចំណាយជាក់ស្តែង។

ចំណេញមូលធន = ថ្លៃលក់ឬផ្ទេរនៃទ្រព្យ - (៨០%xថ្លៃលក់ឬផ្ទេរនៃទ្រព្យ)

ការគណនាពន្ធលើចំណេញមូលធន

ប្រាក់ពន្ធលើចំណេញមូលធនត្រូវបង់ = ចំណេញមូលធន x ២០%

- **ការលើកលែងពន្ធ និងការអនុគ្រោះពន្ធ**

ពន្ធលើចំណេញមូលធនត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរ៖

១.ដីកសិកម្ម ជាកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋដែលជាកសិករកំពុងបង្កបង្កើនផលពិតប្រាកដនិងមានអាសយដ្ឋានរស់នៅ ស្ថិតនៅក្នុងឃុំ/សង្កាត់ដែលដីកសិកម្មនោះស្ថិតនៅ។

២.ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ។

៣.និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធដែលបានកាន់កាប់យ៉ាងតិចរយៈពេលប្រាំ(០៥)ឆ្នាំមុនពេលលក់ឬផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធ និងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នាមាននិវាសនដ្ឋានតែមួយប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតជានិវាសដ្ឋានជាគោលដើមអចលនទ្រព្យក្នុងរង្វង់ញាតិដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត រវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ និងរវាងយាយ-តាក្មេកនិងចៅប្រសារទ្រព្យដែលត្រូវបានលក់ឬផ្ទេរដើម្បីបម្រើប្រយោជន៍សាធារណៈស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

## ១៣.អាករលើតម្លៃបន្ថែម

- **និយមន័យ**

អាករលើតម្លៃបន្ថែម(អតប) ជាប្រភេទពន្ធលើការប្រើប្រាស់ ដែលយកលើទំនិញ និងសេវា។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន។

"ទំនិញ" សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លីនិងប្រាក់កាស រីឯសេវា សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

- ការផ្គត់ផ្គង់"ជាប់អាករសំដៅដល់៖

- ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា

- ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ៖

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននិងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលនិងការទិញទំនិញសម្រាប់ឬដោយបេសកកម្មទូតនិងកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទីភ្នាក់ងារ សហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន។

- អត្រាអាករលើតម្លៃបន្ថែមមាន៖

- ១០% សម្រាប់ការនាំចូលឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- 0% សម្រាប់ការនាំចេញ
- ♦ ការគណនាប្រាក់អាករត្រូវបង់៖
- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញទំនិញ ឬសេវាសម្រាប់ ប្រកបអាជីវកម្ម ហៅថា "អាករលើធាតុចូល"
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញ ឬសេវាហៅថា "អាករលើធាតុចេញ"

ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល

- ♦ អាករលើធាតុចូលដែលមិនអាចកាត់កងបាន៖
- អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើៈចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ។
- ការទិញឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត
- ការទិញឬការនាំចូលផលិតផលតេលសិលា (ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែ ប្រេងម៉ាស៊ុត និងប្រេងរំអិល) មួយចំនួនលើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ ផលិតផលតេលសិលាទាំងនោះ។

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញ ឬ សេវាត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារ ពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

**១៤.អាករពិសេសលើទំនិញ និងសេវា**

អាករពិសេសប្រមូលទៅលើទំនិញ និងសេវាមួយចំនួនដូចខាងក្រោម៖

- ជាទំនិញដែលធ្វើអោយប៉ះពាល់ដល់សុខភាពដែលរដ្ឋាភិបាលមិនលើកទឹកចិត្តក្នុងការប្រើប្រាស់ និងទំនិញដែលជាប់អាករពិសេសនេះរួមមាន៖ ស្រាគ្រប់ប្រភេទ(៣៥%) ស្រាបៀរ(៣០%) និងបារី(២០%)។
- ចំពោះសេវាដែលជាប់អាករនេះមានសេវាលម្ហែកម្សាន្ត និងសេវាដឹកអ្នកដំណើរតាមផ្លូវអាកាស(១០%) និងសេវាទូរស័ព្ទ(៣%)។

អ្នកជាប់ពន្ធដែលផលិតទំនិញ ឬផ្គត់ផ្គង់សេវាទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

**១៥.អាករសម្រាប់បំភ្លឺសាធារណៈ**

អាករសម្រាប់បំភ្លឺសាធារណៈ មានគោលបំណងជាប្រយោជន៍នៃថវិការរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន កំណត់តាមអត្រា ៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាមេរ័យ និងបារី។

**១៦.អាករលើការស្នាក់នៅ**

អាករលើការស្នាក់ត្រូវបានកំណត់តាមអត្រា ២% ដែលអនុវត្តលើការស្នាក់នៅរបស់ភ្ញៀវក្នុងសណ្ឋាគារ សណ្ឋាគារ វីសត បឹងកាឡូ ផ្ទះសំណាក់ឬផ្ទះភ្ញៀវ កន្លែងបោះជំរុំទេសចរណ៍ និងកន្លែងផ្តល់សេវាស្នាក់នៅដទៃទៀត ប៉ុន្តែមិនរួមបញ្ចូលផ្ទះជួល ឬ ផ្ទះល្វែងជួលក្នុងរយៈពេលខ្លី ឬ វែង ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៣ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

### ក.កាតព្វកិច្ចអ្នកជាប់ពន្ធ

អ្នកជាប់ពន្ធមានកាតព្វកិច្ចៈ

- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធនិង[19] ដាក់លិខិតប្រកាសសារពើពន្ធដោយផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ តាមមាត្រា ៩៨ និងមាត្រា ១០៤ នៃចសព។
- បង់ពន្ធតាមកាលបរិច្ឆេទកំណត់ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ[20] ការរៀបចំ និងការដាក់លិខិតប្រកាសសារពើពន្ធ(មាត្រា ១០៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ "ចវចសព") អ្នកជាប់ពន្ធជាភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាល សារពើពន្ធទៅតាមទម្រង់ ពេលវេលា និង ទីកន្លែងដែលបានកំណត់ ។ លិខិតប្រកាសសារពើពន្ធត្រូវចុះហត្ថលេខា ដោយអ្នកជាប់ពន្ធ តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។
- អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិត ប្រកាសសារពើពន្ធប្រចាំខែសម្រាប់ ខែនីមួយៗ និង លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និង បង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ។
- អ្នកវិនិយោគទាំងអស់ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិត ប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ ។
- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានកាតព្វកិច្ចរៀបចំបញ្ជីកាគណនេយ្យ (បិទបញ្ជីគណនេយ្យរបស់ខ្លួន និង រៀបចំ និង ដាក់លិខិតប្រកាសសារពើពន្ធតាមគំរូ ទម្រង់លិខិតប្រកាសសារពើពន្ធ ។

[19] មាត្រា១០១នៃចសព

[20] មាត្រា១០៧ នៃចសព

- រដ្ឋបាលសារពើពន្ធមានសិទ្ធិធ្វើការកំណត់ពន្ធជាឯកតោភាគីចំពោះសហគ្រាសណាដែលមិនបាន រៀបចំ និង ដាក់លិខិតប្រកាសពន្ធ មិនបានកាន់កាប់ និង រក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីការគណនេយ្យ ឬឯកសារ
- កាតព្វកិច្ចចម្បងរបស់អ្នកជាប់ពន្ធ កាន់កាប់ ថែរក្សា និងត្រូវបង្ហាញបញ្ជីលិខិតបញ្ជីយុត្តិការ និងឯកសារផ្សេងៗ។
- អ្នកជាប់ពន្ធត្រូវមានវត្តមានបង្ហាញខ្លួនចំពោះមុខរដ្ឋបាលសារពើពន្ធ តាមកាលបរិច្ឆេទដែលបានចុះក្នុង លិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

ក្នុងករណីពិសេសអ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ប្រាក់បន្ថែម និងពិន័យការប្រាក់ផ្សេងៗដែលរដ្ឋ បាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ការទទួលខុសត្រូវរបស់អភិបាលៈ បណ្ណាធិការ កម្មសិទ្ធិករ (មាត្រា ១០៨ នៃចសព) ប្រសិនបើ អភិបាល ឬ បណ្ណាធិការ ឬ កម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬ មានចេតនាធ្វើឱ្យសហគ្រាស មិនរាយការណ៍ ឬ រាយការណ៍បន្ថយនូវប្រាក់ពន្ធដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យ បង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬ បណ្ណាធិការ ឬ កម្មសិទ្ធិករទាំងនោះត្រូវទទួលខុស ត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

ការបង់ពន្ធត្រូវបានកំណត់ដូចតទៅៈ ១. ប្រាក់ពន្ធត្រូវដល់កំណត់ និង ត្រូវបង់នៅ ក្នុងរយៈ ពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារ បានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាស សារពើពន្ធៈ

**ក - អាករលើតម្លៃបន្ថែម អតប ៖** យ៉ាងយឺតបំផុតនៅថ្ងៃទី២០ នៃខែ បន្ទាប់ (មាត្រា ៧០ ចសព) ។

**ខ - ពន្ធលើប្រាក់ចំណេញ** (មាត្រា ៥ និង ២៩ នៃចសព និង ប្រកាស លេខ ១៤៨១ សហវ.ប្រក.ពដ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពត ។ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៧)

+ ចំពោះសហគ្រាសអនុវត្តឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិនយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ខែឆ្នាំបន្ទាប់ ។
+ ចំពោះសហគ្រាសដែលស្នើសុំប្តូរ ឆ្នាំជាប់ពន្ធថ្មី ក្នុងរយៈពេល ៣ខែ បន្ទាប់ ពីដំណាច់ការិយបរិច្ឆេទ អន្តរកាលក្នុងរយៈពេល ៣ខែ ក្រោយដំណាច់ឆ្នាំជាប់ពន្ធថ្មី

**គ- ពន្ធអាករដទៃទៀត** ដូចជាពន្ធកាត់ទុកទូទៅ ពន្ធលើប្រាក់បៀវត្ស អាករបំភ្លឺសាធារណៈ អាករពិសេស អាករស្នាក់នៅ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃ ខែបន្ទាប់ ពន្ធអាករក្រៅពីនេះ ត្រូវដល់កំណត់ និង ត្រូវ បង់នៅក្នុងរយៈពេលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។ បំណុលសារពើពន្ធត្រូវដល់កំណត់ និងត្រូវបង់ ក្នុងរយៈពេល៣០ថ្ងៃក្រោយពី ការប្រគល់លិខិតជូនដំណឹងទារបំណុល និងប្រាក់ពន្ធត្រូវដល់កំណត់ និង ត្រូវបង់ក្នុងរយៈពេល ៣ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដូចមាន ចែងក្នុងកថា

ខណ្ឌ៤ មាត្រា១១៦នៃចសព បើសិនជាមានមូលដ្ឋានបញ្ជាក់ថាការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធនៅពេលណាមួយក៏បាន ។[21]

**ខ.សិទ្ធិអ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធមានសិទ្ធិទទួលបានៈ

- ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្ដល់ជូនរដ្ឋបាលសារពើពន្ធ។ (មាត្រា ៩៩ នៃចសព រដ្ឋបាលសារពើពន្ធទទួលព័ត៌មានពីអ្នកជាប់ពន្ធ ឬពីតតីយជនត្រូវរក្សាការ សម្ងាត់ ហើយអាចផ្ដល់ព័ត៌មានទៅឱ្យតែបុគ្គលដែលមាត្រា ៩៤ នៃចសព បានអនុញ្ញាតប៉ុណ្ណោះ ដូចជាៈ
  - មន្ត្រី និងភ្នាក់ងាររបស់រដ្ឋបាលសារពើពន្ធក្នុងពេលបំពេញភារកិច្ច
  - អាជ្ញាធរព្រហ្មទណ្ឌគោលដៅបទល្មើសពន្ធដារ
  - តុលាការក្នុងដំណាក់កាលជំរះក្ដីអំពីពន្ធដារ
  - អាជ្ញាធរពន្ធដាររបស់ប្រទេសណាមួយទៀតស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ
  - មានការយល់ព្រមពីអ្នកជាប់ពន្ធជាលាយលក្ខណ៍អក្សរ
  - ករណីមានការបំពារបំពានត្រូវដោះស្រាយជាមួយមន្ត្រីពាក់ព័ន្ធផ្ទាល់ ឬ ប្រធានអង្គភាពនៃរដ្ឋបាលសារពើពន្ធគ្រប់កម្រិត។
- ទទួលបានការផ្ដល់សេវាប្រកបដោយវិជ្ជាជីវៈដោយមានការជួយពន្យល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធិសារពើពន្ធ។[22]
  - អ្នកជាប់ពន្ធមានសិទ្ធិទទួលបាន ៖ ការពន្យល់ណែនាំ ការទំនាក់ទំនង ទាមទារឱ្យបង្ហាញលិខិតបេសកកម្ម ឬលិខិតឧទ្ទេសនាម ការឆ្លើយតបសំណួរនិងសំណូមពរដោយមន្ត្រីពន្ធអំពីកិច្ចការពន្ធដារ។
  - អ្នកជាប់ពន្ធអាចស្វែងរកការណែនាំ និងព័ត៌មាន ៖ បើកមើលគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ធ្វើលិខិតសុំយោបល់ផ្ទាល់មាត់តាមទូរស័ព្ទ
  - ការផ្ដល់ព័ត៌មានដល់អ្នកជាប់ពន្ធៈ លិខិតស្នាម ឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្ដល់ទៅឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធលុះតែធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវប្រគល់ឱ្យដល់អ្នកជាប់ពន្ធ (ឱ្យដល់បុគ្គលផ្ទាល់ ឬ

[21] សៀវភៅនៃនាំកាតព្វកិច្ច និងសិទ្ធិអ្នកជាប់ពន្ធបោះពុម្ពថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១០ដោយអគ្គនាយកដ្ឋានពន្ធដារ

[22] មាត្រា៩៦ នៃច្បាប់ស្ដីពីសារពើពន្ធ និងវិសោធនកម្ម

តាមរយៈប្រៃសនីយ៍ ឬបិទភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬកន្លែងប្រកបអាជីវកម្ម ឬផ្សព្វផ្សាយ តាមសារព័ត៌មាន)។

- ទទួលបានព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ ហើយនិងនីតិវិធីនៃការកំណត់ពន្ធ

ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ។ ជាទូទៅ រដ្ឋបាលសារពើពន្ធពន្យល់ពីសេចក្តីសម្រេចរបស់ខ្លួនឱ្យបាន ច្បាស់លាស់ និងជាលាយលក្ខណ៍អក្សរ ករណីអ្នកជាប់ពន្ធមានសំណួរ ឬមិនយល់ ឬមិនឯកភាព ត្រូវទាក់ទងមន្រ្តីទទួលបន្ទុកកិច្ចការនោះ។ ការជំទាស់នឹងសេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធៈ ត្រូវសរសេរ ជាលាយលក្ខណ៍អក្សរ ព័ណ៌នាលម្អិតហេតុផល ដាក់ឱ្យបានទាន់ពេលកំណត់ មានឯកសារ និងអះអាងត្រឹមត្រូវ ចុះហត្ថលេខា ត្រា កាលបរិច្ឆេទ។

- ទទួលព័ត៌មានពីសិទ្ធិរបស់ខ្លួនរួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា និង បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់។ ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ មាត្រា១១៨ និង១២០ នៃចសព អ្នកជាប់ពន្ធមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ជំទាស់នឹងសេចក្តីសម្រេចផ្សេងៗ ឬអំពើខុសឆ្គងណាមួយរបស់រដ្ឋបាលសារពើពន្ធ។ ដំបូងដោះស្រាយជាមួយមន្រ្តីពាក់ព័ន្ធផ្ទាល់ ឬប្រធាន អង្គភាពនៃរដ្ឋបាលសារពើពន្ធគ្រប់កម្រិត (សាខាពន្ធដារខេត្ត-ខណ្ឌ និង អពដ) គណៈកម្មធិការសម្រុះសម្រួលសារពើពន្ធ និងតុលាការ។
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
  មាត្រា១០៧ នៃចសព ៖ (ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវ)
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ តាមការជ្រើសរើស ដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ។ មាត្រា១០៦ នៃចសព អាចរកអ្នកតំណាង ៖ (មិនមែនមន្រ្តីពន្ធដារ ផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ កំណត់ព្រំដែន សិទ្ធិអំណាច អ្នកជាប់ពន្ធត្រូវទទួលខុសត្រូវផ្ទាល់រាល់សកម្មភាពអ្នកតំណាង)។ កិច្ចការដែលអ្នកតំណាងអាចធ្វើ៖ (ដាក់លិខិតប្រកាសសារពើពន្ធរៀបចំបញ្ជីគណនេយ្យ ទំនាក់ទំនងឆ្លើយចំពោះការស្នើសុំព័ត៌មានពីរដ្ឋបាលសារពើពន្ធ បង្ហាញរបាយការណ៍ បង់ពន្ធអាករ ធ្វើបណ្តឹងតវ៉ា បណ្តឹងឧទ្ធរណ៍ តំណាងនៅតុលាការ បំពេញរាល់កាតព្វកិច្ចពន្ធ)។

## ២.៤ បទល្មើសពន្ធដារ និងទោសទណ្ឌ

### ក.បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

ចាត់ទុកថាជាបទល្មើសពន្ធដារនៅពេលណាដែលអ្នកជាប់ពន្ធបានប្រព្រឹត្តនៅ ការធ្វេសប្រហែស ធ្វេសប្រហេសធ្ងន់ធ្ងរ ការគេចវេះពន្ធ និងប្រព្រឹត្តអំពើរាំងស្ទះជាដើម។

- **ការធ្វេសប្រហែស៖ (មាត្រា ១២៥ ចសព)**

- ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលត្រូវបង់ មិនលើសពី១០%
- ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាមិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់។
- ប្រាក់ពន្ធបានបង់ < ប្រាក់ពន្ធត្រូវបង់ => មិនលើសពី ១០%
- មិនបានដាក់លិខិតប្រកាសពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់

- **ការធ្វេសប្រហែសធ្ងន់ធ្ងរ៖ (មាត្រា ១២៦ សចព)**

- ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលត្រូវបង់លើសពី១០%
- ប្រាក់ពន្ធបានបង់ < ប្រាក់ពន្ធត្រូវបង់ => លើសពី ១០ %

- **ការគេចវេសពន្ធ៖ (មាត្រា ១២៧)**

- ការគេចវេសពន្ធ គឺជាបទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារក្នុងបំណងបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឲ្យបង់។ ត្រូវបានចាត់ទុកថាជាការគេចវេះផងដែរក្នុងករណីដែលការធ្វេសប្រហែស ធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់នេះបានប្រព្រឹត្តឡើង ៖

  ១-ពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣ឆ្នាំ នៃឆ្នាំប្រតិទិន

  ២-បីលើកឬច្រើនជាងនេះដាច់ពីគ្នា ក្នុងរយៈពេលណាមួយក៏ដោយ

- **អំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា១២៨ ចសព)**

- **ករណីដែលបុគ្គល**

  ក- មិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀតឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ។

  ខ- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ

  គ-មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ

  ឃ-មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរការចុះបញ្ជី។

  ង-កសាង ឬផ្តល់នូវកំណត់ត្រាឯកសាររបាយការណ៍ឬព័ត៌មានក្លែងបន្លំផ្សេងៗ

  ច-លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យកំណត់ត្រាឯកសាររបាយការណ៍ ឬព័ត៌មានផ្សេងៗទៀត។

ឆ-ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ និងការប្រមូលពន្ធ។

ជ-មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់

ឈ- ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ។

- **ករណីដែលមន្ត្រីរាជការ**

ក- ធ្វើឱ្យធ្លាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត។

ខ- ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ និងការប្រមូលពន្ធ។

គ- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ។

➢ **អំពីបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា១២៩ ចសព)**

ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា១២៧(ចសព)ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨(ចសព) ត្រូវចាត់ទុកថាបានប្រព្រឹត្តិបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

**ខ.ទោសទណ្ឌ**

➢ **ពន្ធបន្ថែម**

ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើស បទប្បញ្ញត្តិស្តីពីពន្ធដារ ។ ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះ ឬការបង់យឺតត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែមសម្រាប់ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។ នៅក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែម និង ការប្រាក់ត្រូវដល់កំណត់ និង ត្រូវបង់តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ។ ទោះជាក្នុងករណីណាក៏ដោយការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ។[23]

➢ **ពន្ធបន្ថែមចំពោះការបង់ខ្វះ**

- **ករណីធ្វេសប្រហែស**

- ពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះចំពោះបុគ្គលដែលមានការធ្វេសប្រហែសប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់១,៥% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។

- **ករណីធ្វេសប្រហែសធ្ងន់ធ្ងរ**

[23] មាត្រា ១៣០ នៃចសព

- ចំពោះបុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង២៥% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ១,៥ % នៃចំនួន ប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

    - **ករណីឯកតោភាគី**

- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤0% តែចំនួនប្រាក់ពន្ធដែលបង់ខ្វះបូកបន្ថែមការប្រាក់ ១,៥ % នៃចំនួនប្រាក់ពន្ធដែល បង់ខ្វះ សម្រាប់ខែនីមួយៗ ឬចំណែកខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។ការប្រាក់មិនត្រូវអនុវត្តទេក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា១១៨ ច្បាប់ស្តីពីសារពើពន្ធក្នុងរយៈពេល ៣0ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។[24]

➢ **ពន្ធបន្ថែមចំពោះអំពើរាំងស្ទះ**

ពន្ធបន្ថែមចំពោះអំពើរាំងស្ទះ**(មាត្រា១៣៣ចសព)**ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារគឺត្រូវពិន័យ **២,000,000 រៀល**(២លានរៀល) ។ទោះជាក្នុងករណីណាក៏ដោយការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

- ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលពន្ធប្រចាំឆ្នាំ ។
- ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវស្មើនិង ១00% នៃប្រាក់ពន្ធត្រូវបង់ ។

➢ **អំណាចក្នុងការប្តឹងចោទប្រកាន់ខាងព្រហ្មទណ្ឌ** (មាត្រា១៣៤ ចសព)

ការប្តឹងចោទប្រកាន់ និងទាមទារដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយអគ្គនាយក អគ្គនាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- **ការគេចវេះពន្ធ (មាត្រា១៣៥ ចសព)**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បណ្ណាធិការអភិបាល កម្មសិទ្ធិករ ឬអ្នកទទួលខុសត្រូវសហគ្រាស ប្រព្រឹត្តិអំពើគេចវេះពន្ធ ដូចមាត្រា១២៧ ចសព ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី១០លានរៀល ដល់ ២០លានរៀល ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរនេះ។

[24] មាត្រា ១៣១ នៃចសព

- **អំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា១៣៦ ចសព)**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តិអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញស្តីពីពន្ធដារដូចមាត្រា១២៨ចសពត្រូវរងការផ្តន្ទាទោសពិន័យជាទឹកប្រាក់ពី ៥លានរៀល ដល់ ១០លានរៀលឬជាប់ពន្ធនាគារពី១ខែដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។

- **អំពើជ្រោមជ្រែង និងអូសទាញ (មាត្រា១៣៧ ចសព)**

បុគ្គលណាដែលមានចេតនាជ្រោមជ្រែង ឬអូសទាញបុគ្គលម្នាក់ទៀតឲ្យប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌចំពោះច្បាប់នេះ ឬក៏ដោយចេតនាបានផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតឲ្យប្រព្រឹត្តិល្មើសបែបនេះត្រូវជាប់ពិរុទ្ធ ហើយត្រូវទទួលរងនូវការផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តិបទល្មើសផ្ទាល់ខ្លួនដែរ។

- **ការធ្វើឱ្យធ្លាយការសម្ងាត់ (មាត្រា១៣៨ ចសព)**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានបំពានមាត្រា៩៤ នៃច្បាប់នេះ ត្រូវជាប់ពិរុទ្ធជំពីបទល្មើសនឹងច្បាប់ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាទឹកប្រាក់ពី៥លានរៀល ដល់១០លានរៀល ឬ ជាប់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ ឬទោសទាំងពីរនេះ។

- **សំណងចំពោះការប្រព្រឹត្តិការខុសឆ្គង (មាត្រា១៤០ ចសព)**

បើសិនអ្នកជាប់ពន្ធយល់ឃើញថា ខ្លួនបានទទួលរងនូវការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួន អំពីសកម្មភាពខុសឆ្គងឬខុសច្បាប់ពីសំណាក់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចប្តឹងទាមទារសំណងនៃការខូចខាត ឬការរងគ្រោះនោះ ទៅតុលាការក្នុងរយៈពេលបីឆ្នាំ ក្រោយកាលបរិច្ឆេទនៃការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនចុងក្រោយបំផុត។

# ជំពូកទី២

# ការធ្វើទំនើបភាវូបនីយកម្ម

# រដ្ឋបាលសារពើពន្ធ

# ជំពូកទី២
# ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា អគ្គនាយកដ្ឋានពន្ធដារបានផ្តោតជាចម្បងលើការកែទម្រង់រដ្ឋបាលសារពើពន្ធតាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អ ដោយបានពង្រឹងនិងកែលម្អលើមុខងារស្នូល និងមុខងារគាំទ្រ ព្រមទាំងការកែទម្រង់គោលនយោបាយសារពើពន្ធ សំដៅបង្កើនប្រសិទ្ធភាពស័ក្តិសិទ្ធិភាពក្នុងការប្រមូលចំណូលពន្ធ និងបំពេញភារកិច្ច និងបេសកកម្មប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌។ ជាលទ្ធផល ក្នុងរយៈពេល៥ឆ្នាំជាប់ៗគ្នាចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធ-អាករសម្រេចបានលើសផែនការដែលបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងរៀងរាល់ឆ្នាំ រហូតដល់មានឆ្នាំខ្លះទទួលបានសន្ទស្សន៍កំណើន២ខ្ទង់។ សមិទ្ធផលទាំងនេះកើតចេញពីការចូលរួមយ៉ាងសកម្មរបស់មន្ត្រីពន្ធដារទាំងអស់ក្រោមការគាំទ្រយ៉ាងពេញទំហឹង និង ការណែនាំចង្អុលបង្ហាញពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ក្នុងការតម្រង់ទិសដៅលើកិច្ចការប្រមូលចំណូលពន្ធ។

អគ្គនាយកដ្ឋានពន្ធដារផ្តោតសំខាន់លើពីរផ្នែកគឺកំណែទម្រង់រដ្ឋបាលសារពើរពន្ធនិងកំណែទម្រង់គោលនយោបាយរដ្ឋបាលសារពើពន្ធ ហើយបានដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៩-២០២៣ ក្នុងគោលបំណងបីយ៉ាងគឺ៖

១) បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធដោយផ្តល់សេវាប្រកបដោយគុណភាព។

២) បន្តពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាពដើម្បីជំរុញអ្នកជាប់ អោយបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ។

៣) អនុវត្តការងារអោយមានប្រសិទ្ធភាពខ្ពស់ដោយពង្រឹងស្ថាប័ន។

## ផ្នែកទី១៖ កំណែទម្រង់រដ្ឋបាលសារពើពន្ធ

ដោយអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់រដ្ឋបាលសារពើពន្ធ ដោយពង្រឹងដល់ការអនុវត្តការគ្រប់គ្រងដល់ការប្រមូលពន្ធតាមរយៈការពង្រឹងមុខងារប្រតិបត្តិស្នូល និង មុខងារប្រត្តិបត្តិការគាំទ្រតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធរួមមាន ការបង់ពន្ធ ការធ្វើសវនកម្ម និងការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការដោះស្រាយវិវាទពន្ធដារជាដើម។

❖ អគ្គនាយកដ្ឋានពន្ធដារគ្រប់គ្រងការប្រមូលចំណូលពន្ធតាមមុខងារប្រតិបត្តិការស្នូល និងគាំទ្រ តាមចំណាត់ថ្នាក់អ្នកជាប់ពន្ធ។




## ១.១.ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច

ការធ្វើទំនើបភាវូបនីយកម្មក្របខ័ណ្ឌស្ថាប័ន និង អភិបាលកិច្ចនឹងធានាសម្រេចឱ្យបានពីរផ្នែកគឺៈ (១)ក្របខ័ណ្ឌស្ថាប័នដែលមានសមត្ថភាពសម្របខ្លួនទៅតាមរបត់នៃសេដ្ឋកិច្ច-សង្គម(learning organization) ដោយមានការបែងចែកការទទួលខុសត្រូវនិងសិទ្ធិអំណាចច្បាស់លាស់រវាងស្នាក់ការកណ្តាលនិងថ្នាក់មូលដ្ឋាន។ ដោយស្នាក់ការកណ្តាល ផ្តោតលើការគ្រប់គ្រងហានិភ័យចម្បងៗលើចំណូល និងត្រួតពិនិត្យវាយតម្លៃសមិទ្ធកម្មការងារ (output and outcome)។ រីឯអង្គភាពអនុវត្តថ្នាក់មូលដ្ឋាន (សាខាខេត្ត-ខណ្ឌ) ផ្តោតលើការងារប្រតិបត្តិការប្រចាំថ្ងៃដើម្បីធានាថារដ្ឋបាលសារពើពន្ធអាចឆ្លើយតប និង សម្របខ្លួនទាន់ពេលវេលាទៅនឹងរបត់សេដ្ឋកិច្ច-សង្គម និង

(២) យន្តការប្រតិតុល្យការ (check and balance) ក្របខ័ណ្ឌអភិបាលកិច្ចដែល សវនកម្មផ្ទៃក្នុងមានឯករាជ្យភាពខ្ពស់ក្នុងការធានាសុចរិតភាព វិជ្ជាជីវៈ និងទំនុកចិត្តនៃរដ្ឋបាលសារពើពន្ធ ។ [25]ក្នុងរយៈពេល៥ឆ្នាំកន្លងមក អគ្គនាយកដ្ឋានពន្ធដារបានបញ្ចប់ និង ដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រពង្រឹងសមត្ថភាពគ្រប់គ្រង ហានិភ័យ លើកកម្ពស់សេវាអ្នកជាប់ពន្ធ និងបង្កើនកម្រិតអនុលោមភាព ។ ដោយឡែក ដើម្បីសម្រេចបាននូវគោលបំណង

[25] បទបង្ហាញរបស់អគ្គនាយកដ្ឋានពន្ធដារសេចក្តីផ្តើមនៃការប្រមូលពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា

នៃការកែទម្រង់ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តដោះស្រាយបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងកម្មវិធីកែទម្រង់ភាគច្រើនផ្តោតលើសកម្មភាព និងលទ្ធផល (output) ដោយមិនបានផ្តោត គ្រប់ជ្រុងជ្រោយលើសមិទ្ធកម្ម (outcome)
- សិទ្ធិសម្រេច និងសមត្ថភាពក្នុងការគ្រប់គ្រងប្រតិបត្តិការថ្នាក់មូលដ្ឋាននៅមានកម្រិត ដែលធ្វើឱ្យភាពជាម្ចាស់ និងការទទួលខុសត្រូវលើប្រតិបត្តិការនៅមានភាពទន់ខ្សោយ
- ការគ្រប់គ្រងហានិភ័យទៅលើប្រភពចំណូលនៅមានកម្រិតនៅឡើយដោយពុំទាន់អាចឆ្លើយតបទៅតាមបេត់សេដ្ឋកិច្ចពាណិជ្ជកម្ម និងបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។
- ការប្រមូល និងការចែករំលែកព័ត៌មានទិន្នន័យផ្ទៃក្នុងអង្គភាព និងរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានភាពយឺតយ៉ាវមិនទាន់សភាពការណ៍ដែលប៉ះពាល់ដល់ប្រសិទ្ធភាពការងារប្រចាំថ្ងៃ
- សវនកម្មផ្ទៃក្នុងមិនទាន់បានបំពេញមុខងារពេញលេញដើម្បីធានាគុណភាពអភិបាលកិច្ចផ្ទៃក្នុង។

❖ ដកស្រង់ចេញពីសៀវភៅអភិបាលកិច្ចល្អរបស់ក្រសួងមហាផ្ទៃ។



## ១.២ មុខងារប្រតិបត្តិការស្នូល

ជាប្រភេទមុខងារដែលទាក់ទងទៅនឹងការគ្រប់គ្រង និងប្រតិបត្តិការប្រមូលពន្ធដោយផ្ទាល់លើរូបវន្ត បុគ្គល និងនីតិបុគ្គល ដែលច្បាប់សារពើពន្ធបានកំណត់ថាត្រូវជាប់កាតព្វកិច្ចបង់ពន្ធ។[26]

តាមរយៈការធ្វើទំនើបភាវូបនីយកម្មមុខងារប្រតិបត្តិការស្នូល ប្រទេសកម្ពុជានឹងធ្វើការរៀបចំឡើងវិញ ដោយផ្អែកតាមឧត្តមានុវត្តន៍អន្តរជាតិត្រូវមានលក្ខណៈពិសេសបីគឺ៖

(១)ការធ្វើអោយកាន់តែប្រសើរឡើងនូវដំណើរការការងារ និង ការគ្រប់គ្រងកាត់ផ្លាស់ប្តូរស្ថាប័នមុននឹង ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

(២)ការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែល ស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាលើមុខងារប្រតិបត្តិទាំងអស់។ និង

(៣)ការផ្លាស់ប្តូរទៅជារដ្ឋបាលសារពើពន្ធដែលផ្តោតទៅលើអ្នកជាប់ពន្ធ(costumer-oriented administration)តាមរយៈការពង្រឹងគុណភាពសេវា។[27]

ដោយការធ្វើទំនើបភាវូបនីយកម្មនេះមានមុខងារ៥គឺ៖

១-ការចុះបញ្ជីអ្នកជាប់ពន្ធ ៖ ការកែសម្រួល និងធ្វើទំនើបកម្មការងារចុះបញ្ជីពន្ធដារ

២-ការផ្តល់សេវាអ្នកជាប់ពន្ធ ៖ ការផ្តល់សេវាកាន់តែមានភាពល្អប្រសើ

៣-ការចាត់ចែងលិខិតប្រកាស ៖ ការកាត់បន្ថយបន្ទុករដ្ឋបាលក្នុងការដាក់លិខិតប្រកាសពន្ធ និង ការ បង់ប្រាក់ពន្ធ

៤-ការធ្វើសាវនកម្ម៖ការសម្រួលការងារសវនកម្មតាមរយៈការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មាននិងពង្រឹង មុខងារស៊ើបអង្កេតបទល្មើសពន្ធដារ

៥-ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា៖ ការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវយន្តការដោះស្រាយ បណ្តឹងតវ៉ាពន្ធដារ និង ជំរុញការប្រមូលបំណុលពន្ធ។ ព្រមទាំងផ្តោតជាចម្បងលើការពង្រឹងគុណភាពសេវាអ្នក ជាប់ពន្ធដារ ដើម្បីកាត់បន្ថយបន្ទុក លើកទឹកចិត្ត និងកសាងទំនុកចិត្តដល់អ្នកជាប់ពន្ធឱ្យអនុវត្តកាតព្វកិច្ចសារពើ ពន្ធដោយស្ម័គ្រចិត្ត។

[26] បទបង្ហាញរបស់សាលាជាតិពន្ធដារស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា២០២១

[27] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ១២)

ដាក់ស្តែងនៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារបានធ្វើឡើងក្នុងគោលបំណងទី(១)បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធដោយផ្តល់សេវាប្រកបដោយគុណភាព។ ដោយបានកំណត់នូវគោលដៅសំខាន់ៗដូចខាងក្រោម៖

➢ គោលដៅទី១ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធតាមរយៈការរៀបចំនូវប្រព័ន្ធដំណើរការរដ្ឋបាលសារពើពន្ធប្រកបដោយស័ក្តិសិទ្ធិភាព និងសាមញ្ញភាព ព្រមទាំងបានដាក់ចេញនូវយុទ្ធសាស្ត្រ៦ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ កែលម្អដំណើរការចុះបញ្ជីអ្នកជាប់ពន្ធឱ្យមានភាពងាយស្រួល និងសាមញ្ញជាងមុន។
- យុទ្ធសាស្ត្រ២ កែលម្អដំណើរការនៃការដាក់លិខិតប្រកាសពន្ធ និងការបង់ប្រាក់ពន្ធដើម្បីកាត់បន្ថយចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ។
- យុទ្ធសាស្ត្រទី៣ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការធ្វើ សវនកម្ម និងស៊ើបអង្កេតបទល្មើសពន្ធដារ។
- យុទ្ធសាស្ត្រទី៤ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការ ដោះស្រាយវិវាទពន្ធដារ។
- យុទ្ធសាស្ត្រទី៥ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការប្រមូលពន្ធ ។
- យុទ្ធសាស្ត្រទី៦ ធ្វើឱ្យប្រសើរឡើងនូវយន្តការបង់អាករលើតម្លៃបន្ថែម។[28]

➢ គោលដៅទី២ ផ្តល់ជូនអ្នកជាប់ពន្ធនូវព័ត៌មានដែលមានភាពត្រឹមត្រូវ ឯកភាព ទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ

ប្រព័ន្ធពន្ធដារកម្ពុជាមានការវិវឌ្ឍន៍ គួរឱ្យកត់សម្គាល់ទាំងផ្នែកគោលនយោបាយសារពើពន្ធ និងទំនើបកម្ម រដ្ឋបាលសារពើពន្ធក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះដែលជាលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល និងស្របពេលដែលកម្ពុជាបានចាប់ផ្តើមពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យពន្ធដារទាំងក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងការអភិវឌ្ឍនេះ តម្រូវឱ្យមានការធ្វើវិសោធនកម្ម និងបច្ចុប្បន្នភាពលើច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ បន្តបន្ទាប់ជាច្រើន ដែលជាបញ្ហាប្រឈមសម្រាប់អ្នកជាប់ពន្ធក្នុងការយល់ដឹងឱ្យបានច្បាស់លាស់ និងទាន់ពេលវេលា។ អគ្គនាយកដ្ឋាងពន្ធដារបាននឹងកំពុងធ្វើការចុះផ្សព្វផ្សាយអំពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងធ្វើការឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកជាប់ពន្ធ ដើម្បីចៀសវាងភាព

[28] ផែនការយុទ្ធសាស្ត្រ២០១៩_២០២៣(ទំព័រ៥)

ស្រពេចស្រពិល និងការបកស្រាយផ្សេងៗគ្នា។ ដូចនេះក្នុងគោលដៅផ្តល់សេវាអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរជាងមុន និងដើម្បីអោយប្រាកដថាអ្នកជាប់ពន្ធនឹងទទួលបានព័ត៌មានត្រឹមត្រូវលក្ខណៈឯកភាព ទាន់ពេលវេលា និង តាមគ្រប់មធ្យោបាយអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ រៀបចំ និងផ្តល់ព័ត៌មានត្រឹមត្រូវឯកភាពជូនអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលានិងតាម គ្រប់មធ្យោបាយ។
- យុទ្ធសាស្ត្រទី២ ផ្តល់ដំណោះស្រាយជូនអ្នកជាប់ពន្ធចំពោះរាល់ចម្ងល់ និងបញ្ហាផ្សេងៗអោយបានទាន់ពេលវេលា។

➢ គោលដៅទី៣ បង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ តាមរយៈការផ្តល់សេវាអប់រំ និងផ្សព្វផ្សាយ

ក្នុងគោលដៅផ្តល់ការយល់ដឹងអំពីកាតព្វកិច្ចសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននឹងកំពុងធ្វើការផ្តល់សេវាអប់រំ និង ផ្សព្វផ្សាយច្បាប់ និង បទប្បញ្ញត្តិស្តីពីពន្ធដារតាមរយៈការធ្វើសិក្ខាសាលាជូនអ្នកជាប់ពន្ធ ការដាក់ផ្សព្វផ្សាយក្នុងគេហទំព័រប្រព័ន្ធបណ្តាញសង្គមរបស់អគ្គនាយកដ្ឋានពន្ធដារ និង ប្រព័ន្ធផ្សព្វផ្សាយសាធារណៈជាពិសេសការផ្សព្វផ្សាយ និងរំលឹកអំពីការបង់ពន្ធតាមរដូវកាលដូចជា ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ពន្ធលើមធ្យោបាយដឹក ជញ្ជូននិងយានជំនិះគ្រប់ប្រភេទ និងពន្ធលើអចលនទ្រព្យជាដើម។ ទោះបីមានការផ្សព្វផ្សាយនិងការរំលឹកយ៉ាងណាក៏ដោយអគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថាអ្នកជាប់ពន្ធ និងសាធារណជនមួយចំនួននៅតែមិនទាន់ទទួលបាននូវការយល់ដឹងបានទូលំទូលាយ ជាពិសេសអ្នកជាប់ពន្ធនៅតាមបណ្តាខេត្ត និងតំបន់ជាយដែនដែលមានសកម្មភាពសេដ្ឋកិច្ចជាដុំកំភួន។ដូចនេះដើម្បីបង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ រៀបចំឯកសារបោះពុម្ពផ្សព្វផ្សាយឱ្យមានលក្ខណៈសាមញ្ញ និងងាយយល់
- យុទ្ធសាស្ត្រទី២ ផ្តល់ជូននូវកម្មវិធីអប់រំជាប្រចាំដោយប្រើប្រាស់នូវមធ្យោបាយ និងយុទ្ធនាការសមស្របបំផុត។
- យុទ្ធសាស្ត្រទី៣ លើកកម្ពស់ការផ្តល់សេវាបន្ថែមទៀតតាមរយៈការកំណត់តម្រូវការផ្តល់សេវាដល់អ្នកជាប់ពន្ធដោយធ្វើការស្ទង់មតិនៅតាមកម្មវិធីសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាល។
- យុទ្ធសាស្ត្រទី៤ ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធក្នុងអំឡុងពេលសវនកម្ម។

➢ គោលដៅទី៤ លើកកម្ពស់សមធម៌ និងតម្លាភាពនៃការបង់ពន្ធតាមរយៈការគោរពសិទ្ធិ និង ការពារផលប្រយោជន៍របស់អ្នកជាប់ពន្ធ តាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងគោលដៅលើកកម្ពស់សមធម៌ និងតម្លាភាពក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបន្តផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងកម្រងសេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានកំណត់តម្លៃ និងរយៈពេលនៃការផ្តល់សេវាច្បាស់លាស់នៅគ្រប់អង្គភាពពន្ធដារ។ ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានរៀបចំដោយដាក់បញ្ចូលគោលការណ៍សមធម៌ជាមូលដ្ឋានគ្រឹះ ដូចជាការកំណត់ប្រភេទ អ្នកជាប់ពន្ធការយកពន្ធតាមអត្រាកំណើន និងការលើកទឹកចិត្តផ្នែកពន្ធជាដើម។ ទោះជាយ៉ាងនេះក៏ដោយអ្នក ជាប់ពន្ធមួយចំនួននៅតែយល់ឃើញថាការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារមិនទាន់មានសមធម៌និង តម្លាភាពគ្រប់គ្រាន់នៅឡើយ។ ដើម្បីទទួលបាននូវមតិ ឬ ការរិះគន់ស្ថាបនាពីអ្នកជាប់ពន្ធអគ្គនាយកដ្ឋានពន្ធដារបានលើកទឹកចិត្តឱ្យអ្នកជាប់ពន្ធបញ្ចេញមតិយោបល់តាមគ្រប់មធ្យោបាយដូចជាតាមរយៈសារអេឡិចត្រូនិចមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Call Center) សេវាជជែកជាមួយអគ្គនាយកដ្ឋានពន្ធដារ (GDT Live Chat) ប្រព័ន្ធបណ្តាញសង្គម ប្រអប់សំបុត្រ ឬធ្វើ ឡើងដោយផ្ទាល់មាត់តាមរយៈបញ្ជូរពិគ្រោះយោបល់ ប៉ុន្តែនៅតែមិនទាន់ទទួលបានការជឿទុកចិត្តពេញលេញនៅឡើយពីអ្នកជាប់ពន្ធនិងសាធារណជន។ ដើម្បីបន្តលើកកម្ពស់សមធម៌តម្លាភាព និងកសាងទំនុកចិត្តអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ បច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈទាក់ទងនឹងកម្រងសេវា និងពេលវេលា
- យុទ្ធសាស្ត្រទី២ កែលម្អរដ្ឋបាលសារពើពន្ធតាមរយៈការទទួលមតិយោបល់ពីអ្នកជាប់ពន្ធ តាមគ្រប់មធ្យោបាយ។
- យុទ្ធសាស្ត្រទី៣ បង្កើនជំនឿទុកចិត្តនិងភាពជឿជាក់ពីសាធារណជនតាមរយៈការពង្រឹង សុចរិតភាពរបស់ រដ្ឋបាលសារពើពន្ធ។

➢ គោលដៅទី៥ ផ្តល់សេវាដើម្បីឆ្លើយតបទៅនឹងតម្រូវការ ភាពពេញចិត្ត និងឥរិយាបថជាក់លាក់របស់អ្នកជាប់ពន្ធស្របតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ

លទ្ធផលនៃកំណើន និង ពិពិធកម្មសេដ្ឋកិច្ចធ្វើឱ្យមូលដ្ឋានពន្ធមានការកើនឡើងដែលតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារចាំបាច់ត្រូវបន្តស្វែងយល់អំពីតម្រូវការ ភាពពេញចិត្ត និងឥរិយាបថរបស់អ្នកជាប់ពន្ធតាមប្រភេទនិងវិស័យដើម្បីផ្តល់សេវាប្រកបដោយគុណភាពក្នុងគោលដៅជំរុញឱ្យអ្នកជាប់ពន្ធអនុវត្តបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ ដើម្បីសម្រេចបាននូវគំនិតផ្តួចផ្តើមថ្មីនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ កំណត់តម្រូវការ ភាពពេញចិត្ត និងឥរិយាបថ តាមប្រភេទអ្នកជាប់ពន្ធលើ ការផ្តល់សេវាតាមរយៈការស្ទង់មតិ។

- យុទ្ធសាស្ត្រទី២ លើកទឹកចិត្ត និងផ្តល់សេវាជាអាទិភាពសម្រាប់អ្នកជាប់ពន្ធដែលមានអនុលោមភាពខ្ពស់។

➢ គោលដៅទី៦ លើកកម្ពស់ភាពជាដៃគូរជាមួយវិស័យឯកជន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនានា

អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងសហការចូលរួមយ៉ាងសកម្មជាមួយវិស័យឯកជនក្នុងការពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈម និងសំណូមពរ ឬ ដំណោះស្រាយនានាពាក់ព័ន្ធនឹងពន្ធដារតាមរយៈវេទិកាកិច្ចពិភាក្សា និងយន្តការភាពជាដៃគូនានា។ ទន្ទឹមនឹងនេះអគ្គនាយកដ្ឋានពន្ធដារបានកំពុងសហការជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងគោលដៅផ្លាស់ប្តូរព័ត៌មាន និង ផ្តល់ផលប្រយោជន៍ទាំងក្នុងការប្រមូលចំណូលពន្ធ និងក្នុងការបំពេញការងាររបស់ស្ថាប័នសាមីផងដែរ។ ជាក់ស្តែងកិច្ចសហការជាមួយវិស័យឯកជននៅតែតម្រូវឱ្យមានការលើកកម្ពស់បន្ថែមទៀតដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមរបស់អ្នកជាប់ពន្ធ និងប្រមូលធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់កែលម្អគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ ដោយឡែកចំពោះក្រសួងស្ថាប័នពាក់ព័ន្ធដែលមិនទាន់មាន ឬ មានយន្តការដែលមិនមានប្រសិទ្ធភាពតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារស្វែងរកលទ្ធភាពបង្កើតឬកែសម្រួលយន្តការសមស្រប ដើម្បីផ្លាស់ប្តូរព័ត៌មានក្នុងទិសដៅប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ រៀបចំកម្មវិធីជួបពិភាក្សាជាប្រចាំដើម្បីប្រមូលធាតុចូលនិងស្វែងរកដំណោះស្រាយពីវិស័យឯកជន។
- យុទ្ធសាស្ត្រទី២ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ តាមរយៈការបង្កើតយន្តការគាំទ្រ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការផ្លាស់ប្តូរព័ត៌មាន។

យើងឃើញថាបញ្ហាធំពីរនៅក្នុងប្រតិបត្តិការស្នូល គឺការបង្វិលសងអាករលើតម្លៃបន្ថែម (VAT) និងការធ្វើសវនកម្មជាន់គ្នា ដែលត្រូវបានដោះស្រាយតាមរយៈការដាក់ចេញនូវ៖ (១) ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម និង (២) ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ.ប្រក ចុះ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ដែលបានកំណត់នូវវិធាននិងនីតិវិធីលម្អិតសំដៅលុបបំបាត់ការចុះធ្វើសវនកម្មជាន់គ្នារវាងអង្គភាពជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ការកាត់បន្ថយពេលកំណត់ពន្ធឡើងវិញ ចំពោះការធ្វើសវនកម្មពេញលេញដោយកំណត់គោលការណ៍ទូទៅមកនៅត្រឹម ៣ឆ្នាំ ថយក្រោយ និងកាត់បន្ថយអត្រាការប្រាក់ទោសទណ្ឌលើការបង់ប្រាក់ពន្ធយឺតពី ២% មកត្រឹម ១,៥% ក្នុងមួយខែទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់មុខងារប្រតិបត្តិការស្នូលនៅបន្តមានបញ្ហាប្រឈមមួយចំនួនផងដែរ។

## ១.៣ មុខងារគាំទ្រ

មុខងារគាំទ្រ គឺជាប្រភេទមុខងារពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធចាត់តាំងការងារ និងការរៀបចំផែនការទូទៅរបស់អង្គភាពដូចជា ផែនការគ្រប់គ្រងធនធានរួមទាំងធនធានជាសម្ភារៈ ឧបករណ៍បច្ចេកវិទ្យា និងធនធានមនុស្សដែលជាមុខងារគន្លឹះក្នុងការគាំទ្រ និងពង្រឹងសមត្ថភាពនៃការបំពេញមុខងារប្រតិបត្តិការស្នូល។ មានន័យថា ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រទាមទារនូវកត្តាពីរសំខាន់ គឺហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលគាំទ្រការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធ និងធនធានមនុស្សដែលមានសមត្ថភាព និងជំនាញវិភាគតាមវិស័យ ។

ដូចនេះសម្រាប់កម្ពុជាការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រ នឹងផ្តោតលើការងារពីរផ្នែកគឺៈ

(១) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលសារពើពន្ធដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡារួមមានមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ ប្រព័ន្ធវិភាគទិន្នន័យ និងព័ត៌មានអ្នកជាប់ពន្ធ ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធប្រព័ន្ធ ចែករំលែកទិន្នន័យក្នុងស្ថាប័ន និងអន្តរស្ថាប័ន និង

(២) យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារដើម្បីធានាថាមន្ត្រីអនុវត្តការងារប្រកបដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ ។[29]




មុខងារគាំទ្រស្ថិតក្នុង គោលបំណងទី២នៃផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារគឺ បង្កពង្រឹង ការអនុវត្តច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងមាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ។

[29] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ១៤)

អគ្គនាយដ្ឋានពន្ធដារកំពុងបន្តពង្រឹងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធតាមរយៈការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដោយទន់ភ្លន់តែម៉ឺងម៉ាត់ និងកែលម្អព្រមទាំងរិះរកនូវវិធានការថ្មីៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីបំពេញនូវចន្លោះប្រហោងច្បាប់ និងបទប្បញ្ញត្តិដែលកន្លងមកផ្តល់ឱកាសឱ្យមានការគេចវេះ និងកិបកេងបន្លំពន្ធ។ ដើម្បីសម្រេចគោលបំណងអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវគោលដៅមួយចំនួនដូចខាងក្រោម៖

- **គោលដៅទី១ កំណត់អត្តសញ្ញាណអ្នកជាប់ពន្ធ ដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនៅក្នុងវិស័យដែល មានហានិភ័យខ្ពស់ តាមរយៈការប្រមូលផ្តុំពត៌មានពីប្រភពខាងក្នុង និងខាងក្រៅ[30]**

ការកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវនៅក្នុងវិស័យដែលមានហានិភ័យខ្ពស់ជាវិធីសាស្ត្រគន្លឹះក្នុងការជ្រើសរើសអ្នកជាប់ពន្ធសម្រាប់ការធ្វើសវនកម្មចំគោលដៅ។ បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបាន និងកំពុងធ្វើការកែលម្អវិធីសាស្ត្រកំណត់ហានិភ័យ រៀបចំផែនការសវនកម្ម និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធក្នុង វិស័យដែលមានហានិភ័យខ្ពស់។ ទោះបីជាមានការអភិវឌ្ឍលើវិធីសាស្ត្រក្នុងការកំណត់ហានិភ័យប៉ុន្តែដើម្បីលើកកម្ពស់គុណភាពនៃការកំណត់ហានិភ័យ សម្រាប់ការធ្វើសវនកម្មចំគោលដៅ និងទាន់ពេលវេលាតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តកែលម្អវិធីសាស្ត្រទាំងនោះឱ្យមានស្តង់ដាររួម និងដំណើរការដោយស្វ័យប្រវត្តិសំដៅធានាបាននូវសុក្រឹតភាព និងប្រសិទ្ធភាព។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ អភិវឌ្ឍ និងកែលម្អវិធីសាស្ត្រកំណត់ហានិភ័យឱ្យមានស្តង់ដាររួមដើម្បីឈានទៅបង្កើតប្រព័ន្ធកំណត់ហានិភ័យជាស្វ័យប្រវត្តិ។
- យុទ្ធសាស្ត្រទី២ កំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់។
- យុទ្ធសាស្ត្រទី៣ ជំរុញពង្រឹង និងពន្លឿនការផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលាសម្រាប់គោលបំណងសវនកម្ម និងដើម្បីឈានទៅបង្កើតប្រព័ន្ធផ្លាស់ប្តូរព័ត៌មានជាស្វ័យប្រវត្តិ។

- **គោលដៅទី២ ពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព[31]**

[30] ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩_២០២៣(ទំព័រ៩)

[31] ផែនការយុទ្ធសាស្ត្រ២០១៩_២០២៣(ទំព័រ១០)

ឥរិយាបថរបស់អ្នកជាប់ពន្ធមួយចំនួនក្នុងការព្យាយាមគេចវេះពន្ធ និងកិបកេងបន្លំពន្ធបង្កឱ្យមានការប្រកួតប្រជែងមិនស្មើភាព និងប៉ះពាល់ដល់សមធម៌ក្នុងការបង់ពន្ធ។ ដើម្បីលើកកម្ពស់អនុលោមភាពពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានបន្តដាក់ចេញនូវវិធានការជាច្រើនក្នុងការពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិស្តីពីពន្ធដារដូចជាការធ្វើវិសោធនកម្មច្បាប់ និង បទប្បញ្ញត្តិស្តីពីពន្ធដារជាប្រចាំ ការដកហូតជាបណ្តោះអាសន្ននូវវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ការចាត់មន្ត្រីពន្ធដារទៅប្រចាំការនៅទីតាំងផលិតដែលត្រូវជាប់អាករពិសេស ការកំណត់ហានិភ័យក្នុងការធ្វើសវនកម្មឱ្យចំគោលដៅ និងកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសពន្ធដារដោយម៉ឹងម៉ាត់ ការកែលម្អវិធានការដោះស្រាយបណ្តឹងតវ៉ាពន្ធដា ការពង្រឹងការអនុវត្តវិធានការតឹងទារបំណុលពន្ធ និងការជំរុញការចរចាកិច្ចព្រមព្រៀងស្តីពីចៀសវាងការយកពន្ធត្រួតគ្នា។ល។ ទោះជាមានវិធានការរឹងមាំដូចខាងលើក៏ដោយក៏អគ្គនាយកដ្ឋានពន្ធដារចាំបាច់ត្រូវបន្តកែសម្រួលលើកកម្ពស់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយផ្តោតសំខាន់លើមុខងារស្នូលដើម្បីជំរុញការប្រកួតប្រជែងដោយស្មើភាព និង សមធម៌ក្នុងការបង់ពន្ធ។ ដើម្បីសម្រេចគោលដៅនេះអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ ពង្រឹងការចុះបញ្ជីពន្ធដារ។
- យុទ្ធសាស្ត្រទី២ ពង្រឹងការចាត់ចែងលិខិតប្រកាស។
- យុទ្ធសាស្ត្រទី៣ ពង្រឹងការធ្វើសវនកម្ម និងស៊ើបអង្កេតបទល្មើសពន្ធដារ។
- យុទ្ធសាស្ត្រទី៤ ពង្រឹងការគ្រប់គ្រងប្រមូលបំណុលពន្ធនិងការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។
- យុទ្ធសាស្ត្រទី៥ ពង្រឹងការបង្វិលសងអាករលើតម្លៃបន្ថែម។
- យុទ្ធសាស្ត្រទី៦ រៀបចំកែសម្រួល និងធ្វើអោយប្រសើរឡើងនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដើម្បីឆ្លើយតប និងការវិវឌ្ឍននៃបរិបទធុរកិច្ចជាតិ និងអន្តរជាតិ។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកវឌ្ឍនភាពសំខាន់ៗក្នុងការកែទម្រង់មុខងារគាំទ្ររបស់អគ្គនាយកដ្ឋានពន្ធដារដូចជា៖ បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស២០១៤-២០១៨ បានបញ្ចប់ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបានពង្រឹងសវនកម្មផ្ទៃក្នុង ។ យ៉ាងណាមិញការអនុវត្តផែនការមេ និងយុទ្ធសាស្ត្រខាងលើនៅមិនទាន់អាចគាំទ្រដំណើរការការងារ ប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាពដោយសារបញ្ហាមួយចំនួនផងដែរដោយសមត្ថភាពជំនាញឯកទេស និង ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីមួយចំនួននៅមានកម្រិតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធមិនទាន់មានភាពប្រទាក់ក្រឡា និងស្វ័យប្រវត្តិកម្មពេញលេញដែលមិនអាចធានាបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងប្រតិបត្តិការប្រចាំថ្ងៃក្នុងការផ្តល់សេវានៅឡើយ ។

ដូចនេះការពង្រឹងមុខងារគាំទ្ររួមមាន៖ ១)ពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ ២)បច្ចេកវិទ្យាព័ត៌មាន និង ៣)ការគ្រប់គ្រងធនធានមនុស្ស ។

**១.៣.១ ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង**

ការពង្រឹងការគ្រប់គ្រង គឺជាគោលបំណងទី៣ របស់អគ្គនាយកដ្ឋានពន្ធដារការអនុវត្តការងារអោយមានប្រសិទ្ធិភាពខ្ពស់ដោយពង្រឹងស្ថាប័ន។

ដើម្បីពង្រឹងការគ្រប់គ្រង និង ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារអោយកាន់តែមានប្រសិទ្ធិភាព អគ្គនាយកដ្ឋានពន្ធដារបាននឹងកំពុងធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នឹងធ្វើការកែទម្រង់លើការគ្រប់គ្រងធនធានមនុស្ស ដើម្បីគាំទ្រស្ថាប័នក្នុងការជំរុញអោយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពការងារអោយកាន់តែមានប្រសិទ្ធិភាពដោយប្រកាន់ខ្ជាប់នូវភាពទន់ភ្លន់ ម៉ឺងម៉ាត់ ស្មើភាព និងកែលម្អព្រមទាំងវិធានការថ្មីៗប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីបំពេញនូវចន្លោះប្រហោងច្បាប់ និង បទបញ្ញត្តិដែលកន្លងមក ផ្តល់ឱកាសអោយមានការគេចវេះនិងកិបកេងបន្លំប្រាក់ពន្ធ។ដើម្បីសម្រេចគោលបំណងនេះអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវគោលដៅ២ដូចខាងក្រោមគឺ៖ (១)គោលដៅអភិវឌ្ឍន៍ និង ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលសារពើពន្ធតាមរយៈបច្ចេកវិទ្យាព័ត៌មាន និង (២)គោលដៅពង្រឹងប្រសិទ្ធភាពការងារ និងអភិវឌ្ឍន៍សមត្ថភាព។[32]

ដោយអគ្គនាយកដ្ឋានពន្ធដារបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់អង្គភាព និងការគ្រប់គ្រងធនធានមនុស្សដូចខាងក្រោម៖

-រចនាសម្ព័ន្ធ បច្ចុប្បន្នមាននាយកដ្ឋានថ្នាក់ កណ្តាលចំនួន១១អង្គភាពថ្នាក់មូលដ្ឋានសាខាខណ្ឌនៃរាជធានីភ្នំពេញមាន ចំនួន៩ និងសាខាពន្ធដារខេត្តចំនួន២៥។

-ម៉ោងធ្វើការ និងការកត់ត្រាវត្តមានបានកែសម្រួលម៉ោងធ្វើការរបស់មន្ត្រីពន្ធដារ និងបង្កើតប្រព័ន្ធវត្តមានដោយមានការស្កេនម្រាមដៃផងដែរ។ ដែលបានកែប្រែទម្លាប់របស់មន្ត្រីមួយចំនួនដែលមិនគោរពនៃពេលវេលាម៉ោងធ្វើការ។

-ការិយាល័យធ្វើការ មានស្តង់ដារដោយបំពាក់កុំព្យូទ័រ និងសម្ភារៈការិយាល័យ ផ្តល់ប័ណ្ណសម្គាល់ដល់មន្ត្រីពន្ធដារសម្រាប់ចេញ ចូល ព្រមទាំងមានប្រព័ន្ធការពារសុវត្ថិភាពផងដែរ។

-ការបើកប្រាក់បៀវត្សធ្វើឡើងជាមួយធនាគារ រឹងឆាប់រហ័ស និងទទួលបានពេញចំនួន។

-ត្រូវបានទទួលស្គាល់ជានគរបាលយុត្តិធម៌

-ការគ្រប់គ្រងធនធានមនុស្ស មានប្រព័ន្ធសម្រាប់គ្រប់គ្រង ត្រួតពិនិត្យពត៌មានរបស់មន្ត្រី គ្រប់គ្រងរបាយការណ៍ប្រចាំថ្ងៃ គ្រប់គ្រងវាយតម្លៃមន្ត្រី វត្តមាន គ្រប់គ្រងការសុំច្បាប់ របាយការណ៍ និងម៉ោងធ្វើការជាដើម។

[32] ផែនការយុទ្ធសាស្ត្រ២០១៩_២០២៣(ទំព័រ១១)

### ១.៣.២ បច្ចេកវិទ្យាព័ត៌មាន

ក្នុងការធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការពង្រឹងការប្រតិបត្តិការងារផ្ទៃក្នុង និងការផ្ដល់សេវាដល់អ្នកជាប់ពន្ធ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

- **គោលដៅទី១ នៅក្នុងគោលបំណងទី៣របស់អគ្គនាយកដ្ឋានពន្ធដារគឺ អភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលសារពើពន្ធ តាមរយៈបច្ចេកវិទ្យាព័ត៌មាន។**

អគ្គនាយកដ្ឋានពន្ធដារបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយមានប្រព័ន្ធប្រមូលផ្ដុំទិន្នន័យ និងព័ត៌មាន(Centralized Database System) ដូចជា ការគ្រប់គ្រងការចុះបញ្ជី ការដាក់លិខិតប្រកាស សវនកម្ម បំណុលពន្ធនិងបណ្ដឹងតវ៉ា របាយការណ៍ចំណូលពន្ធ ការតាមដានឯកសារ និងការគ្រប់គ្រងធនធានមនុស្ស ព្រមទាំងកម្មវិធីសម្រាប់ប្រើប្រាស់លើឧបករណ៍អេឡិចត្រូនិកផ្សេងៗ។ ដើម្បីឈានទៅទំនើបកម្មរដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តអភិវឌ្ឍន៍ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបន្ថែមទៀតឱ្យស្របតាមការវិវឌ្ឍ និងឧត្តមានុវត្តន៍នៃការប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ដើម្បីសម្រេចគោលដៅនេះអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត ដូចខាងក្រោមៈ

- យុទ្ធសាស្ត្រទី១ បង្កើតធ្វើបច្ចុប្បន្នភាព និងកំណែទៅជំនាន់ថ្មីនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ។
- យុទ្ធសាស្ត្រទី២ បង្កើតជំរុញ និងធ្វើឱ្យប្រសើរឡើងនូវនីតិវិធីប្រតិបត្តិការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈទំនើបមានសារៈសំខាន់ក្នុងការគាំទ្រដល់ ការងារចុះបញ្ជីអ្នកជាប់ពន្ធ សេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាសពន្ធ ការធ្វើសវនកម្ម ការគ្រប់គ្រងបំណុលពន្ធ និងការសន្សំពេលវេលាតាមរយៈការបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងទិន្នន័យ និង ចំនួនមន្ត្រីតាមរយៈការផ្លាស់ប្តូរពីការងារដែលប្រតិបត្តិដោយដៃមកជាការប្រតិបត្តិដោយប្រព័ន្ធកុំព្យូទ័រ។ ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រទាមទារនូវកត្តា២យ៉ាងសំខាន់ៗគឺៈហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលគាំទ្រការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធ និងធនធានមនុស្សដែលមានសមត្ថភាព និងជំនាញវិភាគតាមវិស័យ។

ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រនឹងផ្តោតលើការងារ២ផ្នែកគឺៈ

១.ប្រព័ន្ធព័ត៌មានវិទ្យារដ្ឋបាលសារពើពន្ធដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និង ប្រទាក់ក្រឡារួមមានមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ ប្រព័ន្ធវិភាគទិន្នន័យនិងព័ត៌មានអ្នកជាប់ពន្ធ ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ ប្រព័ន្ធចែករំលែកទិន្នន័យក្នុងស្ថាប័ន និងអន្តរស្ថាប័ន ។

២.យុទ្ធសាស្ត្រអភិវឌ្ឍធនមធានមនុស្ស និងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃសមទ្ធកម្មការងារ ដើម្បីធានាថាមន្ត្រីអនុវត្តការងារប្រកបដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ។

បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបានដាក់អោយដំណើរការកម្មវិធីបង់ពន្ធ ព្រមទាំងធ្វើការអភិវឌ្ឍន៍នូវកម្មវិធីប្រព័ន្ធបច្ចេកវិទ្យាជាច្រើនប្រភេទដែលជាជំនួយដល់អ្នកជាប់ពន្ធមានភាពងាយស្រួលក្នុងការបង់ប្រាក់ពន្ធទាន់ពេលវេលាជាមួយធនាគារជាដៃគូមួយចំនួន ក៏ដូចជាទទួលបានព័ត៌មានពន្ធដារឆាប់រហ័សផងដែរ។

កម្មវិធីទាំងនោះអាចប្រើប្រាស់បានទាំងលើគេហទំព័រ (WEB APP) និងកម្មវិធីទូរស័ព្ទដៃ(Android App , IOS) និង កម្មវិធីលើកុំព្យូទ័រ (Desk Top App) ជាដើម។

ខាងក្រោមនេះជាសេវាកម្មអេឡិចត្រូនិចពន្ធដារ៖

កម្មវិធីលើគេហទំព័រ(Web App) កម្មវិធីលើគេទូរស័ព្ទដៃ (Android App & IOS App)



**មុខងារគាំទ្រ ÷ ប្រព័ន្ធបច្ចេកវិទ្យាពត៌មាន ដែល អពដ សម្រេចបាន**

ឆ្នាំ២០១៤

1. ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីពន្ធដារ
2. ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីពន្ធដារ តាមអនឡាញ
3. ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

ឆ្នាំ២០១៥

4. ប្រព័ន្ធសុវត្ថិភាពច្រកចេញចូល
5. ប្រព័ន្ធគ្រប់គ្រងបង្កាន់ដៃបញ្ជាក់ការទទួលប្រា ក់ពន្ធ
6. ប្រព័ន្ធគ្រប់គ្រងពន្ធអចលទ្រព្យ
7. ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយ ។
8. ប្រព័ន្ធគ្រប់គ្រងការផ្ទេរកម្មសិទ្ធិមធ្យោបាយ ដឹកជញ្ជូន
9. ប្រព័ន្ធគ្រប់គ្រងការប្រឡងជ្រើសរើសមន្ត្រីពន្ធដា រ
10. មជ្ឈមណ្ឌលរក្សាទុកទិន្នន័យលក្ខណៈស្វ័យប្រ វត្តិ

ឆ្នាំ២០១៦

11. រៀបចំមជ្ឈមណ្ឌលបំលែងឯកសារ
12. ប្រព័ន្ធគ្រប់គ្រងការប្រមូលប្រាក់ពន្ធគ្រប់ប្រភេទ
13. ប្រព័ន្ធគ្រប់គ្រងទទួលលិខិតប្រកាសពន្ធ
16. ការគ្រប់គ្រងរបាយការណ៍តាមសាខា
17. ប្រព័ន្ធគ្រប់គ្រងពន្ធលើការជួលអចលនទ្រព្យ
18. ប្រព័ន្ធគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារ
19. ប្រព័ន្ធគ្រប់គ្រងសហគ្រាសទទួលផ្គត់ផ្គង់VAT
20. ប្រព័ន្ធគ្រប់គ្រងសហគ្រាសដែលជាQIPs
21. ប្រព័ន្ធគ្រប់គ្រងការផ្អាកសកម្មភាពរបស់
22. ប្រព័ន្ធគ្រប់គ្រងការងារអង្កេតសហគ្រាស
23. ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃ លទ្ធផលការងារ

ឆ្នាំ២០១៧

24. ប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ
25. ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់បុគ្គល
26. ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធតាមអនឡាយ
27. ប្រព័ន្ធគ្រប់គ្រង Call Center
28. ប្រព័ន្ធគ្រប់គ្រងសវនកម្ម
29. ប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ
30. ប្រព័ន្ធវាយតម្លៃមន្ត្រី តាមទូរស័ព្ទ
31. ប្រព័ន្ធគ្រប់គ្រងលិខិតរំលឹកពីការដាក់លិខិតប្រ កាស
32. ប្រព័ន្ធគ្រប់គ្រងតែមប្រើ
33. ប្រព័ន្ធគ្រប់គ្រងស្ដីពីការបង្កើតអនុលោមភា ពសារពើពន្ធ
34, ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លើយតប
35. ប្រព័ន្ធគ្រប់គ្រងការបញ្ជូនរបាយការណ៍ (FATCA)

ឆ្នាំ២០១៨

36. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាស
37. ប្រព័ន្ធគ្រប់គ្រងការកត់ត្រាឯកសារលិខិតប្រកាស
38. ប្រព័ន្ធគ្រប់គ្រងការស្វែនឯកសារលិខិតប្រកាស
39. ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសងអាករលើតម្លៃ
40. ប្រព័ន្ធគ្រប់គ្រងe-Filing អាករលើតម្លៃបន្ថែម
41. ប្រព័ន្ធគ្រប់គ្រងគណនីប្រើប្រាស់របស់អ្នកជាប់ពន្ធ
42. រៀបចំប្រព័ន្ធគ្រប់គ្រងកាចៀសវាងយកពន្ធត្រួតគ្នា
43. ប្រព័ន្ធគ្រប់គ្រងស្តុករបស់អគ្គនាយកដ្ឋានពន្ធដារ
44. ប្រព័ន្ធគ្រប់គ្រងកម្មវិធីប្រជុំរបស់អគ្គនាយកដ្ឋានពន្ធដារ
45. ប្រព័ន្ធគ្រប់គ្រងការបង្វិលសង អតប សម្រាប់ជនបរទេស
46. ប្រព័ន្ធគ្រប់គ្រងគណនីរបស់មន្ត្រីពន្ធដារ និងដៃគូសហកា
47. ប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដារ
48. ប្រព័ន្ធគ្រប់គ្រងសិក្ខាសាលារបស់អគ្គនាយកដ្ឋានពន្ធដា
49. ប្រព័ន្ធគ្រប់គ្រងសំណើសុំជំនួយ ជំនាន់ទី១២

ឆ្នាំ២០១៩

50. ប្រព័ន្ធគ្រប់គ្រងការចៀសវាងយកពន្ធត្រួតគ្ន
51. ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសង អតប (VAT Refud)
52. ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយ
53. ប្រព័ន្ធគ្រប់គ្រងចុះបញ្ជីសហគ្រាស
54. ប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គល
55. ប្រព័ន្ធគ្រប់គ្រងការទទួលប្រាក់ពន្ធ (Single Invoice)
56. ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធ តាមអនឡាញ (e-Payment)
57. ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម តាមអនឡាញ
58. ប្រព័ន្ធគ្រប់គ្រងអង្កេតអចលនទ្រព្យ
59. ប្រព័ន្ធគ្រប់គ្រងការកត់ត្រាឯកសារលិខិតប្រកាស
60. ប្រព័ន្ធគ្រប់គ្រងស្វែនឯកសារលិខិតប្រកាសស្វ័យប្រវត្តិ
61. កម្មវិធីការប្រកាសពន្ធអាជីវកម្ម សម្រាប់អ្នកជាប់ពន្ធតូច
62, កម្មវិធីគណនាពន្ធលើមធ្យោបាយ ដឹកជញ្ជូន។
63. កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ
64. កម្មវិធីសែនវត្តមានមន្ត្រី Upgrade
65. គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
66. ប្រព័ន្ធគ្រប់គ្រងសាលាជាតិពន្ធដារ
67. ប្រព័ន្ធគ្រប់គ្រងស្តុករបស់អគ្គនាយកដ្ឋានពន្ធដារ
68. ប្រព័ន្ធគ្រប់គ្រងគណនីអ្នកជាប់ពន្ធ (e-Tax Core System)
69. ប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដារ (MapReverunDashboard)
70. កម្មវិធីចែកបណ្ណប៉ាតង់សហគ្រាស
71. ប្រព័ន្ធគ្រប់គ្រងការចុះឈ្មោះចូលរួមសិក្ខាសាលា

## ១.៣.៣ កំណែទម្រង់ធនធានមនុស្ស

➢ **គោលដៅទី២របស់អគ្គនាយកដ្ឋានពន្ធដារ គឺពង្រឹងប្រសិទ្ធភាពការងារ និងអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈមន្ត្រី។**

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានពន្ធដារចាត់ទុកថាជាកត្តាគន្លឹះក្នុងការបង្កើនប្រសិទ្ធភាពក្នុងការប្រមូលពន្ធហេតុនេះទើបអគ្គនាយកដ្ឋានពន្ធដារតែងតែយកចិត្តទុកដាក់ ក្នុងការលើកកម្ពស់សមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្ត្រីពន្ធដារតាមរយៈការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសលើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងពន្ធដារព្រមទាំង ជំនាញទន់ (Soft Skills) ដូចជាជំនាញគ្រប់គ្រង ជំនាញប្រាស្រ័យទាក់ទង ជំនាញដោះស្រាយបញ្ហា និងជំនាញធ្វើការជាក្រុម។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារខ្ពស់ជាងមុនអគ្គនាយកដ្ឋានពន្ធដារត្រូវពង្រឹងសមត្ថភាពមន្ត្រី និង ថ្នាក់ដឹកនាំបន្ថែមទៀត។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្តដូចខាងក្រោម៖

- យុទ្ធសាស្រ្តទី១ ស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដើម្បីឆ្លើយតបនឹងតម្រូវការរបស់អគ្គនាយកដ្ឋានពន្ធដារឱ្យស្របតាមការអភិវឌ្ឍសេដ្ឋកិច្ច និង បរិបទធុរកិច្ច

ជាតិ និងអន្តរជាតិ។

- យុទ្ធសាស្ត្រទី២ ពង្រឹងគុណភាពការងារ និងលើកកម្ពស់ការចែករំលែកចំណេះដឹងជំនាញ និងបទពិសោធន៍។
- យុទ្ធសាស្ត្រទី៣ ពង្រឹងសមត្ថភាព និង ភាពជាអ្នកដឹកនាំ របស់អ្នកគ្រប់គ្រង (ប្រធានការិយាល័យ អនុប្រធានសាខា ប្រធានសាខា និងអនុប្រធាននាយកដ្ឋាន)។

ធនធានមនុស្ស និងការបណ្តុះបណ្តាលដូចខាងក្រោមៈ

-ការដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស

-ការកំណត់លក្ខខណ្ឌការងារ និងការងារទទួលខុសត្រូវតម្រូវការបន្ថែមមន្ត្រីថ្មី ដែលមានសមត្ថភាព

-ការបណ្តុះបណ្តាល ក្នុងស្រុកនិងនៅសាលាជាតិពន្ធដារ

-ការបណ្តុះបណ្តាលផ្សារភ្ជាប់ជាមួយការអនុវត្ត

-ការបណ្តុះបណ្តាលក្រៅប្រទេស

-ការចូលរួមសិក្ខាសាលា វេទិកាស្តីពីពន្ធដារ និងប្រជុំក្នុងស្រុកនិងក្រៅស្រុក

-ការធ្វើទស្សនកិច្ចសិក្សានៅក្រៅប្រទេស

-ទទួលជំនួយបច្ចេកទេសពីដៃគូរអភិវឌ្ឍន៍

-មានទោសទណ្ឌនិងការពិន័យចំពោះមន្ត្រីដែលធ្វើខុស

➢ **គោលដៅទី៣ លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងអភិបាលកិច្ច**

ក្រៅពីសមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្ត្រីពន្ធដា ក្រមសីលធម៌វិជ្ជាជីវៈ និងអភិបាលកិច្ចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនផលិតភាព និងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធប្រកបដោយគុណតម្លៃ ដើម្បីបង្កើននូវជំនឿទុកចិត្តពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជនចំពោះរដ្ឋបាលសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបាន និង កំពុងធ្វើការកែទម្រង់លើការគ្រប់គ្រងធនធានមនុស្ស ដោយជំរុញនិងលើកទឹកចិត្តមន្ត្រីឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់ បង្កើនភាពម្ចាស់ការលើការងារ និងការបំពេញភារកិច្ចឱ្យអស់ពីសមត្ថភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស) ក្នុងការគ្រប់គ្រងប្រចាំថ្ងៃ និងវាយតម្លៃលទ្ធផលការងារជាប្រចាំ។ អគ្គនាយកដ្ឋានពន្ធដារក៏បានផ្តោតសំខាន់ផងដែរលើការធ្វើសវនកម្មផ្ទៃក្នុងដែលមានសារៈសំខាន់ក្នុងការគ្រប់គ្រងធនធានមនុស្ស និង សម្ភារបរិក្ខារដោយម៉ត់ចត់ សំដៅធានាបានការប្រើប្រាស់ចំទិសដៅបង្កើនគណនេយ្យភាព អភិបាលកិច្ច និងភាពជឿទុកចិត្ត។

ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋាន ពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១ ពង្រឹងប្រសិទ្ធភាព និងគុណភាពការងារតាមរយៈសវនកម្មផ្ទៃក្នុង។
- យុទ្ធសាស្ត្រទី២ ពង្រឹងប្រសិទ្ធភាពការងារ និងគុណភាពធនធានមនុស្ស។
- យុទ្ធសាស្ត្រទី៣ ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា។

ការគ្រប់គ្រងមនុស្ស គឺជាការងារស្នូលដែលអគ្គនាយកដ្ឋានពន្ធដារបានខិតខំយកចិត្តទុកដាក់អនុវត្តតាមរយៈការជ្រើសរើសមន្ត្រីបន្ថែមការបណ្តុះបណ្តាលមន្ត្រីនៅក្នុង និង ក្រៅប្រទេសការរៀបចំវិន័យ និង ក្រមសីលធម៌មន្ត្រី ពង្រឹងវិជ្ជាជីវៈការដាក់ទោសទណ្ឌមន្ត្រីប្រព្រឹត្តខុស។ល។ អគ្គនាយកដ្ឋានពន្ធដារបាននឹងកំពុងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សដោយផ្តោតលើការជ្រើសរើសមន្ត្រីថ្មី ការបណ្តុះបណ្តាលមន្ត្រី ការធ្វើផែនការអំពីចំនួនមន្ត្រីសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត វិន័យ និងក្រមសិលធម៌ ការគ្របគ្រងស្ថិតិ មន្ត្រីអត្រាបែងចែកមន្ត្រីតាមសក្តានុពលរបស់ចំណូល និងអត្រាបាត់បង់មន្ត្រី។

ការរៀបចំឱ្យមានយុទ្ធសាស្ត្រនេះ បានជួបបញ្ហាប្រឈមមួយចំនួនដែរ ដូចជា៖

(១) មន្ត្រីដែលមានជំនាញ និង បទពិសោធន៍មានចំនួនតិចត្រូវបានចាត់តាំងទទួលបន្ទុកកិច្ចការជាច្រើនដែលមិនមែនជាភារកិច្ចចម្បងរបស់ខ្លួន ដូចជារៀបចំគោលយោបាយសារពើពន្ធ និងកិច្ចការបន្ទាន់ផ្សេងៗទៀតដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ។

(២) មន្ត្រីមួយភាគធំនៅតាមសាខាពន្ធដារខណ្ឌ ខេត្តត្រូវបានចាត់តាំងអោយប្រមូលចំណូលពន្ធតូចៗរីឯប្រភេទចំណូលពន្ធធំៗវិញ គឺមានចំនួនមន្ត្រីទទួលបន្ទុកនៅមានកម្រិតដែលបញ្ហាប្រឈមនេះ និងមានភាព ស្មុគស្មាញកាន់តែខ្លាំងនៅពេលមានការកែប្រែ ការប្រមូលពន្ធតាមរបបម៉ៅការទៅជារបបស្វ័យប្រកាសវិញការកើនឡើងអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងការកើនឡើងចំនួនសហគ្រាសថ្មី និង

(៣) ការធ្វើសនិទានកម្មលើរង្វាន់លើកទឹកចិត្តនាពេលបច្ចុប្បន្ន ដែលផ្តល់ជូនមន្ត្រីពន្ធដារគ្រប់រូបមិនបានបែងចែកកម្រិតនៃប្រាក់រង្វាន់ដោយផ្អែកលើលទ្ធផលការងាររបស់មន្ត្រីម្នាក់ៗនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុវត្តវិធានការរយៈពេលខ្លីដូចខាងក្រោម៖

- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស
- ធ្វើសនិទានកម្មរបបរង្វាន់លើកទឹកចិត្តត្រូវផ្អែកលើលទ្ធផលការងារជាមូលដ្ឋាន បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពន្ធដារគ្រគ្រប់កម្រិត និងកែលម្អកម្មវិធីសិក្សារបស់សាលាជាតិពន្ធដារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង

- ធ្វើការជ្រើសរើសមន្ត្រីពន្ធដារឱ្យបានឆាប់រហ័សស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាពពន្ធដារនីមួយៗ
- បញ្ចប់ការរៀបចំលក្ខខ័ណ្ឌការងារ និងការទទួលខុសត្រូវលើមុខងារនីមួយៗ ទម្រង់វាយតម្លៃលទ្ធផលការងាររបស់មន្ត្រីរាជការពន្ធដារតាមឋានានុក្រម
- បញ្ចប់សេចក្តីព្រាងស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងរៀបចំសេចក្តីណែនាំស្តីពីវិន័យ និង ការដាក់ទណ្ឌកម្មដែលបញ្ជាក់អំពីនីតិវិធីអនុវត្តច្បាស់លាស់
- រៀបចំបទដ្ឋានគោលការណ៍ឱ្យបានច្បាស់លាស់សម្រាប់ការផ្លាស់ប្តូរមន្ត្រី
- រៀបចំគម្រោងចំណាយថវិការបស់អង្គភាពពន្ធដារ ដើម្បីទទួលបានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់គាំទ្រការអនុវត្តការងារប្រមូលចំណូលពន្ធ និងការកែទម្រង់ពន្ធដារឱ្យមានប្រសិទ្ធភាព។

## ផ្នែកទី២៖ កំណែទម្រង់គោលនយោបាយសារពើពន្ធ

សម្រាប់បរិបទកម្ពុជាដែលមានការអភិវឌ្ឍន៍លឿនជាមួយនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមជាប្រចាំ និង បំណងប្រាថ្នាសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ តម្រូវអោយរដ្ឋាភិបាលគិតគូរលើទិដ្ឋភាពចំណូលសេដ្ឋកិច្ច សង្គម និងបរិស្ថានរយៈពេលវែងដើម្បីសម្រេចគោលដៅនេះរាជរដ្ឋាភិបាលនឹងសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ គោលបំណងនៃយុទ្ធសាស្ត្រគៀគរចំណូល២០១៩-២០២៣ ក៏បានចេញការធ្វើវិចារណកម្ម (Rationalization) លើគោលនយោបាយសារពើពន្ធសំដៅធានាសង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងប្រមូលចំណូលអោយអស់សក្តានុពលស្របទៅនឹងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សង្គមកម្ពុជាដោយប្រកាន់យកគោលការណ៍សាមញ្ញភាព តម្លាភាព ភាពប្រាកដប្រជាសមធម៌ និងប្រសិទ្ធភាព។

ដោយកំណែទម្រង់គោលនយោបាយសារពើពន្ធអាចធ្វើឡើងតាមរយៈ៖

-ការប្តូរអត្រាពន្ធ ការពង្រីកមូលដ្ឋានពន្ធ ការលើកលែងពន្ធ ការបង្កើតពន្ធថ្មី

-ការវិភាគព្យាករណ៍ចំណូលពន្ធ និងការរៀបចំយុទ្ធសាស្ត្រពន្ធដារ

-ការធ្វើអោយប្រព័ន្ធពន្ធដារ សាមញ្ញ សមធម៌ និងយុត្តិធម៌ ស្ថិរភាព តម្លាភាព ប្រសិទ្ធិភាពដោយបន្ថយចំណាយរបស់អ្នកជាប់ពន្ធ និងរបស់រដ្ឋបាលសារពើពន្ធ

-កាត់បន្ថយការគេចវេះ និងជៀសវាងពន្ធ

-ការពង្រឹងសមត្ថភាពរដ្ឋបាលសារពើពន្ធ និងការចុះកិច្ចព្រមព្រៀងពន្ធ

-ការធ្វើវិសោធនកម្មច្បាប់ស្តីពីសារពើរពន្ធ ច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ

-ការរៀបចំច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារបន្ថែមទៀត

## ២.១ ការរៀបចំច្បាប់ និងគោលនយោបាយសារពើពន្ធ[33]

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងគោលយោបាយសារពើពន្ធដែលបានរៀបចំដាក់ចេញខាងលើ(ការរៀបចំច្បាប់) តាមរយៈការធ្វើវិចារណកម្ម(rationalization) លើគោលយោបាយសារពើពន្ធ សំដៅលើសន្តិភាពជាមួយនឹងគោលយោបាយអភិវឌ្ឍជាតិជំរុញ និងតម្រង់ទិសការវិនិយោគលើកកំពស់ឧត្តមភាពក្នុងការប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និង ប្រមូលចំណូលអោយអស់សក្តានុពលស្របទៅតាមការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច-សង្គម កម្ពុជាដោយប្រកាន់យកគោលការណ៍ សាមញ្ញភាព តម្លាភាព ភាពប្រាកដប្រជា សមធម៌ និងប្រសិទ្ធភាព។ ដោយគោលការនៃការរៀបចំគោលនយោបាយសារពើពន្ធគឺស្របតាមយុទ្ធសាស្ត្រកៀគរចំណូល ២០១៩-២០២៣




វិធានគោលនយោបាលយសារពើពន្ធមានរយៈពេលខ្លី និងមធ្យមផ្អែកតាមគោលបំណងនៃយុទ្ធសាស្ត្រកៀគរចំណូល២០១៩-២០២៣បានដាក់ចេញនូវវិធានគោលនយោបាយសារពើពន្ធមានរយៈពេលខ្លី និងមធ្យមដើម្បីដោះស្រាយបញ្ហាប្រឈមទៅតាមប្រភេទពន្ធមានដូចជា៖

### ២.១.១ គោលនយោបាយអាករពិសេស[34]

ដែលមានគោលបំណងប្រមូលចំណូលពន្ធ កែប្រែឥរិយាបថអ្នកប្រើប្រាស់ និងការកាត់បន្ថយផលវិជ្ជាមាន (Negative externalities) ក្នុងការប្រើប្រាស់ផលិតផលដែលអាចប៉ះពាល់សុខភាព និងបរិស្ថានដូចជា៖ ភេសជ្ជៈ គ្រឿងស្រវឹង បារី ប្រេងឥន្ធនៈ រថយន្តនិងផលិតផលប្រណិតមួយចំនួន។ ដើម្បីអនុវត្តការប្រមូលអាករពិសេស រដ្ឋាភិបាលកម្ពុជាបានដាក់ចេញអនុក្រឹត្យចំនួន១៣ និងប្រកាស១៥ជាបន្តបន្ទាប់ ជាពិសេសអាករពិសេសលើមុខទំនិញសំខាន់ៗដូចជាយានយន្ត ភេសជ្ជៈ និងបារី។

[33] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ២១)

[34] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ២១)

### ២.១.២ ពន្ធលើអចលនទ្រព្យ[35]

គោលនយោបាយលើអចលនទ្រព្យមានគោលបំណងធានានូវសមធម៌ បង្កើនប្រសិទ្ធភាពទៅលើការប្រើប្រាស់អចលនទ្រព្យ និងប្រមូលចំណូលសម្រាប់អភិវឌ្ឍមូលដ្ឋាន ហើយបច្ចុប្បន្នប្រទេសកម្ពុជាអនុវត្តពន្ធបីប្រភេទលើអចលនទ្រព្យគឺៈ(១) ពន្ធលើអចលនទ្រព្យ មានអាត្រា ០,១%, (២) ពន្ធលើដីធ្លីមិនបានប្រើប្រាស់មានអត្រា ២%, និង (៣) ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ (Property Transfer Tax) ដែលមានអត្រា៤%។ ម្យ៉ាងវិញទៀតការអនុវត្តន៍ពន្ធទាំងបីប្រភេទនេះក៏សំដៅលើកកំពស់វប្បធម៌បង់ពន្ធរបស់ពលរដ្ឋ និង ជំរុញអោយមានការវិនិយោគលើដីទំនេរ។

### ២.១.៣ អាករលើតម្លៃបន្ថែម[36]

ចាប់តាំងពីការដាក់អនុវត្តអាករលើតម្លៃបន្ថែមនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៩ប្រភេទពន្ធនេះបានក្លាយជាប្រភពចំណូលដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណូលអាករលើតម្លៃបន្ថែមមានកំណើនមធ្យម ១៦% ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨។ ប្រទេសកម្ពុជាអនុវត្តអត្រាអាករលើតម្លៃបន្ថែម ១០% លើទំនិញនិងសេវាភាគច្រើនដែលប្រហាក់ប្រហែលប្រទេសក្នុងអាស៊ាន លើកលែងតែប្រទេសថៃ សិង្ហបុរី និងម៉ាឡេស៊ី ដែលមានអត្រាទាបជាងនេះ។ ដែលការអនុវត្តនេះស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ ក៏ដូចជាជួយពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលចំណូល។ ការអនុវត្តអាករលើតម្លៃបន្ថែមក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅមិនទាន់បានគិតគូរគ្រប់ជ្រុងជ្រោយលើប្រភេទទំនិញចាំបាច់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ក៏ដូចជាមុខទំនិញជាធាតុចូលសម្រាប់គាំទ្រផលិតកម្មក្នុងវិស័យអាទិភាព។ កន្លងមកអាករលើតម្លៃបន្ថែមត្រូវបានចាត់ជាបន្ទុករបស់រដ្ឋលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋ ប៉ុន្តែមានចរិតជាវិធានការដោះស្រាយបញ្ហាតាមករណីជាក់ស្តែង ដែលទាមទារអោយមានការពិនិត្យឡើងវិញ។

ដើម្បីស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រគៀរចំណូល២០១៩-២០២៣ បានដាក់ចេញនូវវិធានការមួយចំនួនៈ

១.សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ ឬ បទបញ្ញត្តិដែលពាក់ពន្ធនឹងអាករលើតម្លៃបន្ថែមដោយផ្តោតលើវិក័យបត្រអាករ (Tax Invoice) និងវិក្កយបត្រតាមប្រព័ន្ធអេឡិចត្រូនិក (E-tax system) ព្រមទាំងសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើស និងបទ ប្បញ្ញត្តិស្តីពីពន្ធដារ។

---

[35] យុទ្ធសាស្ត្រគៀរចំណូល២០១៩_២០២៣(ទំព័រ២៣)

[36] យុទ្ធសាស្ត្រគៀរចំណូល២០១៩_២០២៣(ទំព័រ២៤)

២.ពិនិត្យឡើងវិញលើការលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

**២.១.៤ អាករសម្រាប់បំភ្លឺសាធារណៈ** [37]

ប្រទេសកម្ពុជាបានអនុវត្តអាករបំភ្លឺសាធារណៈ ៣%លើតម្លៃសុរាមេរ័យ និងបារី និងត្រូវកំណត់គ្រប់ដំណាក់កាលផ្គត់ផ្គង់នៅឆ្នាំ១៩៩៥។ ទន្ទឹមនេះ ប្រទេសមួយចំនួននៅអាស៊ីក៏អនុវត្តប្រភេទពន្ធប្រហាក់ប្រហែលនេះក្នុងគោលបំណងខុសគ្នាៗ ដូចជាប្រទេសថៃបានអនុវត្តពន្ធសុខភាព (health surtax) ប្រទេសកូរ៉េ បានអនុវត្តពន្ធអប់រំ និងសុខភាពសាធារណៈ(Education and Public Health Tax) និងតៃវ៉ាន់បានអនុវត្តពន្ធសុខភាព (Health tax) លើផលិតស្រា ស្រាបៀរ និងបារី។ ការអនុវត្តអារករសម្រាប់បំភ្លឺសាធាណៈគ្រប់ដំណាក់កាលផ្គត់ផ្គង់បានបង្កើតបន្ទុកអនុលោមភាពដល់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ។ នៅក្នុងឆ្នាំ២០១៨ មានការកំណត់យក ២០% នៃតម្លៃវិក្កយបត្រជាមូលដ្ឋានគិតពន្ធអាករសម្រប់បំភ្លឺសាធារណៈសម្រាប់ប្រតិបត្តិការចាប់ពីដំណាក់កាលទី២ ក៏ការកំណត់នេះនៅតែមិនឆ្លុះបញ្ចាំងពីកម្រិតប្រាក់ចំណូលជាក់ស្តែងដែលជាមូលដ្ឋានគិតពន្ធរបស់អ្នកជាប់ពន្ធអ្នកផ្គត់ផ្គង់បន្តអាចប៉ះពាល់ដល់ការប្រកួតប្រជែងទីផ្សារ។

ដើម្បីអាចដោះស្រាយនូវបញ្ហាខាងលើនេះយុទ្ធសាស្ត្រកៀរចំណូល ២០១៩-២០២៣ បានដាក់ចេញវិធានការរយៈពេលខ្លី៖ ត្រួតពិនិត្យលទ្ធភាពធ្វើការកែសម្រួលអាករសម្រាប់បំភ្លឺសាធារណៈ ដើម្បីបង្កើនអនុលោមភាពផ្តល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងបង្កើនប្រសិទ្ធនៃការប្រមូលពន្ធ។

**២.១.៥ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល** [38]

កម្ពុជាក៏បានប្រមូលចំណូលរូបវន្តបុគ្គលតាមរយៈពន្ធលើប្រាក់បៀវត្ស និង លើអត្ថប្រយោជន៍បន្ថែម ព្រមទាំងពន្ធលើប្រាក់ចំណូលពីប្រភពផ្សេងៗ ដូចជាពន្ធលើថ្លៃឈ្នួលផ្ទះ និងដី ការប្រាក់ ភាគលាភ និង សួយសារទៅតាមអត្រាផ្សេងៗគ្នា។ ប៉ុន្តែរាជរដ្ឋាភិបាលមិនទាន់បានប្រមូលពន្ធលើប្រាក់ចំណូលពីប្រភពផ្សេង ដូចជាចំណេញមូលធន (Capital gain) ដែលមិនសូវធានានូវសមធម៌ យុត្តិធម៌ព្រមទាំងបាត់បង់សក្តានុពលចំណូលពន្ធមួយចំនួន។ ហេតុនេះទើបរដ្ឋាភិបាលបានចេញវិធានការតាមរយៈពេលដូចខាងក្រោម៖

**១.វិធានការសម្រាប់រយៈពេលខ្លី២០១៩- ២០២០**

- កសាងក្របខណ្ឌគោលយោបាយ សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល
- ដាក់អោយអនុវត្តពន្ធលើចំណេញមូលធន (Capital gain)

[37] យុទ្ធសាស្ត្រគៀរចំណូល២០១៩_២០២៣(ទំព័រ២៥)

[38] យុទ្ធសាស្ត្រគៀរចំណូល២០១៩_២០២៣(ទំព័រ២៦)

**២.វិធានការរយៈពេលវែង២០២១-២០២៣**

•រៀបចំរដ្ឋបាលសារពើពន្ធដែលមានសមត្ថភាព និងឯកទេសសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលប្រកបដោយប្រសិទ្ធភាព។

**២.១.៦ ពន្ធលើពាណិជ្ជកម្មតាមប្រពន្ធ័អេឡិចត្រូនិក**[39]

ការរីកចំរើននៃបច្ចេកវិទ្យាក្នុងតំបន់ និងសកលលោក សេដ្ឋកិច្ចឌីជីថលនៅកម្ពុជាបាននឹងកំពុងតែលេចរូបរាងជាបណ្តើរៗ និងបានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗ ជាច្រើនតាមប្រព័ន្ធអេឡិចត្រូនិក។ នៅឆ្នាំ២០១៧ ពាណិជ្ជកម្មអេឡិចត្រូនិកសរុបនៅកម្ពុជា ដោយប្រើមធ្យោបាយទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានប៉ាន់ស្មានមានទំហំប្រមាណ១១២លានដុល្លារអាមេរិកដែលស្មើនឹង០,៥១%ផ.ស.ស។ ប្រទេសកម្ពុជាបានកំពុងតែរៀបចំក្របខ័ណ្ឌគតិយុត្តក្នុងការប្រមូលចំណូលពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយឆ្លងកាត់ព្រំដែនស្របពេលដែលប្រទេសជាច្រើននៅលើសកលលោក និងក្នុងសមាគមន៍អាស៊ាននៅពុំទាន់មានយន្ត ការរួមណាមួយក្នុងការប្រមូលចំណូលពីប្រភេទពាណិជ្ជកម្មនេះនោះទេ។ រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំប្រព័ន្ធអេកូឡូហ្ស៊ីដែលគាំទ្រ និង បង្កើតបរិស្ថានអំណោយផលសម្រាប់ធុរកិច្ចថ្មី (start-up)ដែលមានទាំងការវិនិយោគលើធនធានមនុស្ស និង បណ្តុះបណ្តាលជំនាញ រួមមានវិធានការរយៈពេលខ្លី (សិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តដើម្បីលើកកំពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក) និង វិធានការរយៈពេលវែង (សិក្សាពីលទ្ធភាពក្នុងការរៀបចំក្របខណ្ឌគតិយុត្តពាក់ព័ន្ធដើម្បីត្រៀមគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារ បាននឹងកំពុងអនុវត្តដោយចេញសេចក្តីប្រកាសណែនាំស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងកំណត់វិធាន និងនីតិវិធីអនុវត្តគ្រប់គ្រងការប្រមូលអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវា ឌីជីថលដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយអ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមអនុក្រឹត្យលេខ៦៥ អនក្រ.ប.ក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[40] ជាលទ្ធផលអគ្គនាយកដ្ឋានពន្ធដារអាចប្រមូលពន្ធអាករលើតម្លៃបន្ថែមតាមប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកពីបណ្តាក្រុមហ៊ុនយក្ស មួយចំនួនបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ មានដូចជា៖ ក្រុមហ៊ុនGoogle, Facebook, Youtube, និង Tik Tok ជាដើម។

[39] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ២៦)

[40] ប្រកាសនៃនាំស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ២.១.៧ វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ[41]

ដើម្បីធានាបាននូវអភិក្រមទាំងបួនក្នុងការរៀបចំយុទ្ធសាស្ត្រគៀគរចំណូល ២០១៩-២០២៣ ជាពិសេសលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាកាត់បន្ថយបន្ទុកធុរជន និងរដ្ឋបាលសារពើពន្ធបន្តការគាំទ្រការវិនិយោគក្នុងវិស័យអាទិភាព និង ជំរុញសកម្មភាពអាជីវកម្មគោលនយោបាយសារពើពន្ធពន្ធផ្សេងចាំបាច់ត្រួតពិនិត្យឡើងវិញដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនដូចជា៖

១.ការប្រមូលពន្ធមិនទាន់ពេញលេញលើអាជីវកម្មក្នុងបរិវេណកាស៊ីណូ ក្រៅពីអាជីវកម្មភ្នាល់

២.កម្រិតអប្បបរមាប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គលមានកម្រិតទាបមិនផ្តល់ការលើកទឹកចិត្តក្នុងការធ្វើអាជីវកម្ម

៣.ផលរបរប្រចាំឆ្នាំដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច មធ្យម និងធំ នៅមិនទាន់ឆ្លើយតបទៅនឹងកំណើនសកម្មភាពធុរកិច្ចជាក់ស្តែងដែលកត្តានេះបានបង្កើនបន្ទុកដល់រដ្ឋបាលថ្នាក់កណ្តាលក្នុងការគ្រប់គ្រងការកើនឡើងអ្នកជាប់ពន្ធធំ។

៤.ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ (២០%) ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) មិនបានលើកទឹកចិត្តជាក់ស្តែងដល់វិនិយោគិន

៥.មុខទំនិញនាំចូលដែលជាធាតុចូលសម្រាប់គាំទ្រវិស័យអាទិភាពដូចជាវិស័យកសិកម្ម អប់រំ និងការដឹកជញ្ជូននៅមិនទាន់ទទួលបានការលើកទឹកចិត្តពេញលេញ និង

៦. គោលនយោបាយសារពើពន្ធលើវិស័យហិរញ្ញវត្ថុ និងការអនុវត្តមិនមានសង្គតិភាព។

### ២.១.៨ ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ[42]

ការលើកទឹកចិត្តពន្ធក្នុងច្បាប់ស្តីពីវិនិយោគតនៃកម្ពុជា ដែលបានដាក់ឱ្យប្រើប្រាស់តាំងពីឆ្នាំ១៩៩៤ បានចូលរួមបង្កើតការងារ និងទាក់ទាញវិស័យដែលមានតម្លៃបន្ថែមទាបដូចជា វិស័យវាយនភណ្ឌ និងកាត់ដេរជាពិសេសផលិតកម្មស្បែកជើង វិស័យបង្គុំឧបករណ៍អេឡិចត្រូនិក និងវិស័យតម្លើងកង់ជាដើម ។ ប៉ុន្តែការលើកទឹកចិត្តពន្ធនាពេលបច្ចុប្បន្នពុំមានការផ្តល់ការលើកទឹកចិត្តដល់ការពង្រីកចង្វាក់ផលិតកម្មដែលមានស្រាប់ និងទាក់ទាញវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យអាទិភាពថ្មីនៅឡើយដែលតម្រូវឱ្យមានការគិតគូរឡើងវិញលើរបបលើកទឹកចិត្តពន្ធនេះ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច បរិយាកាសធុរកិច្ច និង ផ្សារ

[41] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ២៧)

[42] យុទ្ធសាស្ត្រគៀគរចំណូល២០១៩_២០២៣(ទំព័រ២៨)

ភ្ជាប់សហគ្រាសធុនតូច និង មធ្យមទៅនឹងចង្វាក់ផលិតកម្មគម្រោងវិនិយោគ។ ទន្ទឹមនេះការផ្តល់ការលើកទឹកចិត្តនៅមានភាពមិនស្មើគ្នារវាងគម្រោងវិនិយោគបម្រើទីផ្សារនាំចេញ គម្រោងវិនិយោគក្នុងឧស្សាហកម្មគាំទ្រ និងគម្រោងវិនិយោគបម្រើទីផ្សារក្នុងស្រុក។ បច្ចុប្បន្នវត្ថុធាតុដើមនាំចូលសម្រាប់គម្រោងវិនិយោគបម្រើទីផ្សារនាំចេញបានទទួលការលើកទឹកចិត្តដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋប៉ុន្តែសម្រាប់គម្រោងវិនិយោគបម្រើទីផ្សារក្នុងស្រុកពុំទទួលបានការលើកទឹកចិត្តខណៈដែលទីផ្សារក្នុងស្រុកបច្ចុប្បន្នមានទំហំកាន់តែធំ និង រាជរដ្ឋាភិបាលកំពុងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក ។

ជាក់ស្តែងក្នុងបរិបទបច្ចុប្បន្នរបបលើកទឹកចិត្តពន្ធរបស់កម្ពុជាមានគោលបំណងមិនច្បាស់លាស់ដោយវិសាលភាពនៃវិស័យអាទិភាពទូលំទូលាយការកំណត់នៃលក្ខន្តិកៈមួយចំនួននៅមិនទាន់ច្បាស់លាស់នីតិវិធី និងយន្តការស្នើសុំ និងផ្តល់ការលើកទឹកចិត្តមានភាពស្មុគស្មាញ កង្វះការត្រួតពិនិត្យទៅលើចំណាយថវិការដ្ឋនៃការលើកលែងពន្ធបទប្បញ្ញត្តិនៃការលើកទឹកចិត្តពន្ធមិនស្ថិតក្រោមច្បាប់ស្តីពីសារពើពន្ធ ជាពិសេសកង្វះការលើកទឹកចិត្តពន្ធសម្រាប់ការពង្រីកទុនវិនិយោគ ឬចង្វាក់ផលិតកម្ម និង ការលើកទឹកចិត្តពន្ធដែលទាក់ទាញឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់ ។ ដើម្បីកែសម្រួលការលើកទឹកចិត្តពន្ធឱ្យសមស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិបទសេដ្ឋកិច្ចបច្ចុប្បន្នរបស់កម្ពុជា រាជរដ្ឋាភិបាលបានអនុម័តជាគោលការណ៍ឱ្យរៀបចំយកជំពូកស្តីពីការលើកទឹកចិត្តវិនិយោគចេញពីច្បាប់ស្តីពីវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស មកដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ហើយរៀបចំជាអនុក្រឹត្យរាជរដ្ឋាភិបាលសម្រាប់ការអនុវត្ត ដើម្បីផ្តល់ភាពទន់ភ្លន់ក្នុងការផ្លាស់ប្តូរគោលនយោបាយ សម្រាប់លើកទឹកចិត្តទៅលើវិស័យអាទិភាពនានា ឱ្យបានឆាប់រហ័សតាមសេចក្តីត្រូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាតទៅមុខទៀត ។ ក្នុងក្របខ័ណ្ឌនេះការកំណត់វិស័យអាទិភាពត្រូវទទួលបានការលើកទឹកចិត្ត និងជាកម្មវត្ថុនៃការពិភាក្សាក្នុងចំណោមក្រសួងស្ថាប័នពាក់ព័ន្ធនៅក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.១.៩ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម[43]

សហគ្រាសធុនតូច និងមធ្យម ជាឆ្អឹងខ្នងសេដ្ឋកិច្ច និងជាកម្លាំងចលករដ៏ខ្លាំងមួយក្នុងការជំរុញកំណើន និងបង្កើតការងារសម្រាប់ប្រជាជន ។ ដោយសារទំហំនៃការវិនិយោគតូច និង ភាគច្រើនគឺដើម្បីបម្រើសេចក្តីត្រូវការក្នុងស្រុកសហគ្រាសធុនតូច និងមធ្យមទាំងនៅកម្ពុជា និងនៅប្រទេសដ៏ទៃទៀតតែងតែជួបប្រទះនូវបញ្ហាជាច្រើន។ ដោយយល់ច្បាស់អំពីសារៈសំខាន់របស់សហគ្រាសធុនតូច និងមធ្យមរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាកញ្ចប់ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមពង្រឹងភាព

[43] យុទ្ធសាស្ត្រគៀតរចំណុលល២០១៩_២០២៣(ទំព័រ២៩)

ប្រកួតប្រជែង និងបង្កើនសមត្ថភាពផលិតកម្ម។ អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យមក៏ទទួលបាននូវការលើកទឹកចិត្ត។ វិស័យអាទិភាពដែលទទួលបាននូវការលើកទឹកចិត្តមានដូចខាងក្រោមៈ

១- សហគ្រាសផលិត និងផ្គត់ផ្គង់ទឹកស្អាត

២- ផលិតកម្មកសិកម្ម ឬ កសិឧស្សាហកម្ម

៣- ផលិតកម្មផលិត និងកែច្នៃម្ហូបអាហារ

៤- កម្មន្តសាលផលិតទំនិញបម្រើឱ្យការនាំចេញ

៥- កម្មន្តសាលផលិតទំនិញប្រើប្រាស់ក្នុងស្រុក កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍

៦- កម្មន្តសាលផលិតនូវផលិតផលសម្រេច ឬផលិតផលពាក់កណ្តាលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត។

៧- ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍

៨- អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម

### ២.១.១០ ការរៀបចំប្រព័ន្ធសារពើពន្ធ

គោលនយោបាយសារពើពន្ធដែលបានរៀបរាប់ខាងលើគឺភាគច្រើនសម្រាប់តែរយៈពេល៥ឆ្នាំទៅមុខ។ សម្រាប់បរិបទកម្ពុជាដែលមានការអភិវឌ្ឍលឿនជាមួយនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមជាប្រចាំ និងបំណងប្រាថ្នាសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ក្លាយជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ តម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការគិតគូរគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពចំណូលសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងរយៈពេលវែង។ ដើម្បីសម្រេចបាននូវគោលដៅនេះរាជរដ្ឋាភិបាលនឹងសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជាអោយកាន់តែប្រសើរឡើងថែមទៀត។[44]

## ២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា គឺជាកិច្ចព្រមព្រៀងទ្វេភាគីមានភាពស្មុគស្មាញដែលធ្វើឡើងក្នុងគោលដៅមួយចំនួនរួមមាន :

១- លុបចោលនូវរបាំងពន្ធសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគ ឆ្លងប្រទេស

២- លុបចោល ឬបន្ថយការយកពន្ធត្រួតគ្នាទៅលើនិវាសនជន ដែលមាននិវាសនដ្ឋាននៅក្នុងប្រទេស

៣- ទប់ស្កាត់ និងប្រឆាំងអំពើចៀសវាងពន្ធ និងគេចវេសពន្ធ

[44] យុទ្ធសាស្ត្រគៀរចំណូល២០១៩_២០២៣(ទំព័រ៣០)

៤- បង្កើតយន្តការដោះស្រាយជម្លោះដែលកើតឡើងដោយការបង់ពន្ធត្រួតគ្នា

៥- ធ្វើឱ្យមានភាពប្រាកដប្រជាក្នុងការបង់ពន្ធ

៦- ធ្វើឱ្យមានការកាត់បន្ថយមូលដ្ឋានពន្ធ និងអត្រាពន្ធមួយចំនួន

៧- ធ្វើឱ្យមានការថយចុះចំណាយដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធ

៨- លើកទឹកចិត្តឱ្យមានការហូរចូលការវិនិយោគបរទេស

៩- ផ្លាស់ប្តូរព័ត៌មានរវាងប្រទេសចុះកិច្ចព្រមព្រៀង និង

១០- បែងចែក និងកំណត់សិទ្ធិ និងអធិបតេយ្យភាពយកពន្ធរវាងប្រទេសដែលចុះកិច្ចព្រមព្រៀង។ល។

បច្ចុប្បន្ននេះប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសមួយចំនួនដូចខាងក្រោម៖

- **ប្រទេសសិង្ហបុរី**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលកិច្ចព្រមព្រៀងនេះ បានចុះហត្ថលេខានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ និងប្រកាសអោយប្រើនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១៧។

វិសាលភាព នៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស

**ខ. សម្រាប់សិង្ហបុរី៖**

(១) ពន្ធលើប្រាក់ចំណូល

យើងឃើញថានៅក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុវត្តផងដែរចំពោះប្រភេទពន្ធណាដែលមានចរិតលក្ខណៈដូចគ្នាសុទ្ធសាធ ឬ ប្រហាក់ប្រហែលគ្នាដែលបានដាក់ឱ្យអនុវត្តក្រោយកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះដោយបន្ថែមឬជំនួសឱ្យប្រភេទពន្ធជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗត្រូវជូនដំណឹងគ្នាទៅវិញទៅមកនូវរាល់ការធ្វើវិសោធនកម្មសំខាន់ៗលើច្បាប់ស្តីពីសារពើពន្ធរបស់ខ្លួន។

- **រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង ការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ និងប្រកាសអោយប្រើនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៧។

វិសាលភាពនៃ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬ អាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបពន្ធលើប្រាក់ចំណេញដែលសម្រេចបានមកពីការលក់ ឬ ផ្ទេរចលន ឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬ ប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធអប្បបរមាឡើយ

**ខ. សម្រាប់ចិន៖**

(១) ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល

(២) ពន្ធចំណូលលើសហគ្រាស

- **រដ្ឋាភិបាលនៃប្រទេសថៃ**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង ការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ និងប្រកាសអោយប្រើនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៧។

វិសាលភាព នៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រម ព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស

**ខ. សម្រាប់ថៃ៖**

(១) ពន្ធលើប្រាក់ចំណូល

(២) ពន្ធចំណូលប្រេងកាត

➢ **រដ្ឋាភិបាលនៃប្រទេសប្រទេសប៊្រុយណេដារុយសាឡឹម**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃព្រះមហាក្សត្រស៊ុលតង់ និងយ៉ាងឌីពើរតួន នៃប្រទេសប៊្រុយណេដារុយសាឡឹមស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសអោយប្រើនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៧។

វិសាលភាពនៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស

**ខ. សម្រាប់ប្រុយណេដារុយសាឡឹម៖**

(១) ពន្ធលើចំណូល ដែលអនុវត្តអោយប្រើក្រោមច្បាប់ស្តីពីពន្ធលើចំណូល(ជំពូក៣៥) និង

(២) ពន្ធលើប្រាក់ចំណេញពីប្រេងកាតដែលដាក់អោយអនុវត្តក្រោមច្បាប់ស្តីពីពន្ធលើចំណូលប្រេងកាត (ជំពូក១១៩)

➢ **រដ្ឋាភិបាលនៃប្រទេសប្រទេសឥណ្ឌូនេស៊ី**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង ការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ និងរដ្ឋធានីហ្សាកាតា ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ និងប្រកាសអោយប្រើនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

វិសាលភាព នៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធអប្បបរមាឡើយ

**ខ. សម្រាប់ប្រទេសឥណ្ឌូនេស៊ី៖**

(១) ពន្ធលើចំណូល

➢ **រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រទេសវៀតណាមស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៨ និងប្រកាសអោយប្រើនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៨។

វិសាលភាពពន្ធកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬ ផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬ ប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្សគ្មានបញ្ញត្តិណានៃកិច្ចព្រមព្រៀងនេះអាចរារាំងការអនុវត្តពន្ធអប្បបរមាឡើយ

**ខ. សម្រាប់ប្រទេសវៀតណាម៖**

(១) ពន្ធលើចំណូល រូបវន្តបុគ្គល

(២) ពន្ធលើចំណូលអាជីវកម្ម និង

(៣) ពន្ធបន្ថែមលើចំណូលពីប្រេងកាត

- **រដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសអោយប្រើនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩។

វិសាលភាពនៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំង

បណ្តាពន្ធលើប្រាក់ចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធអប្បបរមាឡើយ

**ខ. សម្រាប់រដ្ឋបាលពិសេសហុងកុង៖**

(១) ពន្ធលើចំណូល

(២) ពន្ធលើប្រាក់បៀវត្ស និង

(៣) ពន្ធលើអចលនទ្រព្យ ដោយមិនគិតពីការអនុគ្រោះពន្ធរបស់បុគ្គល

➢ **រដ្ឋាភិបាលនៃរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ី ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ និងប្រកាសអោយប្រើនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។

វិសាលភាពនៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើប្រាក់ចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធ អប្បបរមាឡើយ

**ខ. សម្រាប់ប្រទេសម៉ាឡេស៊ី**

(១) ពន្ធលើចំណូល

(២) ពន្ធលើចំណូលប្រេងកាត

- **រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ**

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃ សាធារណរដ្ឋកូរ៉េ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ។ កិច្ចព្រមព្រៀងនេះបានចុះហត្ថលេខានៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ និង ប្រកាសអោយប្រើនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០។

វិសាលភាពនៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។ ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬ ចំណែកនៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម៖

**ក. សម្រាប់កម្ពុជា៖**

(១) ពន្ធលើប្រាក់ចំណេញរួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(២) ពន្ធលើប្រាក់បៀវត្ស គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធអប្បបរមាឡើយ

**ខ. សម្រាប់ប្រទេសម៉ាឡេស៊ី**

(១) ពន្ធលើប្រាក់ចំណូល

(២) ពន្ធសាជីវកម្ម

(៣) ពន្ធពិសេសសម្រាប់អភិវឌ្ឍន៍ជនបទ និង

(៤) ពន្ធប្រាក់ចំណូលតាមមូលដ្ឋាន

គិតត្រឹមឆ្នាំ ២០២០ ប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ ចំនួន ៩ ប្រទេសរួចមកហើយ។ ទាំងនេះគឺជាលទ្ធផលដែលល្អដែលរដ្ឋាភិបាលបានសម្រេចបាន

តាមរយៈការដាក់ ចេញនូវយុត្តិសាស្ត្រគៀរគរចំណូល រយៈពេលមធ្យម២០១៤-២០១៨ និងបន្តជំហ៊ានទៅមុខទៀត ដោយការដាក់ចេញ នូវយុទ្ធសាស្ត្រគៀរគរចំណូល២០១៩-២០២០។ និងមាន៦ ប្រទេសទៀតកំពុងចរចារ កិច្ចព្រមព្រៀងDTA (Double Tax of Agreements)ជាបន្តបន្ទាប់ មានដូចជា៖ ប្រទេសរដ្ឋបាលពិសេសម៉ាកាវ ប្រទេសមីយ៉ាន់ម៉ា ប្រទេសហ្វីលីពីន ប្រទេសឡាវ ប្រទេសជប៉ុន ប្រទេសស្លូវ៉ាក។

# សេចក្តីសន្និដ្ឋាន
# និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **"ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា"** រួចមកក្រុមរបស់យើងខ្ញុំ សង្កេតឃើញថាវិស័យពន្ធដារពិតជាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ប្រទេសជាតិទោះជាវប្បធម៌បង់ពន្ធសម្រាប់ប្រជាជនកម្ពុជា ហាក់ដូចនៅមានកម្រិត នៅឡើយនេះបើប្រៀបធៀបជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក។ តែទោះជាយ៉ាងណាក៏ដោយក្នុងរយៈពេលជាង៥ឆ្នាំចុងក្រោយនេះតាមរយៈការប្រជុំបូកសរុបលទ្ធផលប្រចាំឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានពន្ធដារយើងឃើញពីកំណើននៃការប្រមូលពន្ធមានការកើនឡើងជាប្រចាំគួរអោយកត់ សម្គាល់ប្រជាពលរដ្ឋក៏ដូចជាអ្នកជាប់ពន្ធនានាមានការយល់ដឹង និងទទួលស្គាល់នូវកាតព្វកិច្ចចំពោះការបង់ពន្ធជូនរដ្ឋនៃព្រះរាជា ណាចក្រកម្ពុជា។

តាមរយៈការធ្វើកំណែទម្រង់រដ្ឋបាលសារពើពន្ធ និងគោលនយោបាយនេះជាលទ្ធផលបើប្រៀបធៀបនៅក្នុងមុខងារប្រត្តិបត្តិការស្នូល ការចុះបញ្ជីអ្នកជាប់ពន្ធយើងឃើញថាមានភាពងាយស្រួល ក្នុងការចុះបញ្ជីមានប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ មានកត់ត្រាពត៌មានច្បាស់លាស់ កន្លែងផ្តល់សេវាមានស្តង់ដារ និងមានក្រុមការងារចុះអង្កេតសហគ្រាសផងដែរ។ រីឯមុខងារស្នូលនៃការផ្តល់សេវា យើងឃើញមានការផ្សព្វផ្សាយទូលំទូលាយ មានសៀវភៅ ប្រព័ន្ធបណ្តាញសង្គមនានា មានសិក្ខាសាលា មានប្រព័ន្ធផ្តល់សេវានៃការរងចាំទទួល និងតាមដានឯកសារ មានភាពងាយស្រួល និងច្បាស់លាស់ដោយមានបង្កើតកម្មវិធីនានាក្នុងការឆ្លើយតប និងជជែកជាមួយពន្ធដារតាមរយៈទូរស័ព្ទដៃ និងការបង់ពន្ធតាមធនាគារជាដៃគូជាដើម។ ចំពោះមុខងារស្នូលនៃការចាត់ចែងលិខិតប្រកាសវិញ ក្នុងដំណើរការនៃការដាក់លិខិតប្រកាសត្រូវបានកាត់បន្ថយរយៈពេល និងបង្ករភាពងាយស្រួលយ៉ាងខ្លាំងចំពោះអ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធក្នុងការប្រមូលលិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំដោយ បានប្រើប្រាស់ប្រព័ន្ធ និងមុខងារ E-Filling E-payment ដែលចំនេញពេល និងគ្រប់គ្រងទិន្នន័យបានយ៉ាងច្បាស់លាស់។ រីឯការធ្វើសវនកម្មវិញមានទម្រង់បែបបទរវាងនាយកដ្ឋាន និងសាខាខណ្ឌខេត្ត ស្តង់ដារតែមួយ ហើយការគ្រប់គ្រងការធ្វើសវនកម្មមានប្រព័ន្ធគ្រប់គ្រងច្បាស់លាស់។ និងមានប្រព័ន្ធគ្រប់គ្រងបំណុលពន្ធអាចបង់ប្រាក់ពន្ធជាដំណាក់កាល និងបង់ផ្តាច់ មានគណៈកម្មការដោះស្រាយវិវាទសារពើពន្ធ(កម្រិតសហវ៉ក) និងមានក្រុមការងារទារបំណុលពន្ធព្រមទាំងមានវិធានតឹងទារនានា។ ចំពោះមុខងារគាំទ្ររចនាសម្ព័ន្ធ និងការគ្រប់គ្រងធនធានមនុស្សមានការរីកចម្រើនគួរអោយកត់សម្គាល់ដោយការធ្វើបច្ចុប្បន្នភាពក៏ដូចជាការបង្កើតប្រព័ន្ធយើងឃើញថាមានការរីកចម្រើន និងមានមន្ត្រីដែលមានសមត្ថភាពមានជំនាញជាច្រើនត្រូវបានជ្រើសរើស ដែលពង្រឹង និងសម្រួលដល់មុខងារប្រត្តិបត្តិការស្នូលយ៉ាងខ្លាំង។

ដោយឡែកទោះបីជាការធ្វើទំនើបកម្ម និងការដាក់ឱ្យអនុវត្តការផ្តល់សេវាតាមបច្ចេកវិទ្យាជាច្រើនរួចមក ហើយក៏ដោយក៏យើងសង្កេតឃើញថាអ្នកជាប់ពន្ធ និងសាធារណជនមួយចំនួននៅតែមិនទាន់អាចចាប់យកនូវសេវាឌីជីថលទាំងនោះនៅឡើយ ដោយសារចំណេះដឹងផ្នែកបច្ចេកវិទ្យានៅមានកម្រិតសម្រាប់ប្រជាជនកម្ពុជា។

ដូច្នេះដើម្បីបន្តបង្កើនសន្ទស្សន៍ និងនិរន្តរភាពនៃការប្រមូលចំណូលពន្ធឱ្យស្របតាម ការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិកាជាតិសម្រាប់បន្តអភិវឌ្ឍន៍ប្រទេស និងឆ្លើយតបទៅនឹងការកើនឡើងនៃបញ្ហាប្រឈមថ្មីៗ ដែលកើតចេញពីការវិវត្តនៃបរិយាកាសសេដ្ឋកិច្ចជាតិ និងអន្តរជាតិ អគ្គនាយកដ្ឋានពន្ធដារត្រូវតែបង្កើនការយកចិត្តទុកដាក់ និងខិតខំពុះពារបន្ថែមទៀតក្នុងការដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយគុណភាពដល់អ្នកជាប់ពន្ធនិងបង្ការការពារ និង ដោះស្រាយនូវរាល់បញ្ហាប្រឈម ក៏ដូចជាហានិភ័យនានាដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ការប្រមូលចំណូលពន្ធស្របតាមច្បាប់ថវិកា ព្រមទាំងវិវត្តខ្លួនជារដ្ឋបាលសារពើពន្ធដែលប្រមូលចំណូលពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាឌីជីថល សម្រាប់តាមការវិវត្តនៃសេដ្ឋកិច្ចសង្គមឌីជីថល។

# ការផ្តល់អនុសាសន៍

តាមរយៈការធ្វើកំនែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារដែលបានសម្រេចនូវលទ្ធផលការងារស្របទៅតាមផែនការដោយសម្រេចបានស្របតាមគោលនយោបាយ និង យុទ្ធសាស្ត្រនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។

តែទោះជាយ៉ាងណាក៏ដោយក៏យើងខ្ញុំនៅមានចំនុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

ដោយនៅក្នុងការពង្រឹងមុខងារប្រតិបត្តិការស្នូល ៖

-ការចុះបញ្ជីអ្នកជាប់ពន្ធ: ការអនុវត្តជួបផលវិបាកនៅឡើយ ដោយការចុះបញ្ជីមានលក្ខណៈ សាំញ៉ាំ ករណីការចុះបញ្ជីត្រូវបានបដិសេធអ្នកជាប់ពន្ធ ឬបុគ្គលដែលមានបំណងចង់ចុះបញ្ជីមិនបានដឹងពីនីតិវិធីនៃការស្នើសុំឡើងវិញ។

-ការផ្តល់សេវា: អកប្បកិរិយារបស់មន្ត្រីរដ្ឋបាលសារពើពន្ធមួយចំនួន នៅតែមិនទាន់មានភាពល្អប្រសើរក្នុងការផ្តល់សេវាដល់អ្នកជាប់ពន្ធ រីឯការបកស្រាយច្បាប់យើងឃើញថាមិនទាន់ស៊ីគ្នានៅឡើយ។

និងនៅក្នុងការពង្រឹងមុខងារគាំទ្រ ៖

-ប្រព័ន្ធបច្ចេកវិទ្យា : នៅមានចំនុចខ្វះខាត ការគ្រប់គ្រងប្រព័ន្ធដំណើរការមិនទាន់បានល្អប្រសើរបង្ករផលលំបាកដល់អ្នកជាប់ពន្ធ ត្រូវប្រឈមនឹងបញ្ហាផាកពិន័យពីការយឺតយ៉ាវដែលកើតឡើងពីការប្រើប្រាស់ប្រព័ន្ធ។

ដោយការផ្តល់សេវារបស់រដ្ឋបាលសារពើពន្ធពិតជាមានសារៈសំខាន់ខ្លាំងណាស់ មន្ត្រីដែលជាអ្នកផ្តល់សេវាសូមជួយអត់ធ្មត់ និងនែនាំដល់អ្នកជាប់ពន្ធអោយច្បាស់លាស់ពីឯកសារតម្រូវតាមស្តង់ដារតែមួយ។ និងព្យាយាមបកស្រាយពន្យល់ច្បាប់ និងប្រកាសនានារបស់ក្រសួងសេដ្ឋកិច្ចអោយស្របគ្នាដល់អ្នកជាប់ពន្ធ។ ដោយយើងខ្ញុំឃើញថាការអនុវត្តរបស់មន្ត្រីផ្តល់សេវាមានការពន្យល់តាមតែការយល់ឃើញរបស់ពួកគាត់ម្នាក់ៗ ដែលបង្កអោយមានភាពសាំញ៉ាំ ខាតពេលវេលា និងចំណាយច្រើនដល់អ្នកជាប់ពន្ធ។ រីឯប្រព័ន្ធបច្ចេកវិទ្យាពត៌មាន គួរបន្តអភិវឌ្ឍន៍សមត្ថភាព ក្នុងការគ្រប់គ្រងប្រព័ន្ធដោយដោះស្រាយធានាអោយបាននៃនិរន្តរភាពក្នុងប្រើប្រាស់ប្រព័ន្ធនិងសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធអោយបានល្អប្រសើរ។

ដូច្នេះហើយអគ្គនាយកដ្ឋានពន្ធដារត្រូវបន្តការកែទម្រង់ និង កែលម្អការផ្តល់សេវាតាមរយៈការប្រតិបត្តិលើមុខងារស្នូលដោយធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសារពើពន្ធពុំទាន់មានលក្ខណៈពេញលេញ និង គ្រប់ជ្រុងជ្រោយ ដែលអាចឆ្លើយតបទៅនឹងកំណើនតម្រូវការឥតឈប់ឈររបស់អ្នកជាប់ពន្ធក្នុង បរិការណ៍នៃការ វិវត្តសេដ្ឋកិច្ចសង្គមឌីជីថល។ ជាក់ស្តែងការផ្តល់សេវាដល់អ្នកជាប់ពន្ធនៅមានកម្រិតដែលតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តការកែទម្រង់ និង កែលម្អការផ្តល់សេវាតាមរយៈការប្រតិបត្តិលើមុខងារស្នូលឱ្យមានភាពសាមញ្ញ ងាយស្រួល និងប្រកបដោយប្រសិទ្ធិភាព ដើម្បីកាត់បន្ថយចំណាយ និងបង្កើនការពេញចិត្តរបស់អ្នកជាប់ពន្ធ។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

**បទបញ្ញត្តិច្បាប់**

-ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៥៧ ឆ្នាំ១៩៩៣

-ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧

-ច្បាប់ស្តីពីហរិញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

-ច្បាប់ លេខនស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ មីនា ២០០៣ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ

**អនុក្រឹត្យ**

-អនុក្រឹត្យលេខ ១១១ អនក្រ.បក ឆ្នាំ ២០០៥ ស្តីពីរបបលើកទឹកចិត្តពន្ធត្រូវបានកែសម្រួលតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគឆ្នាំ ២០០៣ ។

**ប្រកាស**

-ប្រកាសលេខ០០៩ ចុះថ្ងៃទី១២ ខែមករា ២០២១ស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាស លេខ ៥៤៣ សហវ ប្រក ចុះថ្ងៃទី៨ ខែកញ្ញា ២០២១ ស្តីពីពន្ធលើប្រាក់បៀវត្ស

-ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

-ប្រកាស លេខ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០

វិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ

**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

-លិខិតបទដ្ឋាន ស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ លេខ០០៧ សសរ.សហវ.ពដ ចេញថ្ងៃទី២៩ ធ្នូ ២០០៥

-ប្រកាសលេខ ៥០៧ សហវ.ប្រក ចុះថ្ងៃទី២៦ មេសា ២០១៧ស្តីពីការប្រមូលពន្ធប្រថាប់ត្រា

-ប្រកាសលេខ ៤៩៦ ថ្ងៃ ខែ ឆ្នាំ ស្តីពីការចុះបញ្ជីពន្ធដារ

**សៀវភៅឯកសារគតិយុត្តផ្សេងៗ**

-យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល

-យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល

-ឯកសារអង្គការតម្លាភាពកម្ពុជា

-នីតិពន្ធដារ ដោយលោកគ្រូ គង់ ប៊ុនធី

-សៀវភៅនៃនាំកាតព្វកិច្ច និងសិទ្ធិអ្នកជាប់ពន្ធបោះពុម្ពថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១០ដោយអគ្គនាយកដ្ឋានពន្ធដារ

-បទបង្ហាញស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធសមាគមសាលាត្រាជូ រៀបរៀងដោយលោកគ្រូ កើយ វិញគឿម

# បញ្ជីឧបសម្ព័ន្ធទី១

# ដ្យាក្រាមប្រៀបធៀបចំណូលពន្ធដារ

# ចាប់ពីឆ្នាំ២០១១ ដល់ ខែឧសភា ឆ្នាំ២០២២




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 3,036.32 | 3,604.89 | 4,267.99 | 5,210.00 | 6,010.48 | 7,906.52 | 8,791.66 | 11,277.32 | 11,700.52 | 11,266.79 | 6,994.06 |
| ចំណូល (លានដុល្លារ) | $590.01 | $759.08 | $901.22 | $1,067.00 | $1,302.00 | $1,502.62 | $1,976.64 | $2,197.85 | $2,819.33 | $2,889.02 | $2,781.92 | $1,726.93 |

© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា

នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

ត្រូវនឹងថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០១៩

## ជំពូកទី៦៖ ការត្រួតពិនិត្យ និងវាយតម្លៃ

៩២. ការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ទាមទារឱ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់មួយ ព្រមទាំងមានឆន្ទៈនយោបាយមោះមុត និងធនធានគ្រប់គ្រាន់ ដើម្បីតាមដានលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រនេះជាប្រចាំ ។

៩៣. ការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រនេះ នឹងប្រើប្រាស់យន្តការដែលមានស្រាប់គឺ÷(១)គណៈកម្មាធិការគោលនយោបាយសារពើពន្ធ, (២)គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និង (៣)គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ។

៩៤. គណៈកម្មាធិការគោលនយោបាយសារពើពន្ធ មានតួនាទី និងមុខងារត្រួតពិនិត្យ និងតាមដានលើការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះ ព្រមទាំងសម្របសម្រួល, ពិនិត្យ និងលើកសំណើកែសម្រួលគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍សមធម៌, សាមញ្ញភាព, តម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព ។

៩៥. គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ មានតួនាទីតាមដានការអនុវត្ត, ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ពាក់ព័ន្ធការប្រមូលចំណូលសារពើពន្ធ ព្រមទាំងជំរុញ និងផ្តល់ការណែនាំលើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលសារពើពន្ធឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលវេលា ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ។

៩៦. គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ មានតួនាទីតាមដានការអនុវត្ត, ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងជំរុញ និងផ្តល់ការណែនាំដល់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ លើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលវេលា ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ។

៩៧. អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីជាលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ ដែលនឹងរៀបចំក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃលម្អិត ដើម្បីធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការ និងសូចនាករសមិទ្ធកម្មគន្លឹះទាំងអស់ដែលបានដាក់ចេញ ព្រមទាំងរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំដាក់ជូនគណៈកម្មាធិការទាំង ៣ ។

៩៨. សូចនាករសមិទ្ធកម្មគន្លឹះរបស់វិធានការគោលនយោបាយសំខាន់ៗ ក៏ដូចជាសូចនាករសមិទ្ធកម្មគន្លឹះនៃវិធានការទំនើបភាវូបនីយកម្មរបស់រដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ខណៈដែល បន្ទាត់មូលដ្ឋាន និងគោលដៅនៃសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួនទៀត នឹងរៀបចំក្នុងក្របខ័ណ្ឌនិងដំណើរការត្រួតពិនិត្យ និងវាយតម្លៃលម្អិត ។

៩៩. ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រាល់ការស្នើសុំការផ្លាស់ប្តូរគោលនយោបាយសារពើ-ពន្ធត្រូវមានការពិភាក្សាកម្រិតបច្ចេកទេសជាមួយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍ និងអនុសាសន៍ជូនគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ។

១០០. ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការអនុវត្តវិធានការនានាដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះត្រូវរៀបចំ និងផ្តល់របាយការណ៍វឌ្ឍនភាព មកលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ រៀងរាល់ឆមាស ឬទៅតាមការស្នើសុំរបស់លេខាធិការដ្ឋាន ដើម្បីរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនគណៈកម្មាធិការទាំង ៣ បានទាន់ពេលវេលា ។ របាយការណ៍វឌ្ឍនភាពប្រចាំឆមាសត្រូវផ្ញើជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ យ៉ាងយូរត្រឹមដំណាច់ខែបន្ទាប់ ។

## ជំពូកទី៧÷ សេចក្តីសន្និដ្ឋាន

១០១. **យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣** នឹងក្លាយជាឧបករណ៍គោលនយោបាយក្នុងការគៀរគរចំណូលក្នុងស្រុក ដើម្បីគាំទ្រកិច្ចការកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នៅក្នុង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា** និង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាល ទី ៤** ដើម្បីធានានូវការសម្រេចបាននូវ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងពង្រឹងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរយៈពេលមធ្យម និងវែងរបស់កម្ពុជា ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងមានធនធានកាន់តែច្រើនក្នុងការអនុវត្តនូវគោលនយោបាយនានា សំដៅរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបចីរភាព, បង្កើតការងារជូនប្រជាជន តាមរយៈការកែលម្អបរិយាកាសវិនិយោគ និងការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន, បន្តកាត់បន្ថយភាពក្រីក្រ, បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ និងធានាសមធម៌សង្គម ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង និងបរិការណ៍ថ្មីរបស់កម្ពុជា ព្រមទាំងបន្តរក្សាបាននូវឯករាជ្យភាពនៃថវិកាជាតិ និងសេដ្ឋកិច្ច ។

១០២. ការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩ - ២០២៣ ទាមទារឱ្យមានឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជន ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាក្នុងគោលដៅសម្រេចបានចក្ខុវិស័យ, គោលបំណង, គោលដៅ និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់ ។ ទន្ទឹមនេះ ការអនុវត្តវិធានការដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះទាមទារឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថក្នុងការបំពេញកាតព្វកិច្ចបម្រើជាតិ ដោយត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" ។

## ឧបសម្ព័ន្ធ ១. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានពន្ធដារ

### ក .សូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវរាយការណ៍ជាប្រចាំ

| គោលបំណង | សូចនាករសមិទ្ធកម្មគន្លឹះ | រង្វាស់ | បន្ទាត់មូលដ្ឋាន ២០១៨ | គោលដៅប្រចាំឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| សេវាកម្ម និង អនុលោមភាព | ១ រយៈពេលមធ្យមនៃការបង្វិលសងអាករលើតម្លៃបន្ថែម ត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ | ចំនួនថ្ងៃធ្វើការ | ១២០ | ៣៧ | ៣៥ | ៣៣ | ៣១ | ៣០ |
| | ២ រយៈពេលមធ្យមនៃការបញ្ចប់សវនកម្មមានកម្រិត | ចំនួនថ្ងៃធ្វើការ | ៣៥ | ៣៣ | ៣០ | ២៨ | ២៥ | ២០ |
| | ៣ រយៈពេលមធ្យមនៃការបញ្ចប់សវនកម្មពេញលេញ | ចំនួនថ្ងៃធ្វើការ | ៣០ | ៣០ | ២៨ | ២៥ | ២៣ | ២០ |
| | ៤ អត្រាប្រកាសពន្ធទាន់ពេលវេលា | % នៃអ្នកជាប់ពន្ធពន្ធធំ និងមធ្យម | ៦៨% | កើនឡើង ២%រៀងរាល់ឆ្នាំ | | | | |
| | ៥ អត្រាបង់ពន្ធទាន់ពេលវេលា | % នៃអ្នកជាប់ពន្ធពន្ធធំ និងមធ្យម | ៧០% | កើនឡើង ២%រៀងរាល់ឆ្នាំ | | | | |

## ២ .សូចនាករសមិទ្ធកម្មគន្លឹះកម្រិតប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវរាយការណ៍ជាប្រចាំ

<table>
<tr><th rowspan="2">វិធានការទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ</th><th rowspan="2">សូចនាករសមិទ្ធកម្មគន្លឹះ</th><th rowspan="2">មូលដ្ឋាន ២០១៨</th><th colspan="5">គោលដៅ</th></tr>
<tr><th>២០១៩</th><th>២០២០</th><th>២០២១</th><th>២០២២</th><th>២០២៣</th></tr>
<tr><td colspan="8">យោងតាមគោលបំណង និងគោលដៅដូចដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលនឹងធ្វើការវាយតម្លៃសមិទ្ធកម្មការងារលើវិធានការដែលបានដាក់ចេញ តាមរយៈសូចនាករសមិទ្ធកម្មគន្លឹះដូចខាងក្រោម÷</td></tr>
<tr><td colspan="8">ក. ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច</td></tr>
<tr><td>• ដាក់ឱ្យអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតប្រតិបត្តិ-ការ ដើម្បីផ្តល់ភាពងាយស្រួលដល់ថ្នាក់ដឹកនាំ និងប្រធានអង្គភាពក្នុងការគ្រប់គ្រងជាយុទ្ធសាស្ត្រ និងវាយតម្លៃសមិទ្ធកម្ម (outcome)</td><td>របាយការណ៍ស្តីពីការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះកម្រិតប្រតិបត្តិការ និងកម្រិតយុទ្ធសាស្ត្រ</td><td>គ្មាន</td><td colspan="5">រៀងរាល់ឆមាស</td></tr>
<tr><td rowspan="2">• រៀបចំផែនការពង្រឹងសមត្ថភាព, ការធ្វើវិមជ្ឈការមុខងារ និងការទទួលខុសត្រូវ ដល់សាខាខេត្ត-ខណ្ឌ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តមុខងារស្នូល<br>• ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីធានាតម្លាភាព និងគណនេយ្យភាព អភិបាលកិច្ចផ្ទៃក្នុង</td><td>ផែនការពង្រឹងសមត្ថភាព, ការធ្វើវិមជ្ឈការមុខងារ និងការទទួលខុសត្រូវដល់សាខាខេត្ត-ខណ្ឌ ត្រូវបានរៀបចំ</td><td>គ្មាន</td><td></td><td>√</td><td></td><td></td><td></td></tr>
<tr><td>ចំនួនអង្គភាពដែលមានប្រើប្រាស់នីតិវិធីប្រតិបត្តិការស្តង់ដារ (standard operational procedure)</td><td>១</td><td colspan="5">កើនយ៉ាងតិច ១ ក្នុងមួយឆ្នាំ</td></tr>
</table>

| | | | | | | | |
|---|---|---|---|---|---|---|---|
| • ពង្រឹង និងពង្រីកការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅដល់គ្រប់នាយកដ្ឋាន និងសាខាខេត្ត-ខណ្ឌ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពប្រតិបត្តិការប្រចាំថ្ងៃ | ចំនួនការិយាល័យក្នុង អ.ព.ដ. ដែលប្រើប្រាស់ប្រព័ន្ធចែករំលែកទិន្នន័យបែបអេឡិចត្រូនិក (real-time data sharing system) | គ្រប់ការិយាល័យទាំងអស់ | √ | | | | |
| • ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ<br>• ពង្រឹងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូល និងចែករំលែកទិន្នន័យ និងព័ត៌មាន | ប្រព័ន្ធចែករំលែកទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក-ដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានគោលនយោបាយត្រូវបានតភ្ជាប់ | គ្មាន | | √ | | | |
| • ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យប្រភពចំណូល ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (business cycle) | ឯកសារវិភាគហានិភ័យទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ | សេចក្តីព្រាងឯកសារ | √ | √ | √ | √ | √ |
| • កសាង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យដំណើរការប្រតិបត្តិការស្វ័យទាន់ពេលវេលា ដើម្បីពង្រឹងប្រសិទ្ធភាពតាមដានវឌ្ឍនភាពស្ទូចនាករសមិទ្ធកម្មគន្លឹះ | ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដំណើរការប្រតិបត្តិ-ការស្វ័យទាន់ពេលវេលាត្រូវបានដាក់ឱ្យដំណើរការ | គ្មាន | | | √ | √ | √ |
| **ខ. មុខងារប្រតិបត្តិការស្នូល** | | | | | | | |
| • ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់នូវ (១) ប្រព័ន្ធ អនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃ | ភាគរយនៃករណីបង្វិលសងដោយជោគជ័យក្នុងការទទួលបានការបង្វិលសងអាករលើតម្លៃបន្ថែម | គ្មាន | កើនឡើងជារៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បន្ថែម និង (២) ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩, | របាយការណ៍វឌ្ឍនភាពនៃការអនុវត្តប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ. ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩ (ដោយបញ្ជាក់ពីសមិទ្ធផលការងារដែលឆ្លើយតបនឹងគោលបំណងនៃប្រកាសនេះ) | គ្មាន | របាយការណ៍វឌ្ឍនភាពជារៀងរាល់ឆ្នាំ | | | | |
| • រៀបចំ និងអនុវត្តផែនការរៀបចំឡើងវិញនូវដំណើរការការងារ (business process re-engineering) និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយរលូន | ឯកសារស្តីពីដំណើរការការងារនៃមុខងារស្នូល និងមុខងារគាំទ្រនីមួយៗ ទាំងមុន និងក្រោយប្រើ-ប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ | គ្មាន | | √ | | | |
| | ផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័នត្រូវបានដាក់ឱ្យអនុវត្ត | គ្មាន | | √ | | | |
| • ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្មរួម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ<br>• ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើន សមត្ថភាពធ្វើសវនកម្មសំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ | ភាគរយនៃសហគ្រាសដែលត្រូវបានធ្វើសវនកម្មធៀបនឹងផែនការសវនកម្ម | ៥០% | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសស្នើសុំបិទអាជីវកម្មដែលត្រូវបានធ្វើសវនកម្ម | ៣៥% | កើនឡើង ៣% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសស្នើសុំជម្រះបញ្ជីពន្ធដែលត្រូវបានធ្វើសវនកម្ម | ៦០% | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • ពង្រឹងការធ្វើសវនកម្មដោយផ្អែកលើហានិភ័យ (risk-based audit) | ចំនួនករណីសវនកម្មជាមធ្យមក្នុងសវនករម្នាក់ក្នុងមួយឆ្នាំ | ១១ | មិនលើស ១២ | | | | |
| | រយៈពេលមធ្យមនៃសវនកម្មពេញលេញអ្នកជាប់ពន្ធមធ្យម/ ធំ | ៣៥ ថ្ងៃ | ៣៥ | ៣០ | ៣០ | ២៥ | ២០ |
| | រយៈពេលមធ្យមនៃសវនកម្មមានកម្រិតអ្នកជាប់ពន្ធមធ្យម/ ធំ | ៣០ ថ្ងៃ | ៣០ | ៣០ | ២៥ | ២៥ | ២០ |
| | ភាគរយជាមធ្យមនៃករណីកំណត់ពន្ធឡើងវិញដែលត្រូវបានប្តឹងតវ៉ា ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីអ្នកជាប់ពន្ធទទួលលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ | ៣០% | | | | | |
| | ចំនួនករណីស៊ើបអង្កេតដែលបានបញ្ចប់ | ២៥ | ៤០ | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | |
| | រយៈពេលមធ្យមនៃការបញ្ចប់ការស៊ើបអង្កេត | ១២ខែ | ១២ | ១២ | ១១ | ១០ | ១០ |
| • រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមាន លក្ខណៈនវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកជាប់ពន្ធ | រយៈពេលមធ្យមនៃការបង្វិលសងអាករលើតម្លៃបន្ថែមត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ | ១២០ | ៣៧ | ៣៥ | ៣៣ | ៣១ | ៣០ |
| | លទ្ធផលនៃការស្ទង់មតិស្តីពីការពេញចិត្តចំពោះការផ្តល់សេវាដល់អ្នកជាប់ពន្ធរៀងរាល់ ០២ឆ្នាំម្តង | គ្មាន | | √ | | √ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រយៈពេលដែលអ្នកជាប់ពន្ធរង់ចាំក្នុងការទទួលបានការពិគ្រោះយោបល់ និងឆ្លើយបំភ្លឺពី អពដ (លាយលក្ខណ៍អក្សរ, call centre, live chat, SMS, បញ្ជរពិគ្រោះយោបល់ និងប្រអប់ទទួលមតិយោបល់) | ៣០ថ្ងៃ សម្រាប់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ | ៣០ | ២៩ | ២៨ | ២៧ | ២៥ |
| • អនុវត្តការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា, | ភាគរយនៃសហគ្រាស ដែលត្រូវចុះបញ្ជីតាមលទ្ធផលអង្កេតសហគ្រាស | ២០% | ឱ្យបាន ២០% ក្នុងមួយឆ្នាំ ធៀបនឹងលទ្ធផលអង្កេត | | | | |
| | ភាគរយនៃក្រុមហ៊ុនចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក | គ្មាន | កើនឡើង ២% ក្នុងមួយឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបានធ្វើបច្ចុប្បន្នភាពដោយជោគជ័យ ធៀបជាមួយចំនួនសហគ្រាសដែលបានស្នើសុំក្នុងឆ្នាំ | ៧០% | ៧០% | ៧០% | ៨០% | ៨០% | ៩០% |
| | ភាគរយនៃសហគ្រាសដែលបានដាក់លិខិតប្រកាស | ៧៥% | កើនឡើង ១% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលដាក់លិខិតប្រកាសតាមប្រព័ន្ធអេឡិចត្រូចនិក (e-filing) | គ្មាន | កើនឡើង ២% ក្នុងមួយឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ចំនួនសហគ្រាសដែលបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) | ១៣១ | កើនឡើង ៥០% ក្នុងមួយឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលដាក់លិខិតប្រកាសទាន់ពេលវេលាសម្រាប់អ្នកជាប់ពន្ធធំ និងមធ្យម | ៦៨% | កើនឡើង ២% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបង់ប្រាក់ពន្ធទាន់ពេលវេលាសម្រាប់អ្នកជាប់ពន្ធធំ និងមធ្យម | ៧០% | កើនឡើង ២% រៀងរាល់ឆ្នាំ | | | | |
| | រយៈពេលនៃការទទួលលិខិតប្រកាស និងផ្ទៀងផ្ទាត់ | ១៥នាទី | ១០ | ១០ | ១០ | ៨ | ៨ |
| | រយៈពេលបម្រើសេវា (serving time) នៃការដាក់ពាក្យស្នើសុំប្រកាសបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនៅរាជធានីភ្នំពេញ | ១៥នាទី | ១០ | ១០ | ១០ | ៨ | ៨ |
| | ភាគរយនៃអចលនទ្រព្យដែលបានចុះបញ្ជីតាមរយៈអង្កេត | ១០០% | ១០០% | | | | |
| | ភាគរយនៃអចលនទ្រព្យដែលបានធ្វើបច្ចុប្បន្នភាពតាមរយៈអង្កេត | ១០០% | ១០០% | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ និងរៀបចំផែនការលើកទឹកចិត្តដល់មន្ត្រីផ្តល់សេវា | យន្តការត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ ត្រូវបានបង្កើត | គ្មាន | | √ | | | |
| | ផែនការលើកទឹកចិត្តដល់មន្ត្រីផ្តល់សេវាត្រូវបានរៀបចំ | គ្មាន | | √ | | | |
| • ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងជៀសវាងការកើនឡើងបំណុលពន្ធអនាគត | ចំនួនសហគ្រាសដែលស្ថិតក្នុងបញ្ជីបំណុលអាចប្រមូលបាន (បំណុលអាយុកាលតិចជាង ០៣ឆ្នាំ) | ២ ៨៤៣ សហគ្រាស | ថយចុះជារៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបានទូទាត់ | ១០% | កើនឡើង ១% រៀងរាល់ឆ្នាំ | | | | |
| | ចំនួនសហគ្រាសដែលស្ថិតក្នុងបញ្ជីបំណុលមិនអាចប្រមូលបាន (បំណុលអាយុកាលលើសពី ០៣ឆ្នាំ) | ២ ៩៩២ សហគ្រាស | ថយចុះជារៀងរាល់ឆ្នាំ | | | | |
| **គ. មុខងារគាំទ្រ** | | | | | | | |
| • ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាល និងរៀបចំប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មការងារ | ផែនការយុទ្ធសាស្ត្រធនធានមនុស្សត្រូវបានដាក់ឱ្យអនុវត្ត | គ្មាន | √ | | | | |
| | ចំនួនមន្ត្រីដែលបានទទួលការកសាងសមត្ថភាពត្រូវនឹងមុខងាររបស់ខ្លួន | ១ ៣៦០ នាក់ | កើនឡើងជារៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • អនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមាន លក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា, ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និងប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន ដោយរួមបញ្ចូលទាំងផែនការវិនិយោគ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធ រួមមានមុខងារស្នូល (ចុះបញ្ជីពន្ធដារ, សេវាអ្នកជាប់ពន្ធ, ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ, សវនកម្ម, បំណុល, និង វិវាទ) និងមុខងារគាំទ្រ ត្រូវបានធ្វើសមាហរណកម្ម និងស្វ័យប្រវត្តិកម្មពេញលេញ ត្រូវបានបង្កើត | គ្មាន | | | | √ | |
| • សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ឬបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិ និងលទ្ធភាពពេញលេញដល់រដ្ឋបាលសារពើពន្ធក្នុងការទទួលយកព័ត៌មាន និងទិន្នន័យពន្ធដារ (submission and management of taxation data) ដោយ ផ្តល់លទ្ធភាពតភ្ជាប់រវាងប្រព័ន្ធទិន្នន័យរបស់ស្ថាប័ននានាមកកាន់ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ | របាយការណ៍លទ្ធផលនៃការសិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ឬបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិ និងលទ្ធភាពពេញលេញដល់រដ្ឋបាលសារពើពន្ធក្នុងការទទួលយកព័ត៌មាន និងទិន្នន័យពន្ធដារ | គ្មាន | | √ | | | |
| • សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតម្រូវការឱ្យអាជីវកម្មទាំងអស់ប្រើប្រាស់ប្រព័ន្ធ cash receipt system សម្រាប់ប្រតិបត្តិការជាមួយអតិថិជនទូទៅ (business to customers) ដោយសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញតិស្តីពីពន្ធដារ | របាយការណ៍លទ្ធផលនៃសិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតម្រូវការឱ្យអាជីវកម្មទាំងអស់ប្រើប្រាស់ប្រព័ន្ធ cash receipt system សម្រាប់ប្រតិបត្តិការជាមួយអតិថិជនទូទៅ (business to customers) | គ្មាន | | √ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • រៀបចំក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីតម្រូវការនៃព័ត៌មាន និងនីតិវិធីនៃការបែងចែកព័ត៌មាន ហើយលើកសំណើរៀបចំនូវថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សំដៅធ្វើទំនើបកម្មសម្រួលកិច្ចការចុះបញ្ជីអាជីវកម្ម និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០១៩ | សេចក្តីសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីតម្រូវការនៃព័ត៌មាន និងនីតិវិធីនៃការបែងចែកព័ត៌មានហើយលើកសំណើរៀបចំនូវថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សំដៅធ្វើទំនើបកម្មសម្រួលកិច្ចការចុះបញ្ជីអាជីវកម្ម | គ្មាន | | √ | | | |
| • ពិនិត្យលទ្ធភាព, ភាពចាំបាច់ និងផលប៉ះពាល់លើការរៀបចំឡើងវិញការលើកទឹកចិត្តសវនករពន្ធដារ ដែលត្រូវផ្សារភ្ជាប់នឹងសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ | លទ្ធផលនៃការសិក្សាការរៀបចំឡើងវិញការលើកទឹកចិត្តសវនករពន្ធដារ ដែលត្រូវផ្សារភ្ជាប់នឹងសូចនាករសមិទ្ធកម្មគន្លឹះ | គ្មាន | | √ | | | |
| • ដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ ដើម្បីធានាថា  មន្ត្រីអនុវត្តការងារប្រកប ដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ | ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ មន្ត្រីត្រូវបានប្រើប្រាស់ នៅគ្រប់នាយកដ្ឋាន និងសាខាខេត្ត-ខណ្ឌ | គ្មាន | | | √ | | |

## ឧបសម្ព័ន្ធ ២. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

| ល.រ | វិធានការទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សូចនាករ | បន្ទាត់មូលដ្ឋាន | គោលដៅប្រចាំឆ្នាំ |
|---|---|---|---|---|
| I. | **កិច្ចសម្រួលពាណិជ្ជកម្ម** | | | |
| ១ | កែលម្អវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ | វិធីសាស្ត្រនៃការកំណត់សូចនាករហានិភ័យ និងលក្ខខណ្ឌវិនិច្ឆ័យជ្រើសរើសហានិភ័យ ត្រូវបានអនុវត្ត | | ២០២០ |
| | | ភាគរយនៃចំនួន SAD សរុបដែលបានកំណត់ក្រោមច្រកក្រហម | ១០% | មិនលើស ៩% នៃចំនួន SAD សរុប (២០២០) |
| | | របាយការណ៍ចំនួនបទល្មើសគយក្រោយពីបានធ្វើការត្រួតពិនិត្យរូបវន្ត | | ២០២០ |
| ២ | ជំរុញការអនុវត្តប្រកាសលេខ ១៦០៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការផ្តល់សេវា សាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង ប្រកាសលេខ ៣២៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូលផ្ទុកក្នុងកុងតែន័រ ឱ្យមានប្រសិទ្ធភាពខ្ពស់ | របាយការណ៍លទ្ធផល | | ២០១៩ |

| | | | | |
|---|---|---|---|---|
| ៣ | បញ្ចប់ការរៀបចំ និងធ្វើវិសោធនកម្មអនុក្រឹត្យលេខ ២០៩ អនក្រ.បក ដោយកាត់បន្ថយឱ្យបានជាអតិបរមា នូវមុខទំនិញជាប់កម្រិតកំណត់ និងមុខទំនិញហាមឃាត់ | អនុក្រឹត្យថ្មីត្រូវបានបង្កើត | | ២០២០ |
| ៤ | សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំង ៥ ដើម្បីជំរុញដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី ២ ឱ្យបានទាន់ពេលវេលាដូចដែលបានកំណត់ | ប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី ២ ត្រូវបានដាក់ឱ្យអនុវត្ត | | ២០១៩ |
| ៥ | បន្តធ្វើសាមញ្ញកម្ម, ទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀតស្របតាមស្តង់ដារអន្តរជាតិ សំដៅកែលម្អបន្ថែមទៀតនូវគុណភាពនៃការផ្តល់សេវា និងបង្កើនភាពពេញចិត្តរបស់អតិថិជន | របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃលើបញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ (prohibited and restricted goods) និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | | ២០១៩ |
| | | ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងការផ្តល់លិខិតអនុញ្ញាតគយ ត្រូវបានធ្វើវិមជ្ឈការដោយផ្អែកលើគោលការណ៍ហានិភ័យ | | ប្រចាំឆ្នាំ |
| | | នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតគយត្រូវបានកាត់បន្ថយឱ្យខ្លី និងត្រូវបានធ្វើស្វ័យប្រវត្តិកម្ម | | ២០១៩ |
| | | ការត្រួតពិនិត្យដោយម៉ាស៊ីនស្កេនត្រូវបានកាត់បន្ថយ | | ២០១៩ |
| | | ចងក្រងបញ្ជីមុខទំនិញដែលចាំបាច់នៃការប្រើប្រាស់លិខិតអនុញ្ញាតគយសម្រាប់ការនាំចេញ និងការនាំចូល | | ២០២០ |

| | | | | |
|---|---|---|---|---|
| | | តម្រូវការឯកសារ hard copy សម្រាប់នីតិវិធីគយត្រូវបាន កាត់បន្ថយ | | ២០២១ |
| | | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ត្រូវបានធ្វើសន្ទានកម្ម | | ២០២៣ |
| ៦ | រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយកិច្ចសម្រួលពាណិជ្ជកម្ម ប្រកបដោយការទទួលខុសត្រូវ | យន្តការតាមដាន និងវាយតម្លៃនៃការផ្តល់សេវាសាធារណៈត្រូវបានបង្កើត | | ២០១៩ |
| | | របាយការណ៍នៃការតាមដាន និងវាយតម្លៃ | | ២០១៩ |
| | | របាយការណ៍ការសិក្សារយៈពេលបញ្ចេញទំនិញពីគយ (time release study) | | ២០២០ |
| ៧ | ពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហានិភ័យ ជាពិសេសជំរុញការដាក់អនុវត្តនូវប្រព័ន្ធ pre-arrival information ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារត្រួតពិនិត្យ និងលើកកម្ពស់អនុលោមភាព | ប្រព័ន្ធ pre-arrival ព័ត៌មានត្រូវរៀបចំ និងអនុវត្តជាប្រព័ន្ធស្វ័យប្រវត្តិកម្ម | | ២០២២ |
| ៨ | ធ្វើឱ្យប្រសើរឡើងថែមទៀត នូវការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ | កញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តត្រូវបានកែសម្រួលនិងដាក់ឱ្យអនុវត្ត | | ២០២១ |
| ៩ | ពង្រីកយន្តការធុរជនល្អបំផុត (best trader mechanism) និងឈានទៅអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (authorised economic operator - AEO) និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការនេះ | ចំនួនសមាជិកក្រុមធុរជនល្អបំផុតត្រូវបានបង្កើន | | ២០២១ |
| | | យន្តការ AEO ត្រូវបានបង្កើត និងដាក់អនុវត្ត | | ២០២៣ |

| | | | | |
|---|---|---|---|---|
| ១០ | ពង្រីកវិសាលភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព | ចំនួនការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព | | ២០២២ |
| ១១ | ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ | ប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី ៣ ចាប់ផ្តើមអនុវត្ត និងពង្រីកវិសាលភាពជាបន្តបន្ទាប់ | | ២០២០ |
| ១២ | តភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិរបស់កម្ពុជាទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន | ប្រព័ន្ធបញ្ជរតែមួយជាតិរបស់កម្ពុជាត្រូវបានតភ្ជាប់ទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន | | ២០២៣ |
| **II.** | **ការកែលម្អ និងពង្រឹងអភិបាលកិច្ច** | | | |
| ១ | ពង្រឹងការកំណត់សូចនាករ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការជ្រើសរើសក្រុមហ៊ុនសម្រាប់ធ្វើសវនកម្ម ដោយផ្អែកលើហានិភ័យ | សូចនាករ និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស ក្រុមហ៊ុនសម្រាប់ធ្វើសវនកម្មត្រូវបានអនុវត្ត | | ២០២០ |
| ២ | ជំរុញការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយឱ្យបានទូលាយ (comprehensive customs audit) ជាជាងការធ្វើសវនកម្មតែលើឯកសារ (desk review audit) | ចំនួនសវនកម្មក្រោយពេលបញ្ចេញទំនិយពីគយដែលសម្រេចបានធៀបនឹងផែនការ | | ៥០% ក្នុងឆ្នាំ ២០២០ |
| | | យន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយឱ្យបានទូលាយ (comprehensive customs audit) ត្រូវបានអនុវត្ត | | ២០២០ |
| ៣ | បន្តពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ | មុខសញ្ញារងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ត្រូវបានបង្កើនចំនួន | | ២០២០ |

| | | | | |
|---|---|---|---|---|
| ៤ | ពង្រឹងសមត្ថភាពរបស់មន្ត្រីសវនកម្មគយ និងបង្កើនចំនួនអង្គភាពសវនកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង | ចំនួនអង្គភាពសវនកម្មត្រូវបានបង្កើត | | ២០២០ |
| | | ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីសវនកម្មគយត្រូវបានបង្កើន | | ២០២០ |
| ៥ | បញ្ចប់យុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy) | យុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ត្រូវបានបញ្ចប់ និងដាក់ឱ្យអនុវត្ត | | ២០២០ |
| ៦ | ជំរុញការអនុវត្តកម្រិតផ្តន្ទាទោសតាមប្រព័ន្ធតុលាការចំពោះបទល្មើសគយ ដែលមិនអាចសម្រុះសម្រួលដោះស្រាយដោយរដ្ឋបាលគយ | របាយការណ៍លទ្ធផល | | ២០២០ |
| ៧ | ពិនិត្យឡើងវិញលើសិទ្ធិរបស់អង្គភាពក្រោមឱវាទ អ.គ. រ. ក្នុងការសម្រុះសម្រួលបទល្មើសគយ តាមឋានានុក្រម | លិខិតបទដ្ឋានគតិយុត្តទាក់ទិននឹងសិទ្ធិក្នុងការសម្រុះសម្រួលបទល្មើសគយ ត្រូវបានកែសម្រួល | | ២០២០ |
| ៨ | តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយតាមបណ្តាអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ | របាយការណ៍វាយតម្លៃប្រសិទ្ធភាពការងារតាមអង្គភាពត្រូវបានរៀបចំ | | ២០២០ |
| III. | **ការគ្រប់គ្រងបែបយុទ្ធសាស្ត្រ** | | | |
| ១ | ពិនិត្យ និងកំណត់មុខទំនិញដែលជាប្រភពចំណូលសំខាន់ និងពិនិត្យភាពចាំបាច់នៃការកំណត់មាត់ច្រកជាក់លាក់សម្រាប់ការនាំចូលមុខទំនិញទាំងនេះ តាមកម្រិតហានិភ័យ | មុខទំនិញដែលជាប្រភពចំណូលសំខាន់ៗ ត្រូវបានកំណត់ | | ២០២០ |
| | | មាត់ច្រកសម្រាប់ការនាំចេញនាំចូលមុខទំនិញខាងលើ ត្រូវបានកំណត់ | | ២០២០ |

| | | | | |
|---|---|---|---|---|
| ២ | បន្តពង្រឹងយន្តការផ្តល់ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម | របាយការណ៍លទ្ធផលត្រូវបានរៀបចំ | | ២០១៩ |
| ៣ | បញ្ចប់ការកសាងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT Strategy) របស់ អ.គ.រ. | ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបញ្ចប់ និងដាក់អនុវត្ត | | ២០២០ |
| ៤ | រៀបចំផែនការជាក់លាក់ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប | របាយការណ៍លទ្ធផលវាយតម្លៃតម្រូវការចាំបាច់នៃធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត និងតាមភូមិសាស្ត្រ | | ២០២១ |
| | | ផែនការជាក់លាក់ក្នុងការរៀបចំធនធានមនុស្សសម្រាប់ អ.គ.រ. | | ២០២១ |
| ៥ | ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ទានកម្មបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. ឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, ប្រព័ន្ធបញ្ជរតែមួយជាតិ និង direct trader input (DTI) ។ល។ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានាត្រូវបានធ្វើសន្ទានកម្ម | | ២០២៣ |

## ឧបសម្ព័ន្ធ ៣. សូចនាករវិធានការគោលនយោបាយសារពើពន្ធ

| ល.រ | វិធានការគោលនយោបាយសារពើពន្ធ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **I.** | **គោលនយោបាយអាករពិសេស** | | | |
| ១ | កំណត់គោលការណ៍នៃរយៈពេលចូលជាធរមាន នៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស ក្នុងការធានាភាពប្រាកដប្រជានៃគោលនយោបាយ ដើម្បីសម្រួលដល់ការរៀបចំផែនការអាជីវកម្ម និងលំហូរសាច់ប្រាក់របស់ធុរជន | រយៈពេលចូលជាធរមាន នៃការផ្លាស់ប្តូរគោល-នយោបាយអាករពិសេសត្រូវបានកំណត់ | ២០២០ | កសហវ, អគរ, អពជ និង អគស |
| ២ | សិក្សា និងពិនិត្យឡើងវិញលើមូលដ្ឋានកំណត់អាករពិសេសរបស់ផលិតផលក្នុងស្រុក ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកទឹកចិត្តឱ្យមានផលិតកម្មក្នុងស្រុកកាន់តែច្រើន | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អគរ, អពជ និង អគស |
| ៣ | ពិនិត្យឡើងវិញអត្រាអាករពិសេស និងមូលដ្ឋានគិតពន្ធលើយានយន្តភាតរបរិស្ថាន (environmentally friendly vehicles), ផលិតផលបារី, ស្រាបៀរ, ស្រា, និងភេសជ្ជៈមានជាតិស្ករ ។ល។ និងទំនិញប្រភេទប្រណិតមួយចំនួន ដើម្បីធានាសុខុមាលភាពប្រជាជន និងការពារបរិស្ថាន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ និង ក្រសួងពាក់ព័ន្ធ |
| ៤ | បន្តធ្វើវិចារណកម្មអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០១៩ | កសហវ, អគរ, អពជ និង អគស |

| | | | | |
|---|---|---|---|---|
| ៥ | ពង្រឹងអនុលោមភាពការងារបច្ចេកទេសគយ តាមរយៈការពង្រឹងយន្តការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញ និងការជំរុញការលើកទឹកចិត្តអនុលោមភាពដោយស្ម័គ្រចិត្ត | នីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញត្រូវបានកែសម្រួល | ២០២០ | កសហវ, អគរ, អពជ និង អគស |
| | | មុខសញ្ញាមានហានិភ័យទាប ត្រូវបានកំណត់ដើម្បីផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្ត | ២០២០ | កសហវ, អគរ, អពជ និង អគស |
| ៦ | រៀបចំគោលនយោបាយអាករពិសេស ដើម្បីពង្រឹងភាពដែលអាចទស្សន៍ទាយបាន (predictability) នៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស និងលើកកម្ពស់បរិយាកាសធុរកិច្ច | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០១៩ | កសហវ, អពជ, អគរ, និង អគស |
| | | សេចក្តីព្រាងគោលនយោបាយអាករពិសេសត្រូវបានដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ | ២០២០ | |
| ៧ | រាល់សំណើកែប្រែគោលនយោបាយអាករពិសេស ត្រូវដាក់ឱ្យមានការពិគ្រោះយោបល់ក្នុងគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីធានានូវប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្ត | សំណើរលើការកែប្រែគោលនយោបាយអាករពិសេសត្រូវបានពិគ្រោះយោបល់ក្នុងគណៈកម្មាធិការគោល-នយោបាយសារពើពន្ធ | ២០១៩ | គណៈកម្មាធិការគោលនយោបាយសារពើពន្ធ |
| ៨ | ពិនិត្យលទ្ធភាពប្តូរប្រព័ន្ធអាករពិសេសពី ប្រភេទគិតតាមអត្រា (ad valorem) ទៅជាប្រព័ន្ធចម្រុះដែលគិតតាមអត្រាផងនិង/ ឬគិតតាមឯកតាផង (mixed method) ដើម្បីធានាបានសមធម៌រវាងផលិតផលក្នុងស្រុក និងផលិតផលនាំចូល | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២១ | កសហវ, អគរ, អពជ និង អគស |
| | | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០១៩ | |

| | | | | |
|---|---|---|---|---|
| ៩ | រៀបចំឱ្យមានច្បាប់អាករពិសេសរួម និងគ្រប់ជ្រុងជ្រោយ ដើម្បីសម្រួលដល់ការគ្រប់គ្រង, ការអនុវត្ត និងការពង្រឹងអនុលោមភាព | កិច្ចប្រជុំរបស់ក្រុមការងារជាមួយតួអង្គពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងច្បាប់អាករពិសេស | ២០២០ | កសហវ, ក្រុមប្រឹក្សានីតិកម្ម, អគរ, អពដ និង អគស |
| | | សេចក្តីព្រាងច្បាប់អាករពិសេសត្រឹមកម្រិតក្រុមការងារ | ២០២១ | |
| | | សេចក្តីព្រាងច្បាប់អាករពិសេសត្រូវបានដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ | ២០២២ | |
| **II.** | **ពន្ធលើអចលនទ្រព្យ** | | | |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) លើពន្ធអចលនទ្រព្យ ឱ្យស្របនឹងថ្លៃអចលនទ្រព្យដែលត្រូវធ្វើបច្ចុប្បន្នភាពសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រាដោយដាក់ឱ្យអនុវត្តនៅឆ្នាំ ២០១៩ | លិខិតបទដ្ឋានគតិយុត្តលើការធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានគិតពន្ធត្រូវបានដាក់ឱ្យអនុវត្ត | ២០១៩ | កសហវ, អពដ, និង អគស |
| | | លិខិតបទដ្ឋានគតិយុត្តនៃការកែសម្រួលកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) លើពន្ធអចលនទ្រព្យ ត្រូវបានដាក់ឱ្យអនុវត្ត | ២០២០ | |
| ២ | កំណត់គោលការណ៍ធ្វើបច្ចុប្បន្នកម្មថ្លៃអចលនទ្រព្យ សម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រា និង កម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) រៀងរាល់ ៥ ឆ្នាំម្តង | លិខិតបទដ្ឋានគតិយុត្តក្នុងការកំណត់រយៈពេលនៃការធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានគិតពន្ធត្រូវបានដាក់ឱ្យអនុវត្ត | ២០២០ | កសហវ, អពដ, MOI, MOLMUC |

| | | | | |
|---|---|---|---|---|
| ៣ | ត្រួតពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យក្នុងរង្វង់ញាតិ | របាយការណ៍លទ្ធផលត្រួតពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគស |
| ៤ | ពិនិត្យលទ្ធភាពលើការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគស |
| ៥ | ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ចំនួនអ្នកបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ២០១៩ | កសហវ, អពដ |
| ៦ | សិក្សា, រៀបចំ និងដាក់ចេញវិធានការបង្ការសកម្មភាពបរិកប្បកម្មលើអចលនទ្រព្យ (property speculation) | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០២០ | កសហវ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| | | របាយការណ៍លទ្ធផលសិក្សាត្រូវបានរៀបចំ | ២០២៣ | |
| **III.** | **អាករលើតម្លៃបន្ថែម** | | | |
| ១ | សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាករលើតម្លៃបន្ថែម ដោយផ្តោតលើវិក្កយបត្រអាករ (tax invoice) និងវិក្កយបត្រអាករតាមប្រព័ន្ធអេឡិចត្រូនិក (e-tax system) ព្រមទាំងសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ | របាយការណ៍លទ្ធផលសិក្សា និងបទប្បញ្ញត្តិគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ, អគរ និង អគស |
| ២ | ពិនិត្យឡើងវិញលើការលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងបទប្បញ្ញត្តិគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគរ |
| **IV.** | **អាករសម្រាប់បំភ្លឺសាធារណៈ** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពិនិត្យលទ្ធភាពធ្វើការកែសម្រួលអាករសម្រាប់បំភ្លឺសាធារណៈ ដើម្បីបង្កើនអនុលោមភាព, ផ្តល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ, អគរ និង អគស |
| **V.** | **ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល** | | | |
| ១ | កសាងក្របខ័ណ្ឌគោលនយោបាយ សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល | ក្របខ័ណ្ឌគោលនយោបាយត្រូវបានបង្កើត | ២០២០ | កសហវ, អពដ និង អគស |
| ២ | ដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន (capital gain) | លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីគណនា ត្រូវបានរៀបចំ | ២០២០ | កសហវ និង អពដ |
| | | ផ្សព្វផ្សាយដល់សាធារណៈជន | ២០២០ | កសហវ និង អពដ |
| | | ពន្ធលើចំណេញមូលធនត្រូវបានអនុវត្ត | ២០២០ | កសហវ និង អពដ |
| ៣ | រៀបចំរដ្ឋបាលសារពើពន្ធដែលមានសមត្ថភាព និងឯកទេស សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលប្រកបដោយប្រសិទ្ធភាព | រដ្ឋបាលសារពើពន្ធត្រូវបានពង្រឹងសមត្ថភាព | ២០២៣ | កសហវ និង អពដ |
| **VI.** | **ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** | | | |
| ១ | សិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តពន្ធ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ និងក្រសួងពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ២ | សិក្សាលទ្ធភាពក្នុងការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ដើម្បីត្រៀមគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២៣ | កសហវ និងក្រសួងពាក់ព័ន្ធ |
| **VII.** | **វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ** | | | |
| ១ | ដាក់កាតព្វកិច្ចបង់ពន្ធតាមរបបស្វ័យប្រកាសចំពោះអាជីវកម្មទាំងអស់ក្រៅពីសកម្មភាពល្បែង | លិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ២០២០ | កសហវ, អពដ |
| ២ | ពិនិត្យឡើងវិញនូវផលរបរប្រចាំឆ្នាំ ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច, មធ្យម និងធំ ដើម្បីឆ្លើយតបទៅនឹងកំណើនសកម្មភាពធុរកិច្ច | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និងអគស |
| ៣ | ពិនិត្យឡើងវិញកម្រិតប្រាក់ចំណូលអប្បបរមាជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គលដើម្បីលើកទឹកចិត្តការធ្វើអាជីវកម្ម | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និងអគស |
| ៤ | ពិនិត្យឡើងវិញពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ (២០%) ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដើម្បីទាក់ទាញការវិនិយោគ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និងអគស |
| ៥ | ពិនិត្យឡើងវិញអត្រាពន្ធគយលើមុខទំនិញ ដែលមិនមែនជាប្រភពចំណូលនិងជាធាតុចូលសំខាន់សម្រាប់វិស័យអាទិភាព ដូចជា វិស័យកសិកម្ម, អប់រំ និងដឹកជញ្ជូន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អគរ, អពដ, និង អគស |
| ៦ | ពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធលើវិស័យហិរញ្ញវត្ថុ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២២ | កសហវ, អពដ និងអគស |
| **VIII.** | **ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ** | | | |

| | | | | |
|---|---|---|---|---|
| ១ | បញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និងរៀបចំច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ឱ្យបានចប់សព្វគ្រប់នៅចុងឆមាសទី ១ ឆ្នាំ ២០១៩ | ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគត្រូវបានបញ្ចប់ | ឆមាសទី ១ ឆ្នាំ ២០១៩ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| | | ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសត្រូវបានរៀបចំ | ឆមាសទី ១ ឆ្នាំ ២០១៩ | |
| ២ | កំណត់វិស័យអាទិភាព និងរបបលើកទឹកចិត្តពន្ធដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង | វិស័យអាទិភាព និងរបបលើកទឹកចិត្តពន្ធ ត្រូវបានកំណត់ និងដាក់បញ្ចូលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង | ២០២០ | កសហវ |
| **IX.** | **ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម** | | | |
| ១ | រៀបចំប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១២៤, ៥១ និង ៥០ | ប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើត | ២០១៩ | កសហវ |
| ២ | សិក្សា និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តអនុក្រឹត្យទាំងបីខាងលើ និងស្នើសុំកែសម្រួលក្នុងករណីចាំបាច់ | របាយការណ៍វាយតម្លៃត្រូវបានរៀបចំ | ២០២១ | កសហវ |
| **X.** | **ការរៀបចំប្រព័ន្ធសារពើពន្ធ** | | | |
| ១ | សិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជា | ឯកសារស្តីពីប្រព័ន្ធសារពើពន្ធត្រូវបានរៀបចំ | ២០២៣ | កសហវ |

## ឧបសម្ព័ន្ធ ៤. សូចនាករសមិទ្ធកម្មគន្លឹះរបស់រដ្ឋបាលចំណូលមិនមែនសារពើពន្ធ

| ល.រ | វិធានការ | សូចនាករ | ឆ្នាំគោលដៅ | ក្រសួង-ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| I | **ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រង** | | | |
| ១ | បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ដើម្បីសម្រួលដល់ការបង់ចំណូល, ការប្រើប្រាស់ប្រព័ន្ធធនាគារឱ្យបានពេញលេញ, ការបង់ចំណូលចូលគណនីទោលរតនាគារជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា, ការចងក្រងរបាយការណ៍ចំណូលក្នុងប្រព័ន្ធឱ្យកាន់តែមានតម្លាភាព និងឆាប់រហ័ស និងបញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬ អាជ្ញាបណ្ណ ចូលក្នុងប្រព័ន្ធ ដើម្បីធានាតម្លាភាព និងការតាមដានកាន់តែមានប្រសិទ្ធភាព | រាល់ប្រតិបត្តិការចំណូលត្រូវបានឆ្លងកាត់ប្រព័ន្ធ NRMIS | ២០២០ | កសហវ និង ក្រសួង-ស្ថាប័នប្រមូលចំណូល (ថ្នាក់ជាតិ) |
| | | | ២០២២ | កសហវ និង រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | | ចំនួនកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណបន្ថែមត្រូវបានបញ្ចូលក្នុងប្រព័ន្ធ NRMIS | ២០២០ | កសហវ និងក្រសួង-ស្ថាប័នប្រមូលចំណូល |
| ២ | បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិសម្រាប់ដាក់ឱ្យអនុវត្តដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងជំរុញឱ្យការរៀបចំបញ្ជីក្នុងប្រព័ន្ធ និងការរៀបចំបណ្ណកម្មសិទ្ធិឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ | ប្រព័ន្ធក្រៅបណ្តាញ (offline) ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | កសហវ និងក្រសួង-ស្ថាប័នជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ |
| | | ប្រព័ន្ធអនឡាញ (online system) ត្រូវបានអនុវត្តដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២៣ | កសហវ និងក្រសួង-ស្ថាប័នជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ |

| | | | | |
|---|---|---|---|---|
| ៣ | សិក្សាស៊ីជម្រៅស្តីពីនីតិវិធីនៃការផ្លាស់ប្តូរការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ ឬជាការប្រើប្រាស់ e-payment | លទ្ធផលជាក់លាក់ស្តីពីនីតិវិធីនៃការផ្លាស់ប្តូរការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ ឬជាការប្រើប្រាស់ e-payment ត្រូវបានបញ្ចប់ ដោយក្នុងនោះមានទាំងលទ្ធផលនៃការសិក្សា រៀបចំលិខិតបទដ្ឋានគតិយុត្ត និងការងារបច្ចេកទេសព័ត៌មានវិទ្យា | ២០២១ | កសហវ និងក្រសួងស្ថាប័នប្រមូល-ចំណូល |
| **II** | **បទប្បញ្ញត្តិគោលពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ** | | | |
| ១ | សិក្សា និងរៀបចំឯកសារគោល (blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ | ឯកសារគោល (blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ | ២០២០ | កសហវ |
| ២ | អនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ២០២២ | កសហវ |
| ៣ | អនុម័តច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ២០២០ | កសហវ |
| **III** | **វិធានការតាមវិស័យ និងប្រភពចំណូលសំខាន់ៗ** | | | |
| ១ | សិក្សាឡើងវិញ និងរៀបចំយន្តការស្តង់ដារក្នុងការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈ ឈរលើគោលការណ៍សមធម៌ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល | ចងក្រងឯកសារ និងយន្តការស្តង់ដារក្នុងការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈ | ២០២២ | ក្រសួង-ស្ថាប័នប្រមូលចំណូល និងកសហវ |

| | | | | |
|---|---|---|---|---|
| **ក** | **វិស័យអាកាសចរណ៍ស៊ីវិល** | | | |
| ១ | បន្តសិក្សា និងពិនិត្យលទ្ធភាពកែសម្រួលកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាឱ្យឆ្លុះបញ្ចាំងពីកំណើនជើងហោះហើរឡើង/ចុះ និងហោះ ឆ្លងកាត់ដែនអាកាសកម្ពុជា និងធានាឱ្យបាននូវលក្ខខណ្ឌដែលអំណោយផលដល់ការអភិវឌ្ឍវិស័យនេះ និងកំណើនចំណូលសមស្រប | កិច្ចសន្យាថ្មីដែលត្រូវបានធ្វើវិសោធនកម្ម ឬ របាយការណ៍ហេតុផលនៃការមិនធ្វើវិសោធនកម្ម ក្នុងករណីមិនមានការកែសម្រួល | ២០២០ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង កសហវ |
| **ខ** | **វិស័យទេសចរណ៍** | | | |
| ១ | បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារ | រាល់អាជ្ញាបណ្ណទេសចរណ៍ត្រូវស្នើសុំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងចំណូលត្រូវបង់តាមធនាគារ | ២០២០ | ក្រសួងទេសចរណ៍ និង កសហវ |
| ២ | សិក្សាកែតម្រូវប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់ការធ្វើអាជីវកម្ម និងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ | ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ | ២០១៩ | ក្រសួងទេសចរណ៍ |
| ៣ | រៀបចំបែងចែកតួនាទីគ្រប់គ្រងរមណីយដ្ឋានឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធ | លិខិតបទដ្ឋានស្តីពីការបែងចែកតួនាទីគ្រប់គ្រងរមណីយដ្ឋានរបស់ស្ថាប័នពាក់ព័ន្ធ | ២០២០ | ក្រសួងទេសចរណ៍, កសហវ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤ | បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ | ប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍ត្រូវបានដាក់អនុវត្ត | ២០២០ | ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| ៥ | សិក្សានិងពិនិត្យលទ្ធភាពអភិវឌ្ឍន៍រមណីយដ្ឋានដែលមានសក្ដានុពល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងប្រមូលចំណូលឱ្យអស់លទ្ធភាព | របាយការណ៍លទ្ធផលនៃការសិក្សា ស្ដីពីការអភិវឌ្ឍរមណីយដ្ឋានសក្ដានុពល | ២០២២ | ក្រសួងទេសចរណ៍ |
| **គ** | **ចំណូលពីអាករស្ថានទូត** | | | |
| ១ | ពង្រឹងការរៀបចំរបាយការណ៍ស្ដីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ផ្អែកលើនីតិវិធីនៃការកត់ត្រា និងតាមដានសន្និធិ តាមវិធីសាស្ត្រឃ្លាំងសន្និធិ (stock inventory) នៅគ្រប់ចំណុចគោលដៅ ដែលមានសមត្ថកិច្ចផ្ដល់ទិដ្ឋាការជូនភ្ញៀវទេសចររួមមាន ច្រកអន្តរជាតិ, ស្ថានទូត, ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស | របាយការណ៍ស្ដីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និង ស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ត្រូវបានផ្ដល់ជូន កសហវ ឱ្យបានទៀងទាត់ | ប្រចាំត្រីមាស | ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ២ | សិក្សាលទ្ធភាពកែសម្រួលកម្រៃទិដ្ឋាការសម្រាប់ជនអន្តោប្រវេសន៍ចេញចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា | របាយការណ៍សិក្សា និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | ក្រសួងមហាផ្ទៃ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង កសហវ |
| **ឃ** | **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ១ | ជំរុញការប្រើប្រាស់ប្រកាសរួមស្ដីពីការដាក់ឱ្យអនុវត្តទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ឱ្យមានប្រសិទ្ធភាព ដើម្បីជាមូលដ្ឋានក្នុងការប្រមូលចំណូលពន្ធ និងមិនមែនពន្ធ | ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃប្រកាសរួមស្ដីពីការដាក់ឱ្យអនុវត្តទិន្នន័យ DMC | ២០១៩ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២ | គ្រប់គ្រង និងប្រមូលចំណូលពីវិសាលគមន៍ប្រេកង់វិទ្យុ (radio frequency spectrum) ដែលជាធនធានកម្មសិទ្ធិរបស់ជាតិ និងចំណូល | កំណើនចំណូលថ្មីពីវិសាលគមន៍ប្រេកង់វិទ្យុ (radio frequency spectrum) | ២០១៩ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | |
|---|---|---|---|---|
| | ផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ តាមរយៈការដកហូតអាជ្ញាបណ្ណប្រេកង់ទំនេរដែលមិនបានប្រើប្រាស់ ព្រមទាំងការដាក់ឱ្យដេញថ្លៃ (auction) ប្រេកង់ទំនេរនិងមានតម្រូវការ | | | |
| ៣ | អនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ឱ្យបានពេញលេញ និងពន្លឿនបញ្ចប់បទប្បញ្ញត្តិគាំទ្រ ព្រមទាំងពង្រឹងការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់នៅក្នុងវិស័យនេះ | ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ និងអនុវត្តបទប្បញ្ញត្តិគាំទ្រ | ២០២០ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៤ | ធ្វើវិសោធនកម្មច្បាប់ស្តីពីវិស័យប្រៃសណីយ៍ | ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ត្រូវបានធ្វើវិសោធនកម្ម | ២០២០ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| **ង** | **ដីសម្បទានសេដ្ឋកិច្ច** | | | |
| ១ | ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យា ឬ កិច្ចសន្យាកែសម្រួលពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសជំរុញការអនុវត្តច្បាប់ និង លិខិតបទដ្ឋាននានាឱ្យបានម៉ឺងម៉ាត់ | ៥០% នៃកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចទាំងអស់ ត្រូវបានរៀបចំឡើងវិញស្របតាមបទ-ប្បញ្ញត្តិជាធរមាន | ២០១៩ | កសហវ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រសួងបរិស្ថាន |
| | | ១០០% នៃកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចទាំងអស់ ត្រូវបានរៀបចំឡើងវិញស្របតាមបទ-ប្បញ្ញត្តិជាធរមាន | ២០២០ | កសហវ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រសួងបរិស្ថាន |

| | | | | |
|---|---|---|---|---|
| ២ | រៀបចំយន្តការគ្រប់គ្រងការផ្ទេរឬលក់ដីសម្បទានសេដ្ឋកិច្ច ក្រោមរូបភាពជាការផ្ទេរភាគហ៊ុនឬផ្លាស់ប្តូរឈ្មោះម្ចាស់ក្រុមហ៊ុន ដើម្បីបង្កើនការប្រមូលចំណូលឱ្យអស់លទ្ធភាព | លិខិតបទដ្ឋានស្តីពីយន្តការគ្រប់គ្រងការផ្ទេរ ឬលក់ដីសម្បទានសេដ្ឋកិច្ច | ២០២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង កសហវ |
| ៣ | ពិនិត្យឡើងវិញលើថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច និងពិនិត្យបែងចែកចំណូលពីដីសម្បទានសេដ្ឋកិច្ចទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៥០% នៃចំណូលត្រូវបែងចែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | កសហវ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤ | ការផ្លាស់ប្តូរការបង់ចំណូលដីសម្បទានសេដ្ឋកិច្ចពីការបង់ចំណូលតាមទំហំផ្ទៃដីអនុញ្ញាតឈូសឆាយ មកជាការបង់ចំណូលតាមទំហំផ្ទៃដីផ្តល់ជូនដែលមានចែងក្នុងកិច្ចសន្យាសម្បទាន អនុវត្តតាមគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល | លក្ខខណ្ឌនេះ ត្រូវបានកែសម្រួលបញ្ចូលទៅគ្រប់កិច្ចសន្យាលិខិតអនុញ្ញាត/កិច្ចព្រមព្រៀង/ពាក់ព័ន្ធនានា នៃសម្បទានដីសេដ្ឋកិច្ច ឬតាមរយៈលិខិតបទដ្ឋានគតិយុត្តដើម្បីដាក់ឱ្យអនុវត្ត | ២០២០ | កសហវ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ច** | **ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍** | | | |
| ១ | ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ | កំណើនចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាន | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ២ | សិក្សាលទ្ធភាពកែសម្រួលថ្លៃជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យស្របតាមថ្លៃទីផ្សារជាក់ស្តែង និង ការផ្តល់រយៈពេលអនុគ្រោះលើការបង់ថ្លៃឈ្នួល ដោយភ្ជាប់លក្ខខណ្ឌជាមួយនឹងវឌ្ឍនភាពនៃការអនុវត្តគម្រោង/កិច្ចសន្យា | របាយការណ៍លទ្ធផលសិក្សាត្រូវបានរៀបចំ | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | | | | |
|---|---|---|---|---|
| ៣ | អនុវត្តការបង់កម្រៃចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន | កំណើនចំណូលពីការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **ឆ** | **សហគ្រាសសាធារណៈ** | | | |
| ១ | រៀបចំក្របខ័ណ្ឌគតិយុត្តថ្មីឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ | ក្របខ័ណ្ឌគតិយុត្តថ្មីត្រូវបានរៀបចំ | ២០២២ | កសហវ, ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ |
| **ជ** | **គ្រឹះស្ថានសាធារណៈរដ្ឋបាល** | | | |
| ១ | គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវអនុវត្តតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី ឱ្យបានពេញលេញ ដើម្បីធានាតម្លាភាពនៃប្រតិបត្តិការរបស់គ្រឹះស្ថាន | គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្តពេញលេញតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី | ២០២០ | កសហវ, ក្រសួងអាណាព្យាបាលបច្ចេកទេស និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ |
| **ឈ** | **វិស័យរ៉ែ និងថាមពល** | | | |
| ១ | សិក្សា និងធ្វើបច្ចុប្បន្នភាព កាតព្វកិច្ចហិរញ្ញវត្ថុនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ឱ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងផ្តល់ផលប្រយោជន៍ជូនភាគីរាជរដ្ឋាភិបាល | ៥០% នៃកាតព្វកិច្ចហិរញ្ញវត្ថុ នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាននឹងត្រូវបានពិនិត្យឡើងវិញ (ឆ្នាំគោល ២០១៨) | ២០២០ | ក្រសួងរ៉ែ និងថាមពល និង កសហវ |

| | | | | |
|---|---|---|---|---|
| | | ១០០% នៃកាតព្វកិច្ចហិរញ្ញវត្ថុ នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាននឹងត្រូវបានពិនិត្យឡើងវិញ (ឆ្នាំគោល ២០១៨) | ២០២៣ | ក្រសួងរ៉ែ និងថាមពល និង កសហវ |
| ២ | ពង្រឹងប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ, | កំណើនចំណូលពីការកៀរគរការប្រមូលចំណូលពីសួយសារ | ២០២០ | ក្រសួងរ៉ែ និងថាមពល និង កសហវ |
| ៣ | រៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល | ប្រព័ន្ធព័ត៌មានគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ត្រូវបានបង្កើត | ២០២០ | ក្រសួងរ៉ែ និងថាមពល |
| ៤ | រៀបចំលិខិតបទដ្ឋានដើម្បីកំណត់ឱ្យក្រុមហ៊ុនអាជីវកម្មរ៉ែមានប្រធានការដ្ឋានដែលមានជំនាញច្បាស់លាស់នៅគ្រប់ការដ្ឋានរ៉ែ | លិខិតបទដ្ឋានត្រូវបានរៀបចំ | ២០២០ | ក្រសួងរ៉ែ និងថាមពល |
| | | ៣០% នៃការដ្ឋានរ៉ែមានប្រធានការដ្ឋានដែលមានជំនាញទទួលស្គាល់ដោយក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើនចំណូល | ២០២១ | ក្រសួងរ៉ែ និងថាមពល |
| | | ១០០% នៃការដ្ឋានរ៉ែមានប្រធានការដ្ឋានដែលមានជំនាញទទួលស្គាល់ដោយក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើនចំណូល | ២០២៣ | ក្រសួងរ៉ែ និងថាមពល |
| **៣** | **ចំណូលពីសកម្មភាពល្បែង** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពន្លឿនការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់ | ច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ | ២០២០ | កសហវ និងក្រសួងមហាផ្ទៃ |
| | | អនុក្រឹត្យ ឬប្រកាស ត្រូវបានបង្កើត | ២០២១ | |
| ២ | បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់ | ចំនួនករណីអាជីវកម្មល្បែងខុសច្បាប់ត្រូវបានបង្ក្រាប | ២០២០ | កសហវ និងក្រសួងមហាផ្ទៃ |
| ៣ | បន្តខិតខំកៀរគរចំណូលឱ្យអស់ពីលទ្ធភាពពីសកម្មភាពល្បែងគ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលតាមបទប្បញ្ញត្តិជាធរមាន | កំណើនចំណូល | ២០២០ | កសហវ |
| **ង** | **ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** | | | |
| ១ | ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន | ៥០% នៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋត្រូវបានពិនិត្យឡើងវិញ | ២០១៩ | កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| | | ១០០% នៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋត្រូវបានពិនិត្យឡើងវិញ | ២០២០ | កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ២ | ពង្រឹងយន្តការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធានាការអភិវឌ្ឍ និងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព | របាយការណ៍ស្តីពីការចុះត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ | ២០២០ | កសហវ |

| | | | | |
|---|---|---|---|---|
| ៣ | សិក្សា និងពិនិត្យលទ្ធភាពបង្កើតតំបន់អចលនវត្ថុរបស់រដ្ឋ ឱ្យស្របទៅតាមផែនការមេនៃការរៀបចំទីក្រុង (urban development master plan) | របាយការណ៍លទ្ធផលនៃការសិក្សា | ២០២១ | កសហវ |
| ៤ | សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍ ស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាធារណៈ | របាយការណ៍លទ្ធផលនៃការសិក្សា | ២០២២ | កសហវ, ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ និងអាជ្ញាធរមូលដ្ឋាន |
| ៥ | សហការជាមួយក្រសួងទទួលបន្ទុក និងអាជ្ញាធរដែនដីចុះពិនិត្យផ្ទាល់ការអនុវត្ត និងផ្ទៀងផ្ទាត់លើការបង់ចំណូលពីការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចជាការចាក់ដីបំពេញបឹង, ឆ្នេរ, ទន្លេ និងការយកដីសាធារណៈរបស់រដ្ឋដទៃទៀត ដើម្បីផលប្រយោជន៍ឯកជន ហើយត្រូវអនុវត្តតាមច្បាប់ និងនីតិវិធីជាធរមាន ព្រមទាំងបង់ចំណូលចូលថវិការដ្ឋតាមតម្លៃទីផ្សារជាក់ស្តែង | ចុះពិនិត្យផ្ទៀងផ្ទាត់នៅតំបន់ដែលមានការអភិវឌ្ឍខ្លាំង<br>ស្នើសុំគោលការណ៍ និងសេចក្តីណែនាំពីថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/រាជរដ្ឋាភិបាល<br>បំពេញនីតិវិធីលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន<br>បង្កើនការបង់ចំណូលចូលថវិការដ្ឋ | ២០២០ | កសហវ, ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានីខេត្ត |
| **ច** | **ចំណូលពីការចាត់ចែងវត្ថុតាងរឹបអូសពីបទល្មើស** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពន្លឿនការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិរឹបអូសពីបទល្មើសនានា និងបង់ចំណូលចូលថវិការដ្ឋ ស្របតាមនីតិវិធីជាធរមាន មុនមានសាលក្រម/ សាលដីកាស្ថាពរ | ច្បាប់ពាក់ព័ន្ធត្រូវបានធ្វើវិសោធនកម្ម | ២០២០ | ក្រសួងយុត្តិធម៌ |
| ២ | រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូស | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាត្រូវបានរៀបចំ | ២០២១ | ក្រសួងយុត្តិធម៌ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៩ សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីឱ្យមានសង្គតិភាពក្នុងការគ្រប់គ្រង ប្រមូលចំណូលពន្ធគ្រប់ប្រភេទឱ្យមានប្រសិទ្ធភាព តម្លាភាព និងសមធម៌ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីពន្ធដារចាប់ពីឆ្នាំ២០២១ តទៅ។

### ប្រការ ៣.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "ផលរបរ" សំដៅដល់ តម្លៃនៃការផ្គត់ផ្គង់ទំនិញឬសេវាដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ។

២- ពាក្យ "ទ្រព្យសកម្ម" សំដៅដល់ ទ្រព្យសម្បត្តិនានាដែលត្រូវបានយកទៅប្រើប្រាស់ក្នុងអាជីវកម្មដែលរួមមានទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង។

### ប្រការ ៤.- ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម, វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មនិងពាណិជ្ជកម្ម។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចាត់ថ្នាក់ជា បី ប្រភេទ ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិ ដែល÷

ក- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ៦០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

គ- មានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ឃ- រំពឹងថាមានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាខាងមុខ ចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ង- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា រួមទាំងភាសុី។

២- អ្នកជាប់ពន្ធមធ្យមគឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម÷

ក- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល សម្រាប់វិស័យ សេវាកម្ម និងពាណិជ្ជកម្ម ឬ

គ- មានផលរបរប្រចាំឆ្នាំលើសពី ១ ៦០០ លានរៀល ដល់ ៨ ០០០ លានរៀល សម្រាប់វិស័យ ឧស្សាហកម្ម ឬ

ឃ- ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

ង- ជាស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សមាគមឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬ គម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ ឬ

ច- ជាបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ។

៣- អ្នកជាប់ពន្ធធំ គឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម÷

ក- មានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ- មានផលរបរប្រចាំឆ្នាំលើសពី ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្មនិងពាណិជ្ជកម្ម ឬ

គ- មានផលរបរប្រចាំឆ្នាំលើសពី ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ- ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ

ង- ជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**ប្រការ ៥.- ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែងរបស់អ្នកជាប់ពន្ធទេនោះ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលបានប្រើប្រាស់ក្នុងអាជីវកម្មរបស់សហគ្រាសដូចខាងក្រោម÷

១- អ្នកជាប់ពន្ធតូច÷

ក- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំចាប់ពី ២០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

២- អ្នកជាប់ពន្ធមធ្យម÷

ក- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

៣- អ្នកជាប់ពន្ធធំ៖

ក- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

## ប្រការ ៦.- ការអនុវត្ត

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាននិងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសនិងស្ថាប័នពាក់ព័ន្ធនានាត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...... សហវ.ប្រក

# ប្រកាស
## ស្ដីពី
## វិធាននិងនីតិវិធីនៃការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.. គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់វិធាននិងនីតិវិធីអនុវត្ត និងគ្រប់គ្រងការប្រមូលអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយអ្នកជាប់ពន្ធអនិវាសនជនដែលមិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### ប្រការ ២.. វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលធ្វើឡើងដោយអ្នកផ្គត់ផ្គង់អនិវាសនជននៅក្រៅព្រះរាជាណាចក្រកម្ពុជាមកព្រះរាជាណាចក្រកម្ពុជា និងចំពោះអ្នកជាប់ពន្ធនិវាសនជនដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកជាប់ពន្ធអនិវាសនជន។

### ប្រការ ៣.. បុគ្គលជាប់អាករ

សម្រាប់គោលដៅនៃប្រកាសនេះ បុគ្គលជាប់អាករ សំដៅដល់÷

១- អ្នកជាប់ពន្ធអនិវាសនជន ដែលធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម ដូចមានចែងក្នុងប្រការ ១១។

២- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកជាប់ពន្ធអនិវាសនជន។

### ប្រការ ៤.. ការផ្គត់ផ្គង់មិនជាប់អាករ

ការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនូវទំនិញ ឬសេវាដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់មិនជាប់អាករ។

### ប្រការ ៥.. តម្លៃជាប់អាករ

សម្រាប់គោលដៅនៃប្រកាសនេះ តម្លៃជាប់អាករត្រូវកំណត់ដូចខាងក្រោម÷

១- តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញឌីជីថល ឬសេវាឌីជីថល ដែលអ្នកលក់យកពីអ្នកទិញ។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាស ដើម្បីជាផលប្រយោជន៍ផ្ទាល់ ឬប្រយោលដល់អ្នកផ្គត់ផ្គង់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ។

៣- ប្រសិនជាតម្លៃជាប់អាកររបស់ទំនិញឌីជីថល ឬសេវាឌីជីថលដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិត រដ្ឋបាលសារពើពន្ធអាចកំណត់ចេញនូវតម្លៃមួយ ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ដែលរដ្ឋបាលសារពើពន្ធយល់ព្រម។

**ប្រការ ៦.. ពេលផ្គត់ផ្គង់**

អាករលើតម្លៃបន្ថែម ត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់។ ពេលផ្គត់ផ្គង់ ត្រូវបានកំណត់ដូចតទៅ÷

១- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ពេលផ្គត់ផ្គង់គឺជាពេលមុនគេក្នុងចំណោមពេលដែលវិក្កយបត្រត្រូវបានចេញ ឬពេលទំនិញឌីជីថលត្រូវបានប្រគល់ ឬសេវាឌីជីថលត្រូវបានបំពេញ ឬការទូទាត់ត្រូវបានទទួល។

២- ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវគិតអាករជំនួសអ្នកផ្គត់ផ្គង់អនិវាសនជន ពេលផ្គត់ផ្គង់គឺជាពេលមុនគេក្នុងចំណោមពេលដែលទំនិញឌីជីថលត្រូវបានប្រគល់ ឬសេវាឌីជីថលត្រូវបានបំពេញ ឬការទូទាត់ត្រូវដល់កំណត់ ឬបានទូទាត់។

**ប្រការ ៧.. អត្រាអាករ**

អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ១០ភាគរយ លើតម្លៃជាប់អាករចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ ៨.. ឥណទានអាករលើធាតុចូល**

ចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលពីអាជីវកម្មទៅអាជីវកម្ម ប្រាក់អាករដែលបុគ្គលជាប់អាករ ដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣ បានបង់តាមវិធីគិតអាករជំនួស ត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូល។ ឥណទានអាករលើធាតុចូល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២៩ ដល់មាត្រា ៣៩ និងមាត្រា ៤១ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៩.. កាតព្វកិច្ចបង់ពន្ធចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលពីអាជីវកម្មទៅអ្នកប្រើប្រាស់**

បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ដែលបានផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដល់អតិថិជនដែលមិនបានចុះបញ្ជីតាមរបបស្វ័យប្រកាស ឬអ្នកប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

ឧទាហរណ៍÷ បុគ្គលអនិវាសនជន "ក" បានផ្គត់ផ្គង់ទំនិញឌីជីថល ដែលមានតម្លៃជាប់អាករចំនួន ៥០ ០០០ ដុល្លារ ក្នុងខែឧសភា ឆ្នាំ២០២១ ទៅឱ្យអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (មិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស)។ បុគ្គលអនិវាសនជន "ក" ត្រូវចេញវិក្កយបត្រដោយរួមបញ្ចូលតម្លៃទំនិញនិងអាករចំនួន ៥៥ ០០០ ដុល្លារ ឬចេញវិក្កយបត្រថ្លៃទំនិញចំនួន ៥០ ០០០ ដុល្លារ បូកអាករលើតម្លៃបន្ថែមចំនួន ៥ ០០០ ដុល្លារ។

ដូចនេះ បុគ្គលអនិវាសនជន "ក" ត្រូវគណនាអាករដោយប្រើអត្រាប្តូរប្រាក់ជាប្រាក់រៀល ដើម្បីដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១។

**ប្រការ ១០.. កាតព្វកិច្ចបង់ពន្ធចំពោះការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលពីអាជីវកម្មទៅអាជីវកម្ម**

១- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ដែលបានផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដល់បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣

ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ប៉ុន្តែមិនតម្រូវឱ្យបង់ប្រាក់អាករលើតម្លៃបន្ថែមទេ។

២- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣ ដែលទទួលការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលធ្វើឡើងដោយបុគ្គលអនិវាសនជន ត្រូវប្រមូលអាករតាមវិធីគិតអាករជំនួស (Reverse Charge) ហើយធ្វើការដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។

ឧទាហរណ៍÷ បុគ្គលអនិវាសនជន "ក" បានផ្គត់ផ្គង់ទំនិញឌីជីថលមួយដល់ក្រុមហ៊ុន "ខ" ដែលជាបុគ្គលនិវាសនជនជាប់ពន្ធតាមរបបស្វ័យប្រកាស។ បុគ្គលអនិវាសនជន "ក" បានចេញវិក្កយបត្រដែលមានតម្លៃជាប់អាករចំនួន ៤ ០០០ ដុល្លារ ក្នុងខែឧសភា ឆ្នាំ២០២១។ ករណីនេះ ពេលក្រុមហ៊ុន "ខ" ធ្វើការទូទាត់ទឹកប្រាក់ចំនួន ៤ ០០០ ដុល្លារនោះទៅឱ្យបុគ្គលអនិវាសនជន "ក" ហើយក្រុមហ៊ុន "ខ" ត្រូវគណនាអាករលើតម្លៃបន្ថែមលើទឹកប្រាក់ចំនួន ៤ ០០០ ដុល្លារ គុណ ១០ភាគរយ ស្មើ ៤០០ ដុល្លារ ដោយប្រើអត្រាប្តូរប្រាក់ជាប្រាក់រៀល ដើម្បីដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១។

**ប្រការ ១១.. ការចុះបញ្ជីអាករលើតម្លៃបន្ថែម**

១- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ដែលធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមកព្រះរាជាណាចក្រកម្ពុជា មានផលរបរប្រចាំឆ្នាំក្នុងកម្រិតចាប់ពី ២៥០ លានរៀលឡើងទៅ ឬរំពឹងថាមានផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយដែលបានបញ្ចប់នៅក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០ លានរៀលឡើងទៅ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ (Simplified VAT Registration) ឱ្យបានស្រេចបាច់ក្នុងអំឡុងពេល ៣០ថ្ងៃក្រោយផលរបរដល់កំណត់ត្រូវចុះបញ្ជី ដូចមានចែងក្នុងកថាខណ្ឌនេះ។

២- ការបំពេញបែបបទស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែម ត្រូវបានកំណត់ជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ដោយអនុវត្តដូចខាងក្រោម÷

ក- ចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (E-registration) តាមរយៈគេហទំព័រ https://www.tax.gov.kh តាមទម្រង់និងព័ត៌មានដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ឬចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ខ- ចំពោះការចុះបញ្ជីតាមរយៈគេហទំព័រ ឬការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអនិវាសនជនអាចជ្រើសរើសប្រើប្រាស់សេវារបស់ភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីសម្របសម្រួលក្នុងការចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។

គ- ឯកសារតម្រូវសម្រាប់ការចុះបញ្ជីមានដូចខាងក្រោម÷

- ពាក្យស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែម
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីរបស់អ្នកជាប់ពន្ធអនិវាសនជន
- ឯកសារបញ្ជាក់អត្តសញ្ញាណដែលមានសុពលភាពរបស់ម្ចាស់ឬអ្នកតំណាង (អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន)
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេលបីខែ ដែលមានទំហំ ៣៥ x ៤៥មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌សចំនួន ០២សន្លឹក របស់នាយក ឬអ្នកតំណាង
- លិខិតបញ្ជាក់ព័ត៌មានគណនីធនាគាររបស់អ្នកជាប់ពន្ធអនិវាសនជន ដែលចេញដោយ ឬបោះពុម្ពចេញពីប្រព័ន្ធធនាគាររបស់អ្នកជាប់ពន្ធអនិវាសនជន។

ឯកសារតម្រូវខាងលើនេះ អាចប្រើប្រាស់ជាភាសាបរទេស ដោយត្រូវមានវិលេចឬបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។

៣- អ្នកជាប់ពន្ធអនិវាសនជនដែលបានចុះបញ្ជីដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។

៤- កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម÷

ក- ៤០០ ០០០ រៀល សម្រាប់ការចុះបញ្ជីអាករលើតម្លៃបន្ថែម

ខ- ២០០ ០០០ រៀល សម្រាប់ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ÷

- នាមករណ៍សហគ្រាស
- អាសយដ្ឋាន
- សមាសភាពអ្នកគ្រប់គ្រង។

៥- អ្នកជាប់ពន្ធអាចទទួលបានសេចក្ដីសម្រេចចុះបញ្ជីអាករលើតម្លៃបន្ថែម ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងរយៈពេល ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ។

៦- ឯកសារផ្លូវការនៃការចុះបញ្ជីអាករលើតម្លៃបន្ថែម ឬការធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលរដ្ឋបាលសារពើពន្ធត្រូវផ្ដល់ឱ្យអ្នកជាប់ពន្ធជាទម្រង់ឌីជីថល (PDF) មានដូចខាងក្រោម÷

ក- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ

ខ- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ

គ- លិខិតជូនដំណឹងស្ដីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

៧- រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីអាករលើតម្លៃបន្ថែមជាឯកតោភាគី ក្នុងករណីដែលអ្នកជាប់ពន្ធពុំបានមកចុះបញ្ជី ឬមិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ ដោយផ្អែកលើព័ត៌មាននិងទិន្នន័យដែលរដ្ឋបាលសារពើពន្ធមាន។

## ប្រការ ១២.- វិក្កយបត្រអាករ

១- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ត្រូវចេញវិក្កយបត្រ និងប្រមូលប្រាក់អាករពីគ្រប់អ្នកប្រើប្រាស់។ វិក្កយបត្រយ៉ាងតិច ត្រូវមាននិទ្ទេសដូចខាងក្រោម÷

ក- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មចុះបញ្ជីអាករលើតម្លៃបន្ថែម របស់អ្នកជាប់ពន្ធអនិវាសនជន

ខ- ឈ្មោះ អាសយដ្ឋាន និង/ឬលេខអត្តសញ្ញាណកម្មចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់អតិថិជន

គ- លេខវិក្កយបត្រ និងកាលបរិច្ឆេទចេញវិក្កយបត្រ

ឃ- សេចក្ដីបរិយាយមុខទំនិញឌីជីថល ឬសេវាឌីជីថលដែលបានផ្គត់ផ្គង់

ង- តម្លៃជាប់អាករ និងអាករលើតម្លៃបន្ថែម ឬតម្លៃសរុបនៃការផ្គត់ផ្គង់រួមទាំងអាករ។

២- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣ ដែលទទួលការផ្គត់ផ្គង់ជាប់អាករនូវទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវគិតអាករជំនួសអ្នកផ្គត់ផ្គង់អនិវាសនជន ទោះបីអ្នកផ្គត់ផ្គង់អនិវាសនជននោះបាន ឬមិនបានចុះបញ្ជីអាករលើតម្លៃបន្ថែមក្ដី និងត្រូវប្រកាសបង់ប្រាក់អាករលើតម្លៃបន្ថែមផ្អែកលើវិក្កយបត្ររបស់អ្នកផ្គត់ផ្គង់អនិវាសនជនដោយមានឯកសារគាំទ្រការទិញ និងការទូទាត់ប្រាក់។

៣- វិក្កយបត្រអាចប្រើប្រាស់ជាភាសាបរទេស ដោយត្រូវមានបំលែងជាភាសាខ្មែរ ឬភាសាអង់គ្លេស។

## ប្រការ ១៣.- បញ្ជី កំណត់ត្រា និងព័ត៌មាន

១- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ត្រូវរៀបចំរបាយការណ៍អំពីប្រតិបត្តិការនៃការផ្គត់ផ្គង់ប្រចាំខែតាមទម្រង់ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

២- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣ ត្រូវរៀបចំបញ្ជី កំណត់ត្រា និងព័ត៌មានអាករលើតម្លៃបន្ថែមដូចមានចែងក្នុងមាត្រា ៧៩ នៃច្បាប់ស្តីពីសារពើពន្ធ។

### ប្រការ ១៤.- ការអនុគ្រោះភាតពូកិច្ចពន្ធអាករ

១- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៣ ត្រូវបានអនុគ្រោះពីកាតព្វកិច្ចបង់ពន្ធប៉ាតង់។

២- បុគ្គលជាប់អាករដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ៣ ដែលជាអ្នកជាប់ពន្ធតូចបានចុះបញ្ជីស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ត្រូវបានអនុគ្រោះពីកាតព្វកិច្ចអាករលើតម្លៃបន្ថែមតាមយន្តការគិតអាករជំនួសដូចមានចែងក្នុងប្រការ ១០ ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីប្រកាសនេះចូលជាធរមាន។

### ប្រការ ១៥.- ទោសទណ្ឌ

បុគ្គលជាប់អាករដូចមានចែងក្នុងប្រការ ៣ ដែលមិនបានចុះបញ្ជីឬមិនបានធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬមិនបានដាក់លិខិតប្រកាស និងបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធ ត្រូវទទួលរងទោសទណ្ឌដូចមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### ប្រការ ១៦.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ ១៧.- ការអនុវត្ត

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# បញ្ជីឧបសម្ព័ន្ធទី៣

អគ្គនាយកដ្ឋានពន្ធដារ

# ផែនការយុទ្ធសាស្ត្រ

# ២០១៩-២០២៣

បោះពុម្ពឆ្នាំ ២០១៩

# អារម្ភកថា



ដើម្បីកសាងប្រទេសជាតិមួយដែលមានចីរភាព កំណើនសេដ្ឋកិច្ច និងមានការអភិវឌ្ឍជឿនលឿន ប្រទេសរីកចម្រើនទាំងឡាយនៅលើសកលលោកតែងតែយកចិត្តទុកដាក់ជាចម្បងលើប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធផ្ទៃក្នុង ដែលទាមទារចាំបាច់នូវតម្លាភាព ភាពហ្មត់ចត់ និងភាពច្បាស់លាស់ក្នុងការអនុវត្តការងារគ្រប់គ្រង និងប្រមូលចំណូលពន្ធរបស់រដ្ឋបាលសារពើពន្ធ។ ផ្អែកតាមស្មារតីនេះ អគ្គនាយកដ្ឋានពន្ធដារក្នុងនាមជាសេនាធិការរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានយកចិត្តទុកដាក់ខ្ពស់លើការងារគ្រប់គ្រងនិងប្រមូលចំណូលពន្ធផ្ទៃក្នុង ដោយអនុវត្តនូវផែនការយុទ្ធសាស្ត្ររបស់ខ្លួនស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ជាពិសេសគឺ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដែលក្នុងនោះមាន "អភិបាលកិច្ច" ជាស្នូលយុទ្ធសាស្ត្រ និងការដាក់ចេញនូវកម្មវិធី "កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP)" និង "យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ (RMS 2014-2018)"។

ជាលទ្ធផល ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ ការប្រមូលចំណូលពន្ធផ្ទៃក្នុងមានការកើនឡើងគួរឱ្យកត់សម្គាល់ជាប្រវត្តិសាស្ត្រ ដែលពុំធ្លាប់មានពីមុនមកគិតចាប់តាំងពីការបង្កើតរដ្ឋបាលសារពើពន្ធរហូតមកទល់បច្ចុប្បន្ន ដោយលទ្ធផលនៃការប្រមូលចំណូលរក្សាបាននូវកំណើនចំណូលថេរ ក្នុងរង្វង់ជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ។ ពិសេសជាងនេះទៀត ប្រសិនបើពិនិត្យមើលដោយធ្វើការប្រៀបធៀប ចំណូលពន្ធ-អាករដែលប្រមូលបានក្នុងឆ្នាំ ២០១៨ នឹងចំណូលពន្ធ-អាករដែលប្រមូលបានក្នុងឆ្នាំ២០១៣ ឃើញថាមានការកើនឡើងរហូតដល់ ២៤៣,៨៧% ពោលគឺឆ្នាំ២០១៨ សម្រេចបានរហូតដល់ចំនួន ៨ ៧៩១,៤០ ប៊ីលានរៀល (ប្រមាណជា ២ ១៩៧,៨៥ លានដុល្លារអាមេរិក) និងឆ្នាំ២០១៣ សម្រេចបានចំនួន ៣ ៦០៤,៨៩ ប៊ីលានរៀល (ប្រមាណជា ៩០១,២២ លានដុល្លារអាមេរិក)។ លទ្ធផលដ៏ត្រចះត្រចង់នេះ កើតចេញពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងការចង្អុលបង្ហាញដោយផ្ទាល់និងជាប្រចាំរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញនូវ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើ "ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច" និងមានទិសដៅទាំង ៤ រួមមាន កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅឈានទៅជំរុញឱ្យកាន់តែប្រសើរឡើងនូវគុណភាពសេវាអ្នកជាប់ពន្ធ ការធានាបានសមធម៌សង្គម និងចីរភាពកំណើនចំណូលក្នុងការបំពេញតម្រូវការហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍជាតិ។ តាមរយៈនេះ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ត្រូវបានដាក់ចេញ ក្នុងគោលដៅបង្កើនសមត្ថភាពស្ថាប័ននិងធនធានមនុស្សស្របតាមនិយាមជាអន្តរជាតិ ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងស្របតាម

បរិការណ៍អភិវឌ្ឍន៍ថ្មី ការពង្រឹងប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ការកែសម្រួលនិងដាក់ចេញនូវវិធានការគោលនយោបាយដោះស្រាយបញ្ហាប្រឈម និងការបន្តធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធនិងមិនមែនសារពើពន្ធ។ ក្នុងន័យគាំទ្រដល់យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ឱ្យបានសម្រេចជោគជ័យ ខ្ញុំ រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់បានរៀបចំ **ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣** ដែលបានឆ្លងកាត់ការពិនិត្យសម្រិតសម្រាំងយ៉ាងល្អិតល្អន់ ដើម្បីធ្វើយ៉ាងណាកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសារពើពន្ធ តាមរយៈ(១) បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធដោយផ្តល់សេវាប្រកបដោយគុណភាព (២) បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ និង (៣) អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន។ ជារួម ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយគិតគូរពិចារណាយ៉ាងហ្មត់ចត់លើលក្ខខណ្ឌកំណែទម្រង់នានា និងស្ថិតក្នុងក្របខ័ណ្ឌជាក់លាក់មួយ ដែលអាចធានាបាននូវភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ យុត្តិធម៌ក្នុងការប្រកួតប្រជែង និងសមធម៌ក្នុងសង្គម។

ដើម្បីសម្រេចគោលបំណងនិងគោលដៅ ដែលបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រ ក៏ដូចជាលទ្ធផលនៃការប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ជាបន្តបន្ទាប់ទៀត ទន្ទឹមគ្នានឹងការដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ក៏តម្រូវជាចាំបាច់ឱ្យថ្នាក់ដឹកនាំ និងអ្នកចូលរួមអនុវត្តទាំងអស់មានឆន្ទៈមោះមុត មានការលះបង់ និងការទទួលខុសត្រូវខ្ពស់ សំដៅអនុវត្តការងារក្នុងស្មារតីបុរេសកម្ម និងតម្កល់ផលប្រយោជន៍ជាតិ និងអង្គភាពជាធំ។ ក្នុងន័យនេះ ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់ជាន់ថ្នាក់ត្រូវតែប្រកាន់ខ្ជាប់នូវគុណតម្លៃនៃគោលការណ៍សំខាន់ៗចំនួន ៣ គឺ÷ រដ្ឋបាលកិច្ចល្អ (Good Administration), ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ (Effective Leadership and Management), និងជាពិសេស គុណាធិបតេយ្យ (Meritocracy) ដែលសំដៅលើការឱ្យតម្លៃខ្ពស់លើទេពកោសល្យ, សមត្ថភាព, ការខិតខំប្រឹងប្រែង, និងលទ្ធផលការងារ។ លើសពីនេះ ការខិតខំប្រឹងប្រែងអនុវត្តការងារក៏ត្រូវតែអនុលោមតាមអភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន÷ (១) អនុវត្តការងារដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ (២) អនុវត្តការងារជាក្រុម (៣) អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង (៤) មិនត្រូវមើលរំលងកំហុសខ្លួនឯង និងកែតម្រូវកំហុសរបស់ខ្លួនដោយអនុលោមតាមអភិក្រមការងារ ៥ យ៉ាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺ “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**”។

ថ្ងៃពុធ ៩រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ..... ២
**ផ្នែកទី១÷ ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ** ..... ៤
**ផ្នែកទី២÷ គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ** ..... ៥
គោលបំណងទី១÷ បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធ ដោយផ្ដល់សេវាប្រកបដោយគុណភាព ..... ៥
គោលដៅទី១÷កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការរៀបចំនូវប្រព័ន្ធដំណើរការរដ្ឋបាលសារពើពន្ធប្រកបដោយស័ក្ដិសិទ្ធិភាព និងសាមញ្ញភាព ..... ៥
គោលដៅទី២÷ផ្ដល់ជូនអ្នកជាប់ពន្ធនូវព័ត៌មានដែលមានភាពត្រឹមត្រូវ ឯកភាព ទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ ..... ៦
គោលដៅទី៣÷បង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ តាមរយៈការផ្ដល់សេវាអប់រំ និងផ្សព្វផ្សាយ ..... ៧
គោលដៅទី៤÷លើកកម្ពស់សមធម៌ និងតម្លាភាព នៃការបង់ពន្ធ តាមរយៈការគោរពសិទ្ធិ និងការពារផលប្រយោជន៍របស់អ្នកជាប់ពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ..... ៧
គោលដៅទី៥÷ផ្ដល់សេវាដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការ ភាពពេញចិត្ត និងឥរិយាបថជាក់លាក់របស់អ្នកជាប់ពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ..... ៨
គោលដៅទី៦÷លើកកម្ពស់ភាពជាដៃគូឱ្យបានរឹងមាំជាមួយវិស័យឯកជន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនានា ..... ៨
គោលបំណងទី២÷ បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ ..... ៩
គោលដៅទី១÷កំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនៅក្នុងវិស័យដែលមានហានិភ័យខ្ពស់ តាមរយៈការប្រមូលផ្ដុំព័ត៌មានពីប្រភពខាងក្នុង និងខាងក្រៅ ..... ៩
គោលដៅទី២÷ពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារដោយទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ..... ១០
គោលបំណងទី៣÷ អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន ..... ១០
គោលដៅទី១÷អភិវឌ្ឍ និងធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ..... ១១
គោលដៅទី២÷ពង្រឹងប្រសិទ្ធភាពការងារ និងអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈមន្ត្រី ..... ១១
គោលដៅទី៣÷លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងអភិបាលកិច្ច ..... ១២
**ផ្នែកទី៣÷ សេចក្ដីសន្និដ្ឋាន** ..... ១៣

# សេចក្ដីផ្ដើម

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា អគ្គនាយកដ្ឋានពន្ធដារបានផ្ដោតជាចម្បងលើការកែទម្រង់រដ្ឋបាលសារពើពន្ធតាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អ ដោយបានពង្រឹងនិងកែលម្អលើមុខងារស្នូល និងមុខងារគាំទ្រ ព្រមទាំងការកែទម្រង់គោលនយោបាយសារពើពន្ធ សំដៅបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ក្នុងការប្រមូលចំណូលពន្ធ និងបំពេញភារកិច្ចនិងបេសកកម្មប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌។ ជាលទ្ធផល ក្នុងរយៈពេល ៥ឆ្នាំ ជាប់ៗគ្នាចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធ-អាករសម្រេចបានលើសផែនការដែលកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រហូតដល់មានឆ្នាំខ្លះទទួលបានសន្ទុស្សន៍កំណើន២ខ្ទង់។ ជាក់ស្ដែង នៅឆ្នាំ២០១៥ ការប្រមូលចំណូលពន្ធ-អាករសម្រេចបានលើសផែនការប្រចាំឆ្នាំ ១១,៨% និងបន្តលើសផែនការជាបន្តបន្ទាប់ ដែលក្នុងឆ្នាំ២០១៧ និង២០១៨ សម្រេចបានលើសផែនការប្រមាណ ១៥%។ សមិទ្ធផលទាំងនេះកើតចេញពីការចូលរួមយ៉ាងសកម្មរបស់មន្ត្រីពន្ធដារទាំងអស់ក្រោមការគាំទ្រយ៉ាងពេញទំហឹង និងការណែនាំចង្អុលបង្ហាញពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងការតម្រង់ទិសដៅលើកិច្ចការប្រមូលចំណូលពន្ធ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីបន្តបង្កើនសន្ទុស្សន៍ និងនិរន្តរភាពនៃការប្រមូលចំណូលពន្ធឱ្យស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិកាជាតិសម្រាប់បន្តអភិវឌ្ឍប្រទេស និងឆ្លើយតបទៅនឹងការកើនឡើងនៃបញ្ហាប្រឈមថ្មីៗ ដែលកើតចេញពីការវិវឌ្ឍនៃបរិយាកាសធុរកិច្ចជាតិនិងអន្តរជាតិ អគ្គនាយកដ្ឋានពន្ធដារត្រូវតែបង្កើនការយកចិត្តទុកដាក់ និងខិតខំពុះពារបន្ថែមទៀត ក្នុងការដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្ដល់សេវាប្រកបដោយគុណភាពដល់អ្នកជាប់ពន្ធ និងបង្ការ ការពារ និងដោះស្រាយនូវរាល់បញ្ហាប្រឈមក៏ដូចជាហានិភ័យនានាដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ការប្រមូលចំណូលពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ព្រមទាំងវិវឌ្ឍខ្លួនជារដ្ឋបាលសារពើពន្ធដែលប្រមូលចំណូលពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារនេះ ត្រូវបានរៀបចំ និងបោះពុម្ពផ្សាយជាលើកទី១ ដោយអគ្គនាយកដ្ឋានពន្ធដារ បន្ទាប់ពីទទួលបានធាតុចូល និងការប្រឹក្សាយោបល់ពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងជំនាញការជាតិ និងអន្តរជាតិផងដែរ។ ឯកសារនេះគឺជាផែនទីបង្ហាញផ្លូវ និងជាមគ្គុទេសក៍សម្រាប់អគ្គនាយកដ្ឋានពន្ធដារអនុវត្ត និងផ្ដល់ជូនដល់អ្នកជាប់ពន្ធនូវព័ត៌មានស្ដីពី**គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ**ស្របតាមយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រនេះចែកចេញជា ៣ផ្នែកសំខាន់ៗគឺ÷ ផ្នែកទី១-ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ផ្នែកទី២-គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រដែលផ្តោតសំខាន់លើ (១) ការបង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព (២) ការបន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ (៣) ការអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន និងផ្នែកទី៣-សេចក្តីសន្និដ្ឋាន។

# ផ្នែកទី១

## ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារ បំពេញការងារក្នុងក្របខ័ណ្ឌនៃទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ ដូចតទៅ÷

### ទស្សនវិស័យ

ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

### បេសកកម្ម

ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

### គុណតម្លៃ

- ការអនុវត្ត÷ អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ និងតឹងរ៉ឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- វិជ្ជាជីវៈ÷ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ និងងាយស្រួល
- ស័ក្តិសិទ្ធិភាព÷ ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- សុចរិតភាព÷ ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- គារវភាព÷ ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- ភាពបត់បែន÷ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

# ផ្នែកទី២

## គោលបំណង និងគោលដៅយុទ្ធសាស្ត្រ

១. បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព

២. បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ

៣. អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន

### គោលបំណងទី១÷ បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុករបស់អ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព

ការផ្តល់សេវាជូនអ្នកជាប់ពន្ធប្រកបដោយគុណភាព ជាភារកិច្ចចម្បងរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីកាត់បន្ថយបន្ទុក លើកទឹកចិត្ត និងកសាងទំនុកចិត្តដល់អ្នកជាប់ពន្ធឱ្យអនុវត្តកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត។ អគ្គនាយកដ្ឋានពន្ធដារបានកំណត់យកការពង្រឹងគុណភាពនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធជាគោលបំណងអាទិភាព និងបានដាក់ចេញនូវគោលដៅដូចខាងក្រោម÷

#### គោលដៅទី១÷ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការរៀបចំនូវប្រព័ន្ធដំណើរការរដ្ឋបាលសារពើពន្ធប្រកបដោយស័ក្តិសិទ្ធិភាព និងសាមញ្ញភាព

តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ការពង្រឹងមុខងារស្នូលគឺជាផ្នែកមួយនៃការកែទម្រង់ស៊ីជម្រៅរដ្ឋបាលសារពើពន្ធ សំដៅធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និង ធានានូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ ដែលក្នុងនោះ អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សំគាល់ដូចជា÷ ១)ការកែសម្រួល និងធ្វើទំនើបកម្មការងារចុះបញ្ជីពន្ធដារ ២)ការផ្តល់សេវាកាន់តែមានភាពល្អប្រសើរ ៣)ការកាត់បន្ថយបន្ទុករដ្ឋបាលក្នុងការដាក់លិខិតប្រកាសពន្ធ និងការបង់ប្រាក់ពន្ធ ៤)ការសម្រួលការងារសវនកម្មតាមរយៈការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មាន និងពង្រឹងមុខងារស៊ើបអង្កេតបទល្មើសពន្ធដារ ៥)ការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ និងជំរុញការប្រមូលបំណុលពន្ធ តាមរយៈការដាក់ឱ្យអនុវត្តនូវការបង់បំណុលពន្ធជាដំណាក់កាល។ ទោះជាយ៉ាងណាក៏ដោយ ការកែទម្រង់និងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសារពើពន្ធពុំទាន់មានលក្ខណៈពេញលេញនិងគ្រប់ជ្រុងជ្រោយ ដែលអាចឆ្លើយតបទៅនឹងកំណើនតម្រូវការឥតឈប់ឈររបស់អ្នកជាប់ពន្ធក្នុងបរិការណ៍ នៃការវិវឌ្ឍសេដ្ឋកិច្ចសង្គម

និងបរិបទធុរកិច្ច។ ជាក់ស្តែង ការផ្តល់សេវាដល់អ្នកជាប់ពន្ធនៅមានកម្រិត ដែលតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តការកែទម្រង់ និងកែលម្អការផ្តល់សេវាតាមរយៈការប្រតិបត្តិលើមុខងារស្នូលឱ្យមានភាពសាមញ្ញ និងស័ក្តិសិទ្ធិភាព ដើម្បីកាត់បន្ថយបន្ទុក និងបង្កើនការពេញចិត្តរបស់អ្នកជាប់ពន្ធ ដោយដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ កែលម្អដំណើរការចុះបញ្ជីអ្នកជាប់ពន្ធឱ្យមានភាពងាយស្រួល និងសាមញ្ញជាងមុន។*

*យុទ្ធសាស្ត្រទី២÷ កែលម្អដំណើរការនៃការដាក់លិខិតប្រកាសពន្ធ និងការបង់ប្រាក់ពន្ធ ដើម្បីកាត់បន្ថយចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ។*

*យុទ្ធសាស្ត្រទី៣÷ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការធ្វើសវនកម្ម និងស៊ើបអង្កេតបទល្មើសពន្ធដារ។*

*យុទ្ធសាស្ត្រទី៤÷ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។*

*យុទ្ធសាស្ត្រទី៥÷ កាត់បន្ថយបន្ទុករបស់អ្នកជាប់ពន្ធ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការប្រមូលបំណុលពន្ធ។*

*យុទ្ធសាស្ត្រទី៦÷ ធ្វើឱ្យប្រសើរឡើងនូវយន្តការបង្វិលសងអាករលើតម្លៃបន្ថែម។*

## គោលដៅទី២÷ ផ្តល់ជូនអ្នកជាប់ពន្ធនូវព័ត៌មានដែលមានភាពត្រឹមត្រូវ ឯកភាព ទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ

ប្រព័ន្ធពន្ធដារកម្ពុជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ទាំងផ្នែកគោលនយោបាយសារពើពន្ធ និងទំនើបកម្មរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះ ដែលជាលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល និងស្របពេលដែលកម្ពុជាបានចាប់ផ្តើមពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យពន្ធដារទាំងក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងការវិវឌ្ឍនេះ តម្រូវឱ្យមានការធ្វើវិសោធនកម្ម និងបច្ចុប្បន្នភាពលើច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាច្រើនបន្តបន្ទាប់ ដែលជាបញ្ហាប្រឈមសម្រាប់អ្នកជាប់ពន្ធក្នុងការយល់ដឹងឱ្យបានច្បាស់លាស់ និងទាន់ពេលវេលា។ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការផ្សព្វផ្សាយអំពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងធ្វើការឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកជាប់ពន្ធ ដើម្បីចៀសវាងភាពស្រពេចស្រពិល និងការបកស្រាយផ្សេងៗគ្នា។ ដូចនេះ ក្នុងគោលដៅផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរជាងមុន និងដើម្បីឱ្យប្រាកដថាអ្នកជាប់ពន្ធនឹងទទួលបានព័ត៌មានត្រឹមត្រូវ មានលក្ខណៈឯកភាព ទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ រៀបចំ និងផ្តល់ព័ត៌មានត្រឹមត្រូវ ឯកភាព ជូនអ្នកជាប់ពន្ធឱ្យទាន់ពេលវេលា និងតាមគ្រប់មធ្យោបាយ។*

*យុទ្ធសាស្ត្រទី២÷ ផ្តល់ដំណោះស្រាយជូនអ្នកជាប់ពន្ធចំពោះរាល់ចម្ងល់ និងបញ្ហាផ្សេងៗ ឱ្យបានទាន់ពេលវេលា។*

## គោលដៅទី៣៖ បង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ តាមរយៈការផ្តល់សេវាអប់រំ និងផ្សព្វផ្សាយ

ក្នុងគោលដៅផ្តល់ការយល់ដឹងអំពីកាតព្វកិច្ចសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការផ្តល់សេវាអប់រំ និងផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមរយៈការធ្វើសិក្ខាសាលាជូនអ្នកជាប់ពន្ធ ការដាក់ផ្សព្វផ្សាយក្នុងគេហទំព័រ ប្រព័ន្ធបណ្តាញសង្គមរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ជាពិសេសការផ្សព្វផ្សាយ និងរំលឹកអំពីការបង់ពន្ធតាមរដូវកាលដូចជា ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ និងពន្ធលើអចលនទ្រព្យ ជាដើម។ ទោះបីជាមានការផ្សព្វផ្សាយ និងការរំលឹកយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា អ្នកជាប់ពន្ធ និងសាធារណជនមួយចំនួន នៅតែមិនទាន់ទទួលបានការយល់ដឹងបានទូលំទូលាយ ជាពិសេសអ្នកជាប់ពន្ធនៅតាមបណ្តាខេត្តនិងតំបន់ជាយដែន ដែលមានសកម្មភាពសេដ្ឋកិច្ចជាដុំកំភួន។ ដូចនេះ ដើម្បីបង្កើនអនុលោមភាពរបស់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

*យុទ្ធសាស្ត្រទី១៖ រៀបចំឯកសារបោះពុម្ព និងឃ្លីបផ្សព្វផ្សាយអំពីពន្ធដារឱ្យមានលក្ខណៈសាមញ្ញ និងងាយយល់។*

*យុទ្ធសាស្ត្រទី២៖ ផ្តល់ជូននូវកម្មវិធីអប់រំជាប្រចាំដោយប្រើប្រាស់នូវមធ្យោបាយ និងយុទ្ធនាការសមស្របបំផុត។*

*យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការផ្តល់សេវាបន្ថែមទៀត តាមរយៈការកំណត់តម្រូវការផ្តល់សេវាដល់អ្នកជាប់ពន្ធ ដោយធ្វើការស្ទង់មតិនៅតាមកម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល។*

*យុទ្ធសាស្ត្រទី៤៖ ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធក្នុងអំឡុងពេលសវនកម្ម។*

## គោលដៅទី៤៖ លើកកម្ពស់សមធម៌ និងតម្លាភាពនៃការបង់ពន្ធ តាមរយៈការគោរពសិទ្ធិ និងការពារផលប្រយោជន៍របស់អ្នកជាប់ពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងគោលដៅលើកកម្ពស់សមធម៌ និងតម្លាភាពក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបន្តផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងកម្រងសេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានកំណត់តម្លៃ និងរយៈពេលនៃការផ្តល់សេវាច្បាស់លាស់នៅគ្រប់អង្គភាពពន្ធដារ។ ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានរៀបចំដោយដាក់បញ្ចូលគោលការណ៍សមធម៌ជាមូលដ្ឋានគ្រឹះ ដូចជាការកំណត់ប្រភេទអ្នកជាប់ពន្ធ ការយកពន្ធតាមអត្រាកំណើន និងការលើកទឹកចិត្តផ្នែកពន្ធ ជាដើម។ ទោះជាយ៉ាងនេះក៏ដោយ អ្នកជាប់ពន្ធមួយចំនួននៅតែយល់ឃើញថា ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារមិនទាន់មានសមធម៌ និងតម្លាភាពគ្រប់គ្រាន់នៅឡើយ។ ដើម្បីទទួលបាននូវមតិ ឬការរិះគន់ស្ថាបនាពីអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានលើកទឹកចិត្តឱ្យអ្នកជាប់ពន្ធបញ្ចេញមតិយោបល់តាមគ្រប់មធ្យោបាយដូចជា តាមរយៈសារអេឡិចត្រូនិច មជ្ឈមណ្ឌល ផ្តល់ព័ត៌មាន (Call Center) សេវាជជែកជាមួយអគ្គនាយកដ្ឋានពន្ធដារ (GDT Live Chat) ប្រព័ន្ធបណ្តាញសង្គម ប្រអប់សំបុត្រ ឬធ្វើឡើងដោយផ្ទាល់មាត់តាមរយៈបញ្ជរពិគ្រោះយោបល់ ប៉ុន្តែនៅតែមិនទាន់ទទួលបានការជឿទុកចិត្តពេញលេញ

នៅឡើយពីអ្នកជាប់ពន្ធ និងសាធារណជន។ ដើម្បីបន្តលើកកម្ពស់សមធម៌ តម្លាភាព និងកសាងទំនុកចិត្ត អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈទាក់ទងនឹងកម្រៃសេវា និងរយៈពេលផ្តល់សេវា។*

*យុទ្ធសាស្ត្រទី២÷ កែលម្អរដ្ឋបាលសារពើពន្ធ តាមរយៈការទទួលមតិយោបល់ពីអ្នកជាប់ពន្ធតាមគ្រប់មធ្យោបាយ។*

*យុទ្ធសាស្ត្រទី៣÷ បង្កើនជំនឿទុកចិត្តនិងភាពជឿជាក់ពីសាធារណជន តាមរយៈការពង្រឹងសុចរិតភាពរបស់រដ្ឋបាលសារពើពន្ធ។*

## គោលដៅទី៥÷ ផ្តល់សេវាដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការ ភាពពេញចិត្ត និងឥរិយាបថជាក់លាក់របស់អ្នកជាប់ពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

លទ្ធផលនៃកំណើន និងពិពិធកម្មសេដ្ឋកិច្ចធ្វើឱ្យមូលដ្ឋានពន្ធមានការកើនឡើង ដែលតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារចាំបាច់ត្រូវបន្តស្វែងយល់អំពីតម្រូវការ ភាពពេញចិត្ត និងឥរិយាបថរបស់អ្នកជាប់ពន្ធតាមប្រភេទនិងវិស័យ ដើម្បីផ្តល់សេវាប្រកបដោយគុណភាពក្នុងគោលដៅជំរុញឱ្យអ្នកជាប់ពន្ធអនុវត្តបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។ ដើម្បីសម្រេចបាននូវគំនិតផ្តួចផ្តើមថ្មីនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ កំណត់តម្រូវការ ភាពពេញចិត្ត និងឥរិយាបថ តាមប្រភេទអ្នកជាប់ពន្ធលើការផ្តល់សេវា តាមរយៈការស្ទង់មតិ។*

*យុទ្ធសាស្ត្រទី២÷ លើកទឹកចិត្ត និងផ្តល់សេវាជាអាទិភាព សម្រាប់អ្នកជាប់ពន្ធដែលមានអនុលោមភាពខ្ពស់។*

## គោលដៅទី៦÷ លើកកម្ពស់ភាពជាដៃគូឱ្យបានរឹងមាំជាមួយវិស័យឯកជន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនានា

អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងសហការចូលរួមយ៉ាងសកម្មជាមួយវិស័យឯកជន ក្នុងការពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈម និងសំណូមពរ ឬដំណោះស្រាយនានាពាក់ព័ន្ធនឹងពន្ធដារ តាមរយៈវេទិកា កិច្ចពិភាក្សា និងយន្តការភាពជាដៃគូនានា។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារក៏បាននិងកំពុងសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងគោលដៅផ្លាស់ប្តូរព័ត៌មាន និងផ្តល់ផលប្រយោជន៍ទាំងក្នុងការប្រមូលចំណូលពន្ធ និងទាំងក្នុងការបំពេញការងាររបស់ស្ថាប័នសាមីផងដែរ។ ជាក់ស្តែង កិច្ចសហការជាមួយវិស័យឯកជននៅតែតម្រូវឱ្យមានការលើកកម្ពស់បន្ថែមទៀត ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមរបស់អ្នកជាប់ពន្ធ និងប្រមូលធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយ សម្រាប់កែលម្អគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ ដោយឡែក ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធដែលមិនទាន់មាន ឬមានយន្តការដែលមិនមានប្រសិទ្ធភាព តម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារស្វែងរកលទ្ធភាពបង្កើត

ឬកែសម្រួលយន្តការសមស្រប ដើម្បីផ្លាស់ប្តូរព័ត៌មាន ក្នុងទិសដៅប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ រៀបចំកម្មវិធីជួបពិភាក្សាជាប្រចាំ ដើម្បីប្រមូលធាតុចូល និងស្វែងរកដំណោះស្រាយពីវិស័យឯកជន។*

*យុទ្ធសាស្ត្រទី២÷ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ តាមរយៈការបង្កើតយន្តការគាំទ្រ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការផ្លាស់ប្តូរព័ត៌មាន។*

## គោលបំណងទី២÷ បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ

ការបន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយប្រកាន់ខ្ជាប់នូវភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាពចំពោះអ្នកជាប់ពន្ធ ជំរុញឱ្យមានការកាត់បន្ថយឬលុបបំបាត់នូវការធ្វេសប្រហែស ការគេចវេះ និងការកិបកេងបន្លំពន្ធ ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។ ការវិវឌ្ឍនៃបរិយាកាសធុរកិច្ច ដែលមានភាពស្មុគស្មាញនិងប្រទាក់ក្រឡា កំណើនយ៉ាងគំហុកនូវលំហូរពាណិជ្ជកម្មនិងវិនិយោគអន្តរជាតិ និងជាពិសេសការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រព័ន្ធសេដ្ឋកិច្ចឌីជីថល ខណៈដែលច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមានអាចពុំទាន់បានឆ្លើយតបបានទាំងស្រុងទៅនឹងការវិវឌ្ឍនៃប្រតិបត្តិការអាជីវកម្ម ដែលមានលក្ខណៈស្មុគស្មាញទាំងនោះ តម្រូវឱ្យអគ្គនាយដ្ឋានពន្ធដារបន្តពង្រឹងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធ តាមរយៈការអនុវត្តច្បាប់ និងបទប្បញ្ញត្តិដោយទន់ភ្លន់តែម៉ឺងម៉ាត់ និងកែលម្អ ព្រមទាំងរិះរកនូវវិធានការថ្មីៗប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីបំពេញនូវចន្លោះប្រហោងច្បាប់និងបទប្បញ្ញត្តិដែលកន្លងមកផ្តល់ឱកាសឱ្យមានការគេចវេះ និងកិបកេងបន្លំពន្ធ។ ដើម្បីសម្រេចគោលបំណងនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវគោលដៅ ដូចខាងក្រោម÷

### គោលដៅទី១÷ កំណត់អត្តសញ្ញាណអ្នកជាប់ពន្ធ ដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធ នៅក្នុងវិស័យដែលមានហានិភ័យខ្ពស់ តាមរយៈការប្រមូលផ្តុំព័ត៌មានពីប្រភពខាងក្នុង និងខាងក្រៅ

ការកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមិនបានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវ នៅក្នុងវិស័យដែលមានហានិភ័យខ្ពស់ ជាវិធីសាស្ត្រគន្លឹះក្នុងការជ្រើសរើសអ្នកជាប់ពន្ធ សម្រាប់ការធ្វើសវនកម្មចំគោលដៅ។ បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការកែលម្អវិធីសាស្ត្រកំណត់ហានិភ័យ រៀបចំផែនការសវនកម្មនិងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធក្នុងវិស័យដែលមានហានិភ័យខ្ពស់។ ទោះបីជាមានការអភិវឌ្ឍលើវិធីសាស្ត្រក្នុងការកំណត់ហានិភ័យ ប៉ុន្តែដើម្បីលើកកម្ពស់គុណភាពនៃការកំណត់ហានិភ័យសម្រាប់ការធ្វើសវនកម្មចំគោលដៅ និងទាន់ពេលវេលា តម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តកែលម្អវិធីសាស្ត្រទាំងនោះឱ្យមានស្តង់ដាររួម និងដំណើរការដោយស្វ័យប្រវត្តិ សំដៅធានាបាននូវសុក្រឹតភាព និងប្រសិទ្ធភាព។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ អភិវឌ្ឍ និងកែលម្អវិធីសាស្ត្រកំណត់ហានិភ័យឱ្យមានស្តង់ដាររួម ដើម្បីឈានទៅបង្កើតប្រព័ន្ធកំណត់ហានិភ័យជាស្វ័យប្រវត្តិ។*

*យុទ្ធសាស្ត្រទី២÷ កំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់។*

*យុទ្ធសាស្ត្រទី៣÷ ជំរុញ ពង្រឹង និងពន្លឿនការផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលាសម្រាប់គោលបំណងសវនកម្ម និងដើម្បីឈានទៅបង្កើតប្រព័ន្ធផ្លាស់ប្តូរព័ត៌មានជាស្វ័យប្រវត្តិ។*

## គោលដៅទី២÷ ពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព

ឥរិយាបថរបស់អ្នកជាប់ពន្ធមួយចំនួនក្នុងការព្យាយាមគេចវេះពន្ធ និងកិបកេងបន្លំពន្ធ បង្កឱ្យមានការប្រកួតប្រជែងមិនស្មើភាព និងប៉ះពាល់ដល់សមធម៌ក្នុងការបង់ពន្ធ។ ដើម្បីលើកកម្ពស់អនុលោមភាពពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានបន្តដាក់ចេញនូវវិធានការជាច្រើន ក្នុងការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដូចជា ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាប្រចាំ ការដកហូតជាបណ្តោះអាសន្ននូវវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ការចាត់មន្ត្រីពន្ធដារទៅប្រចាំការនៅទីតាំងផលិតដែលត្រូវជាប់អាករពិសេស ការកំណត់ហានិភ័យក្នុងការធ្វើសវនកម្មឱ្យចំគោលដៅ និងកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសពន្ធដារដោយម៉ឺងម៉ាត់ ការកែលម្អវិធានការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ការពង្រឹងការអនុវត្តវិធានការតឹងទារបំណុលពន្ធ និងការជំរុញការចរចាកិច្ចព្រមព្រៀងស្តីពីចៀសវាងការយកពន្ធត្រួតគ្នា។ល។ ទោះជាមានវិធានការរឹងមាំដូចខាងលើក៏ដោយ អគ្គនាយកដ្ឋានពន្ធដារចាំបាច់ត្រូវបន្តកែសម្រួល និងលើកកម្ពស់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដោយផ្តោតសំខាន់លើមុខងារស្នូល ដើម្បីជំរុញការប្រកួតប្រជែងដោយស្មើភាព និងសមធម៌ក្នុងការបង់ពន្ធ។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ ពង្រឹងការចុះបញ្ជីពន្ធដារ។*

*យុទ្ធសាស្ត្រទី២÷ ពង្រឹងការចាត់ថែងលិខិតប្រកាស។*

*យុទ្ធសាស្ត្រទី៣÷ ពង្រឹងការធ្វើសវនកម្ម និងស៊ើបអង្កេតបទល្មើសពន្ធដារ។*

*យុទ្ធសាស្ត្រទី៤÷ ពង្រឹងការគ្រប់គ្រងប្រមូលបំណុលពន្ធ និងការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ។*

*យុទ្ធសាស្ត្រទី៥÷ ពង្រឹងការបង្វិលសងអាករលើតម្លៃបន្ថែម។*

*យុទ្ធសាស្ត្រទី៦÷ រៀបចំ កែសម្រួល និងធ្វើឱ្យប្រសើរឡើងនូវច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃបរិបទធុរកិច្ចជាតិ និងអន្តរជាតិ។*

## គោលបំណងទី៣÷ អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន

អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងធ្វើការកែទម្រង់លើការគ្រប់គ្រងធនធានមនុស្ស ដើម្បីគាំទ្រស្ថាប័នក្នុងការជំរុញឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពការងារ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឆ្លើយតបទៅនឹងកំណើនការងារនៅក្នុងអង្គភាពទំនើបកម្មធុរកិច្ច

និងជំរុញផលិតភាពនៃការបំពេញការងាររបស់មន្ត្រី និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តខិតខំបន្ថែមទៀតក្នុងការអភិវឌ្ឍស្ថាប័ន តាមរយៈការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មាន ពង្រឹងសមត្ថភាពជំនាញ ក្រមសីលធម៌វិជ្ជាជីវៈ និងអភិបាលកិច្ច។ ដើម្បីសម្រេចបានគោលបំណងនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវគោលដៅ ដូចខាងក្រោម÷

## គោលដៅទី១÷ អភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលសារពើពន្ធ តាមរយៈបច្ចេកវិទ្យាព័ត៌មាន

ក្នុងការធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការពង្រឹងការប្រតិបត្តិការងារផ្ទៃក្នុង និងការផ្តល់សេវាដល់អ្នកជាប់ពន្ធ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមានប្រព័ន្ធប្រមូលផ្តុំទិន្នន័យនិងព័ត៌មាន (Centralized Database System) ដូចជា ការគ្រប់គ្រងការចុះបញ្ជី ការដាក់លិខិតប្រកាស សវនកម្ម បំណុលពន្ធនិងបណ្តឹងតវ៉ា របាយការណ៍ចំណូលពន្ធ ការតាមដានឯកសារ និងការគ្រប់គ្រងធនធានមនុស្ស ព្រមទាំងកម្មវិធីសម្រាប់ប្រើប្រាស់លើឧបករណ៍អេឡិចត្រូនិចផ្សេងៗ។ ដើម្បីឈានទៅទំនើបកម្មរដ្ឋបាលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបន្ថែមទៀត ឱ្យស្របតាមការវិវឌ្ឍ និងឧត្តមានុវត្តន៍នៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ បង្កើត ធ្វើបច្ចុប្បន្នភាព និងកំណែទៅជំនាន់ថ្មី នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រ និងទំនើបកម្មរដ្ឋបាលសារពើពន្ធ។*

*យុទ្ធសាស្ត្រទី២÷ បង្កើត ជំរុញ និងធ្វើឱ្យប្រសើរឡើងនូវនីតិវិធីប្រតិបត្តិការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។*

## គោលដៅទី២÷ ពង្រឹងប្រសិទ្ធភាពការងារ និងអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈមន្ត្រី

ការអភិវឌ្ឍធនធានមនុស្សត្រូវបានចាត់ទុកថាជាកត្តាគន្លឹះ ក្នុងការបង្កើនប្រសិទ្ធភាពក្នុងការប្រមូលពន្ធ ហេតុនេះទើបអគ្គនាយកដ្ឋានពន្ធដារតែងតែយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្ត្រីពន្ធដារ តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសលើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងពន្ធដារ ព្រមទាំងជំនាញទន់ (Soft Skills) ដូចជាជំនាញគ្រប់គ្រង ជំនាញប្រាស្រ័យទាក់ទង ជំនាញដោះស្រាយបញ្ហា និងជំនាញធ្វើការជាក្រុម។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារខ្ពស់ជាងមុន អគ្គនាយកដ្ឋានពន្ធដារត្រូវពង្រឹងសមត្ថភាពមន្ត្រី និងថ្នាក់ដឹកនាំបន្ថែមទៀត។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ ស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ អគ្គនាយកដ្ឋានពន្ធដារឱ្យស្របតាមការអភិវឌ្ឍសេដ្ឋកិច្ច និងបរិបទធុរកិច្ចជាតិ និងអន្តរជាតិ។*

*យុទ្ធសាស្ត្រទី២÷ ពង្រឹងគុណភាពការងារ និងលើកកម្ពស់ការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍។*

*យុទ្ធសាស្ត្រទី៣÷ ពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំ របស់អ្នកគ្រប់គ្រង (ប្រធានការិយាល័យ អនុប្រធានសាខា ប្រធានសាខា និងអនុប្រធាននាយកដ្ឋាន)។*

## គោលដៅទី៣÷ លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងអភិបាលកិច្ច

ក្រៅពីសមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្ត្រីពន្ធដារ ក្រមសីលធម៌វិជ្ជាជីវៈនិងអភិបាលកិច្ចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនផលិតភាព និងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធប្រកបដោយគុណតម្លៃ ដើម្បីបង្កើននូវជំនឿទុកចិត្តពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជនចំពោះរដ្ឋបាលសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើការកែទម្រង់លើការគ្រប់គ្រងធនធានមនុស្ស ដោយជំរុញនិងលើកទឹកចិត្តមន្ត្រីឱ្យមានស្មារតីទទួលខុសត្រូវខ្ពស់ បង្កើនភាពម្ចាស់ការលើការងារ និងការបំពេញភារកិច្ចឱ្យអស់ពីសមត្ថភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស) ក្នុងការគ្រប់គ្រងប្រចាំថ្ងៃ និងវាយតម្លៃលទ្ធផលការងារជាប្រចាំ។ អគ្គនាយកដ្ឋានពន្ធដារក៏បានផ្តោតសំខាន់ផងដែរលើការធ្វើសវនកម្មផ្ទៃក្នុង ដែលមានសារៈសំខាន់ក្នុងការគ្រប់គ្រងធនធានមនុស្ស និងសម្ភារបរិក្ខារដោយម៉ត់ចត់ សំដៅធានាបានការប្រើប្រាស់ចំទិសដៅ បង្កើនគណនេយ្យភាពអភិបាលកិច្ច និងភាពជឿទុកចិត្ត។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក៏ដោយ ក៏កម្រិតនៃក្រមសីលធម៌វិជ្ជាជីវៈនិងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារត្រូវតែបន្តពង្រឹងបន្ថែម។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម÷

*យុទ្ធសាស្ត្រទី១÷ ពង្រឹងប្រសិទ្ធភាព និងគុណភាពការងារតាមរយៈសវនកម្មផ្ទៃក្នុង។*

*យុទ្ធសាស្ត្រទី២÷ ពង្រឹងប្រសិទ្ធភាពការងារ និងគុណភាពធនធានមនុស្ស។*

*យុទ្ធសាស្ត្រទី៣÷ ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយឱ្យស្របតាមផែនការយុទ្ធសាស្ត្រថវិកា។*

# ផ្នែកទី៣

## សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ គឺជាមគ្គទេសក៍ក្នុងការបន្តពង្រឹងការកែទម្រង់ស៊ីជម្រៅរបស់រដ្ឋបាលសារពើពន្ធ ក៏ដូចជាចូលរួមក្នុងការកែលម្អគោលនយោបាយសារពើពន្ធ ដើម្បីធ្វើទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ និងសម្រេចឱ្យបានជោគជ័យនូវចក្ខុវិស័យ គោលបំណង គោលដៅ និងស្របតាមអភិក្រម ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រនេះ នឹងប្រែក្លាយមុខមាត់ និងលើកកម្ពស់កិត្យានុភាពរបស់អគ្គនាយកដ្ឋានពន្ធដារមួយកម្រិតថែមទៀតទាំងក្នុងប្រទេស ក្នុងតំបន់ និងឆាកអន្តរជាតិ ក្នុងនាមជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

ដើម្បីសម្រេចឱ្យបានជោគជ័យនូវគោលបំណងជាយុទ្ធសាស្ត្រទាំងបី ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ ទាមទារឱ្យមានការប្តេជ្ញាចិត្តខ្ពស់និងការចូលរួមយ៉ាងសកម្មពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារទាំងអស់ ការគាំទ្រដ៏ខ្លាំងក្លាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការសហការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអ្នកជាប់ពន្ធ ដោយឈរលើគោលការណ៍សាមគ្គីភាព សុចរិតភាព ស្មើភាព យុត្តិធម៌ សមធម៌ និងតម្កល់ផលប្រយោជន៍ជាតិជាធំ។

# អគ្គនាយកដ្ឋានពន្ធដារ

អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) កែងនិងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់ ១, ខណ្ឌទួលគោក, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +855 23 886 708 / ទូរសារ៖ +855 23 886 700
សារអេឡិចត្រូនិក៖ gdt@tax.gov.kh / គេហទំព័រ៖ www.tax.gov.kh